# មង្គលកថា

## មង្គលទី ៣



រៀបរៀងដោយ
ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី
ព.ស.២៥៥៧

# មង្គលកថា

## មង្គលទី ៣



រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី**

ព.ស.២៥៥៧

# ពុទ្ធប្បវត្តិសង្ខេប

ព្រះពុទ្ធមានព្រះនាមថាព្រះសទ្ធត្ថជាបុគ្គលប្រសើរបំផុតក្នុងលោក។ បិតាព្រះនាម សុទ្ធោទនៈ, មាតាព្រះនាម សិរិមហាមយា, ព្រះនគរឈ្មោះ កបិលពស្តុ, សព្វថ្ងៃជាប្រទេសនេប៉ាល បែកចេញពីឥណ្ឌា, ប្រសូតនៅថ្ងៃ សុក្រ ១៥ កើត ខែវិសាខ ឆ្នាំ ច, ត្រកូលជាក្សត្រ សក្យវង្ស តំណពីព្រះ បាទឱក្កាករាជ ប្អូនរួមបិតាព្រះនាម ព្រះនន្ទ មាតាផ្សេងគ្នា ព្រះជន្ម ១៦ ព្រះវស្សា មានអគ្គមហេសី ព្រះនាមពិម្ពាយសោធរា ព្រះជន្ម ២៩ ព្រះវស្សា រាហុលជាបុត្រប្រសូត និង ទ្រង់ចេញសាងផ្នួសព្រះជន្ម ២៩ ព្រះវស្សា ត្រាស់ជាព្រះពុទ្ធព្រះជន្ម ៣៥ ព្រះវស្សា ព្រះនាមថា សមណៈគោតម ។

# ស្ថានទីគង់ចាំព្រះវស្សា

១-ឥសិបតនមិគទាយវ័ន, ២-៤ វត្តវេឡុវ័ន, ៥-កូដាគារសាលាមហាវ័ន ៦-មកុជបព៌តដែនមគធៈ, ៧-ឋានតាវត្តិង្ស, ៨-ភេសកឡាវ័ន ភគ្គរាជ-ជនបទ, ៩-ឃោសិតារាម, ១០-ព្រៃបាលិលេយ្យ ១១-ជង់ព្រៃជិតស្រុក សាលា លេយ្យកៈ,១២-ក្រោមដើមស្ដៅជិតស្រុកវេរញ្ជា,១៣-ចាលិកប-ពត៌, ១៤-វត្តជេតពន ១៥- វត្តនិគ្រោធារាម, ១៦-ស្រុកអាឡវី, ១៧-វត្តវេឡុវ័ន១៨-១៩-ចាលិកបពត៌ ២០- វេឡុវ័ន, ២១-៤៤ វត្តជេតពន, ៤៥- ស្រុកវេឡុវគ្រាម ។

ព្រះជន្ម ៨០ ព្រះវស្សា ដាក់ព្រះជន្មាយុ និងបរិព្វានក្នុងនគរ កុសិនារា នៅថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ ក្នុងវេលាជិតភ្លឺ ។ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនា ៥.០០០ ព្រះវស្សា រហូតរៀងមក ។

## ទេវតាមួយម៉ឺនចក្រវាឡ ចុះមកអារាធនាសូមឱ្យព្រះអង្គសម្ដែងមង្គល




រឿងមង្គលនេះ ទេវតាមួយម៉ឺនចក្រវាឡប្រើពេលអស់១២ឆ្នាំរកមង្គល តែរកមិនឃើញ លុះដល់ព្រះអង្គបានត្រាស់ដឹងក៏នាំគ្នាចុះមកទូលសួរព្រះអង្គ ។ ព្រះអង្គបានសម្ដែងមង្គលទាំង៣៨ប្រការ មានកិរិយាមិនសេពគប់បុគ្គលពាលជាដើម រហូតដល់មានចិត្តក្សេមក្សាន្ត កាលចប់ **ទេវតាសម្រេចជាព្រះអរហន្តរាប់សែនកោដិ ។ សម្រេចជាសោតាបត្តិផល សកទាគាមិផល អនាគាមិផល រាប់ប្រមាណមិនបាន ។**

# មង្គលកថា

## មង្គលទី ៣

រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

**វត្តនិគ្រោធវ័ន គល់ទទឹង**

ព.ស. ២៥៥៧

-ឈ្មោះសៀវភៅ **មង្គលកថាមង្គលទី ៣**

-រៀបរៀងដោយ **ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

-អនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រដោយ **អគ្គធីរោ គង់ សុមិត្ត**

-**ចេញផ្សាយ** លើកទី ១

-**កាលបរិច្ឆេទ** ព.ស. ២៥៥៧

- **ទីកន្លែងធ្វើ** វត្តនិគ្រោធវ័ន"គល់ទទឹង" ភូមិកោះក្របី

សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ

\

# អារម្ភកថា

មនុស្សនៅលើសកលលោកយើងនេះ សុទ្ធតែជាអ្នកប្រាថ្នានូវសេចក្តីសុខចម្រើន សិរីសួស្តី សុភមង្គល ភាពសុខដុមរមនាគ្រប់គ្នា ៗទាំងអស់ មិនចំពោះថា ជាតិសាសន៍ណាឡើយ មានអ្នកខ្លះព្រោះតែចង់បានសេចក្តីសុខ ចម្រើន សិរីសួស្តី សុភមង្គលដល់ជីវិតខ្លាំងពេកទៅ រហូតដល់ថ្នាក់ បន់ស្រន់បួងសួង អារក្សអ្នកតាទេវតា ព្រៃភ្នំ មន្តអាគមអូមអាមផ្សេង ៗនិងមានអ្នកខ្លះទៀតយល់ថា ទាល់តែមានទ្រព្យ សម្បត្តិស្តុកស្តម្ភ មានយសសក្តិខ្ពង់ខ្ពស់ មានគេគោរពលើកតម្កើង បរិវារ ហែហម ចោមរោម ការពារគ្រប់ជំហានជាដើម ទើបជីវិតមាននៅសិរី សួស្តីសុភមង្គល ។ ទង្វើទាំងអស់នេះ វាផ្ទុយស្រឡះអំពីគន្លងនៃព្រះពុទ្ធសាសនាទាំងស្រុង ។

នៅក្នុងព្រះធម៌របស់ព្រះអង្គទាំង ៨៤,០០០ ព្រះធម្មខន្ធ ដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកទាំង ១១០ ក្បាល ដោយព្រះអង្គសម្តែងអស់រយៈពេល ៤៥ ព្រះវស្សានោះ ទាំងសម្តែងឋានទេវតា ឋានមនុស្សគ្រប់ស្រុកតំបន់ផ្សេង ៗនោះ មានព្រះសូត្រមួយឈ្មោះថា **មង្គលសូត្រ** ដែលជាព្រះសូត្រសម្តែងអំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តុង្គឧត្តមនៃជីវិត ។ និងជាព្រះសូត្រ ដែលព្រះអង្គសម្តែងបើកបង្ហាញដល់មនុស្សនិង

ទេវតានាសម័យនោះ ។ ព្រះសូត្រនេះសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលប្រាថ្នានូវសិរីសួស្តីដល់ខ្លួនឯង ក្រុមគ្រួសារ ញាតិមិត្តបងប្អូន និងសង្គមជាតិទាំងមូល ។ ព្រោះព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំតែម្តង អំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តមនៃជីវិត ។

នៅក្នុងអដ្ឋកថា **មង្គលជាតក** បានពោលអំពីព្រាហ្មណ៍ម្នាក់ អ្នកនៅក្នុងក្រុងនគររាជគ្រឹះ ជាអ្នកប្រកាន់មង្គលភ្ញាក់ផ្អើលមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាបុគ្គលមិច្ឆាទិដ្ឋិ មានភោគសម្បត្តិច្រើន ។

ក្នុងកាលនោះកណ្តុរបានកាត់នូវសម្ពត់សាដកមួយគូរបស់គាត់ ។ ដល់ពេលគាត់ត្រូវការឱ្យគេយកសំពត់នោះមក ទើបដឹងថាត្រូវកណ្តុរកាត់ដាច់ជាអន្លើ ៗទៅហើយ ។ ព្រាហ្មណ៍គិតថា សំពត់នេះជាអពមង្គល បើទុកនៅទីផ្ទះនាំឱ្យមានការវិនាសយ៉ាងក្រៃលែង គឺវាដូចជាកាឡកណ្ណីមួយអ៊ីចឹង ទាំងមិនអាចឱ្យដល់បុត្រធីតា ឬទាសកម្មករផង ព្រោះសេចក្តីវិនាសនឹងកើតដល់អ្នកទទួលសំពត់នោះទៅគ្រប់គ្នា ត្រូវយកទៅចោលក្នុងព្រៃខ្មោចទើបបាន ។

ព្រាហ្មណ៍មិច្ឆាទិដ្ឋិ មិនឱ្យពួកទាសកម្មករយកទៅបោលទេ ដោយខ្លាចពួកទាសកម្មករ នាំយកនូវសំពត់នោះទៅប្រើប្រាស់ បណ្ដាលឱ្យវិនាសត ៗគ្នា ។ ទើបព្រាហ្មណ៍ប្រាប់ឱ្យកូនប្រុសរបស់គាត់យកឈើឆ្កឹះទាក់នូវសំពត់នោះ នាំទៅបោលនៅព្រៃខ្មោច ហើយត្រូវងូតទឹកមុជឱ្យលិចក្បាលសឹមត្រឡប់មកផ្ទះវិញ ។

ព្រះបរមសាស្ដាសម្មាសម្ពុទ្ធគង់ប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ជ្រាបឧបនិស្ស័យនៃព្រាហ្មណ៍ពីរនាក់ឪពុកនិងកូន ព្រះអង្គបានយាងទៅកាន់ព្រៃខ្មោចនោះ ហើយទ្រង់កាន់យកនូវសំពត់សាជកដែលកូនប្រុសរបស់ព្រាហ្មណ៍បានបោលហើយ ទាំងដែលកូន ប្រុសនោះឃាត់ព្រះអង្គមិនឱ្យចាប់ ដោយអាងថា ជារបស់ចង្រៃ ។ ព្រះបរមសាស្ដាទ្រង់កាន់យកនូវសំពត់មួយគូរនោះ វិលត្រឡប់មកកាន់វត្តវេឡុវ័នវិញ ។

កាលដែលកូនប្រុសត្រឡប់មកជម្រាបរឿងរ៉ាវ ដល់ឪពុកហើយ ឪពុកនិងកូនក៏ប្រញាប់នាំគ្នាទៅវត្តវេឡុវ័ន ដើម្បីសូមឱ្យព្រះសម្មាសម្ពុទ្ធបោលនូវសំពត់នោះទៅវិញ ។ ព្រាហ្មណ៍គិតថា បើព្រះសមណគោតម ប្រើសំពត់នេះទៅ វាត្រូវធ្វើឱ្យលំបាកដល់ព្រះអង្គផង ត្រូវវិនាសវត្តវេឡុវ័នផង ម្ល៉ោះហើយគេនិងនិន្ទាស្ដីថា

មកដល់យើងជាពិតប្រាដក ដូច្នេះ យើងត្រូវយកសំពត់សាដក ថ្មី ៗទៅថ្វាយដល់ព្រះសមណគោតម ដើម្បីសូមឱ្យព្រះសមណ គោតម បោលនូវសំពត់ចង្រៃនោះ ។

នៅពេលដែលព្រាហ្មណ៍ឪពុកនិងកូនប្រុសបានទៅដល់វត្ត ហើយ ព្រាហ្មណ៍ជាឪពុកបានក្រាបទូលព្រះសម្មាសម្ពុទ្ធដោយ សព្វគ្រប់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួក យើងមានឈ្មោះថាជាបព្វជិតដូច្នេះសំពត់ចាស់ ៗដែលគេបោល នៅព្រៃខ្មោច ឬគំនរសម្រាមជាដើម រមែងសមគួរដល់ពួកយើង ឯចំណែកព្រាហ្មណ៍ឯង មិនមែនទើបតែឥឡូវនេះទេ ពីជាតិមុន មក ក៏ធ្លាប់ប្រកាន់នូវលទ្ធិដូច្នេះដែរ ។

កាលដែលព្រាហ្មណ៍អារាធនាហើយ ព្រះអង្គទ្រង់ត្រាស់ សម្តែងនូវរឿងរ៉ាវអតីតជាតិ មានសេចក្តីប្រហែលគ្នានឹងបច្ចុប្បន្ន ដែរគ្រាន់តែកាលណោះ ព្រះបរមពោធិសត្វជាតាបសបានឈាន ហើយប្រោសព្រាហ្មណ៍ ឯព្រាហ្មណ៍ក៏បានយកព្រះបរមពោធិសត្វ ជាសរណៈ ។

នៅក្នុងបិដលេខ ៥៨ ទំព័រ ៣៨ **មង្គលជាតក** ព្រះ បរមសាស្តាទ្រង់ត្រាស់ថា ៖

មង្គលទាំងឡាយក្តី ឧត្បាតទាំងឡាយក្តី សុបិនទាំងឡាយក្តី លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណាបានផ្តាច់បង់ហើយ បុគ្គលនោះឈ្មោះថា អ្នកកន្លងផុតនូវទោសនៃមង្គល(ភ្ញាក់ផ្អើល) ។ ជាអ្នកគ្របសង្កត់នូវយុគក្កិលេស(ក្រោធ ១ ការចងគំនុំ ១ ការរមិលគុណ ១ និងការវាយឫកស្មើ ១ ទាំង ៤ នេះ ហៅថា យុគក្កិលេស)និងយោគក្កិលេស(កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ១អវិជ្ជាយោគ ១)រមែងមិនមកកើតទៀតឡើយ ។

ដោយសេចក្តីថា បុគ្គលណាមិនប្រកាន់មង្គលភ្ញាក់ផ្អើល មិនប្រកាន់ឧត្បាត មិនប្រកាន់ការយល់សប្តិ មិនប្រកាន់លក្ខណៈជោគល្អ ឬជោគអាក្រក់ បុគ្គលនោះឈ្មោះថា ជាអ្នកកន្លងផុតនូវទោសនៃការប្រកាន់មង្គលភ្ញាក់ផ្អើល ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ឱ្យព្រាហ្មណ៍ឪពុក និងកូនបានសម្រេចសោតាបត្តិផល ។

នៅក្នុងអដ្ឋកថា**នក្ខត្តជាតក** បានពោលអំពីត្រកូលមួយនៅក្រៅក្រុងសាវត្ថី បានទៅស្តីដណ្តឹងកុលធីតាម្នាក់នៅក្នុងក្រុងសាវត្ថី ដើម្បីជាប្រយោជន៍ដល់កូនប្រុសរបស់ខ្លួន ។ គេបានសន្យាថ្ងៃកំណត់មកទទួលយកកូនកូនស្រីទៅកាន់ត្រកូលខាងប្រុស ប៉ុន្តែ

លុះដល់ថ្ងៃកំណត់ ត្រកូលខាងប្រុសគេបានសួរអាជីវកម្នាក់ដែលបានចូលទៅកាន់ត្រកូលរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើនូវមង្គលមួយ តើនក្ខត្តឫក្សល្អដែរទេ ?

អាជីវកមានការខឹងក្រោធជាខ្លាំង ព្រោះគិតថាពួកអស់នេះមិនសួរយើងពីដំបូង ឥឡូវដល់ថ្ងៃទៅហើយទើបតែសួរ យើងនឹងផ្ដល់មេរៀនឱ្យគេម្ដង ដូច្នេះហើយក៏ពោលថា ថ្ងៃនេះមិនល្អទេ អ្នកទាំងអស់គ្នាកុំធ្វើមង្គលឡើយ បើចចេសចេះតែធ្វើនឹងមានការវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលក៏ជឿអាជីវកនោះ ហើយក៏មិនបានទៅទទួលយកកូនស្រីក្នុងថ្ងៃហ្នឹងឡើយ ។

ចំណែកត្រកូលខាងស្រី បានចាត់ការមង្គលរៀបចំទទួលភ្ញៀវខាងប្រុស លុះមិនឃើញពួកគេមកតាមសន្យា ក៏លើកធីតាឱ្យទៅត្រកូលដទៃសម្រេចស្រេចបាច់ក្នុងថ្ងៃនោះដែរទៅ ។

ថ្ងៃស្អែកឡើង ត្រកូលក្រៅក្រុងក៏បាននាំគ្នាមកដល់សូមយកកូនស្រីពួកអ្នកក្នុងក្រុងក៏ពោលតិះដៀលថា ពួកអ្នកឯងសមនឹងឈ្មោះ អ្នកក្រៅក្រុងមែនហើយ ជាមនុស្សខ្វះសម្បត្តិរបស់មនុស្សល្អ ជាមនុស្សអាក្រក់ សន្យាគ្នាហើយ មើលងាយពាក្យសន្យា មិនមកតាមកំណត់ អញ្ជើញទៅតាមផ្លូវដែលអ្នករាល់គ្នា

មកនោះវិញទៅ ពួកយើងលើកកូនស្រីយើងឱ្យអ្នកផ្សេង ៗទៅហើយ ។

ពួកអ្នកក្រៅក្រុង ខំប្រឹងឈ្លោះនឹងអ្នកក្រុងអស់មួយសន្ទុះធំ លុះដឹងប្រាកដថា មិនបានកូនក្រមុំពិតហើយ ក៏នាំគ្នាត្រឡប់ទៅវិញតាមផ្លូវដែលមកនោះឯង ។

រឿងទាំងអស់នេះបានជ្រាបដល់ព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ព្រះជាតក ពីអាជីវកនោះធ្លាប់បំផ្លាញមង្គលរបស់គេតាំងពីជាតិមុនមកហើយ ។

ក្នុងជាតិមុននោះ អ្នកក្រុងពារាណសី ទៅស្ដីដណ្ដឹងកូនស្រីអ្នកជនបទហើយមិនទៅតាមសន្យា ព្រោះថាជឿតាមពាក្យកុហករបស់អាជីវក ។ រឿងក៏ងមានទំនងដូចគ្នា ខុសត្រង់ថាអ្នកជនបទបានតិះដៀលអ្នកក្រុងពារាណសីថា ពួកអ្នករាល់គ្នាឈ្មោះថាជាអ្នកក្រុង ប៉ុន្តែខ្វះនូវសម្បត្តិរបស់មនុស្សល្អ ព្រោះមិនគោរពពាក្យសន្យា ។ ក្នុងកាលណោះ ព្រះបរមពោធិសត្វជាបណ្ឌិត បានពោលថា ផ្កាយទាំងឡាយនឹងមានប្រយោជន៍អ្វី ព្រោះការបានកូនស្រីក្រមុំជាឫក្សល្អស្រេចទៅហើយ មិនមែនទេ ? រួចហើយទើបព្រះបរមពោធិសត្វពោលនូវគាថា ៖

នៅក្នុងបិដកលេខ ៥៨ ទំព័រ ២២ **នក្ខត្តជាតក** បណ្ឌិតបុរសពោធិសត្វពោលថា ៖

នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា
អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកាតិ ។

ប្រែថា: ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ដែលរាប់អាននូវនក្ខត្តឫក្ស ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

បណ្តាបទទាំងនោះ បទថា **បដិមានេន្ត** ដោយសេចក្តីថា អ្នករង់ចាំមើលអធិប្បាយថា រវល់តែរង់ចាំមើល នក្ខត្តឫក្សនឹងមានក្នុងពេលនេះ នឹងមានក្នុងកាលឥឡូវនេះ ។

បទថា អត្ថោពាលំឧបច្ចគា ដោយសេចក្តីថា ប្រយោជន៍ពោលគឺការបាននូវកូនក្រមុំ កន្លងផុតនូវមនុស្សល្ងង់ដែលជាអ្នកក្រុងពារាណសីនោះ ។

បទថា អត្ថោ អត្ថស្ស នក្ខត្តំ ដោយសេចក្តីថា បុគ្គលស្វែងរកនូវប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថាជានក្ខត្តឫក្សរបស់ប្រយោជន៍ ។

បទថា កឹករិស្សន្តិតារកាដោយសេចក្តីថា តើដួងផ្កាយ

ទាំងឡាយក្នុងអាកាសក្រៅអំពីនេះ នឹងញុំាងប្រយោជន៍ដូចម្ដេចឱ្យសម្រេចបាន ។

ម្យ៉ាងទៀត នៅក្នុងបិដកលេខ ៤១, ទំព័រ ៤៧៥ ត្រង់ **មង្គលវគ្គ** ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាបុព្វណ្ហសម័យ( ពេលព្រឹក ) សត្វទាំងនោះ ឈ្មោះថា **មានបុព្វណ្ហសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាមជ្ឈន្តិកសម័យ( ពេលថ្ងៃ )សត្វទាំងនោះឈ្មោះថា **មានមជ្ឈន្តិកសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាសាយណ្ហសម័យ( ពេលល្ងាច )សត្វទាំងនោះឈ្មោះថា សាយណ្ហសម័យដ៏ល្អ ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថា ជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**

**បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា ។**

(ក្នុងថ្ងៃនោះ) កាយកម្មឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន មនោកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន សេចក្ដីប្រាថ្នារបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន ។

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ ។**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្មគួរដល់សេចក្ដីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

នៅក្នុង**មង្គល**សូត្រនេះ ព្រះអង្គបានសម្ដែងមានទាំងអស់ ១០ ព្រះគាថា ។ ក្នុងមួយគាថា មាន ៣ ក៏មាន ៤ ក៏មាន ៥ ក៏មាន ។ ញែកជាមាតិកា មានទាំងអស់ ៣៨ ប្រការ ដែលខាង

ដើម ព្រះអង្គទ្រង់ត្រាស់សម្ដែងថា **អាសេវនា ច ពាលានំ** មិនឱ្យសេពគប់បុគ្គលពាល រហូតដល់ខាងចុងថា **ខេមំ** ធ្វើចិត្តឱ្យឃ្លាតចាកអំពីកិលេស ដែលហៅថា **ចិត្តក្សេមក្សាន្ត** ។

**សរុបមក** បើបុគ្គលណាប្រាថ្នានូវសិរីសួស្ដី សុភមង្គល ភាពសុខដុមរមនាដល់ខ្លួនដល់ក្រុមគ្រួសារជាដើមនោះត្រូវព្យាយាមបដិបត្តិទៅតាមមង្គលទាំង ៣៨ ប្រការនេះចុះ, ឬថា ត្រូវប្រព្រឹត្តឱ្យល្អទៅតាមផ្លូវកាយ វាចា ចិត្ត ឱ្យបានជានិច្ចចុះ ទុំសិរីសួស្ដី សុភមង្គល សេចក្ដីសុខចម្រើន នឹងកើតមានដល់បុគ្គលនោះឯង ។

សៀវភៅ **មង្គលកថា** ដែលនិយាយអំពីមង្គលទាំង ៣៨ ប្រការនេះ ខ្ញុំព្រះករុណាសង្ឃឹមថា នឹងបានជួយតម្រែតម្រង់មាគ៌ាជីវិតនៃពុទ្ធបរិស័ទគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈទាំងអស់ ឱ្យដើរឈានទៅរកសេចក្ដីសុខ និងការរីកចម្រើននៃជីវិតទាំងនៅក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនាយ រហូតដល់អស់នូវអាសវៈកិលេស ។

ម្យ៉ាងទៀត សៀវភៅនេះ បើសិនជាមានខុសត្រង់អក្ខរៈព្យញ្ជនៈភាសាបាលី សេចក្ដីអធិប្បាយត្រង់ចំណុចណាមួយនោះ សូមមេត្តាខន្តី អភ័យទោសផង ។

ដោយអំណាចមហាកុសលចេតនា ដែលខ្ញុំមានចិត្តជ្រះថ្លាក្នុងព្រះសទ្ធម្មរបស់ព្រះអង្គ ខិតខំកសាងសន្សំព្យាយាមធ្វើសៀវភៅនេះសូមបានជាឧបនិស្ស័យដ៏ល្អបានពាល់ត្រូវនូវព្រះនិព្វានក្នុងពេលដ៏ខ្លីខាងមុខនេះផងចុះតែបើមិនទាន់បានសម្រេចទេ សូមកើតជាតិណា ៗក៏ដោយ សូមកុំឱ្យស្គាល់ពាក្យថាអត់ ពាក្យថាគ្មាន ពាក្យថាក្រ ពាក្យថាលំបាក និងសូមឱ្យមានតែសិរីសួស្តី មិនមានសេចក្តីប្រមាទក្នុងជីវិត និងសូមឱ្យខ្ញុំមានបញ្ញាមោះមុតឆាប់ចាក់ធ្លុះនូវអរិយសច្ចធម៌ បានដល់នូវអមតដ្ឋាន **ក្នុងសាសនានៃព្រះសិរិអារ្យមេត្រីយ៍** កុំបីអាក់ខានឡើយ,ម្យ៉ាងទៀតសូមឧទ្ទិសបុណ្យកុសលនេះ ជូនដល់បុព្វការីជនទាំងឡាយ ដែលបានបែកធ្លាយរាងកាយទៅ និងពួកសត្វទាំងឡាយផង សូមបាននូវសេចក្តីសុខ ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ មួយអន្លើយដោយព្រះករុណាគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទ ។

**សូមអនុមោទនា !!!**

**ថ្ងៃ៧កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧**

**ភិក្ខុ សីលប្បញ្ញោ ឆៃ សុផល្លី**

# បញ្ជីមាតិកា

| មាតិកា | មង្គលកថា | ទំព័រ |
| --- | --- | --- |


អារម្ភកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ក

**មង្គលទី ៣ បូជាបុគ្គលដែលគួរបូជា** ... ... ... ... ១

ការបូជាគឺជាអ្វី ... ... ... ... ... ... ... ... ... ... ... ... ... ... ១

ការបូជា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៣

បុគ្គលដែលគួរបូជា ... ... ... ... ... ... ... ... ... ... ... ... ៤

ការសម្តែងចេញដល់ការបូជា ... ... ... ... ... ... ... ... ១០

ប្រភេទរបស់ការបូជា ... ... ... ... ... ... ... ... ... ... ... ១១

ចំណុចគួរចងចាំ ... ... ... ... ... ... ... ... ... ... ... ... ... ១២

ការថ្វាយបង្គំ៣ យ៉ាង ... ... ... ... ... ... ... ... ... ... ... ១៣

សរុបបុគ្គលដែលគួរបូជានិងមិនគួរបូជា ... ... ... ... ១៥

បិង្គិយានិសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ១៧

ឆព្វាលាតសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ២២

ឧគ្ឃជិតញ្ញូសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ២៤

បដិភាណសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ២៦

សុន្ទរិកសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ២៧

វត្ថុដែលគួរបូជា ... ... ... ... ... ... ... ... ... ... ... ... ... ៥២

មហាបរិនិព្វានសូត្រ ... ... ... ... ... ... ... ... ... ... ... ៥៤

ការដល់សរណគមន៍ ... ... ... ... ... ... ... ... ... ... ... ៥៦

**មាតិកា** **ទំព័រ**

គោលបំណងនៃការបូជា ... ... ... ... ... ... ... ... ... ៦៧
វណ្ណសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៦៩
ឧជ្ជយសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ៧២
រឿងព្រាហ្មណ៍អ្នកជាអឺរបស់ព្រះសារីបុត្តត្ថេរ ... ... ៧៥
រឿងព្រាហ្មណ៍អ្នកជាក្មួយរបស់ព្រះសារីបុត្រ ... ... ៧៩
រឿងព្រាហ្មណ៍អ្នកជាសម្លាញ់ព្រះសារីបុត្តត្ថេរ ... ៨១
រូបសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៨៥
រឿងទាក់ទងនឹងបដិបត្តិបូជា ... ... ... ... ... ... ... ... ... ៨៧
រឿងព្រះអត្តទត្ថត្ថេរ ... ... ... ... ... ... ... ... ... ... ... ៨៨
រឿងព្រះតិស្សត្ថេរ ... ... ... ... ... ... ... ... ... ... ... ... ៩២
រឿងព្រះធម្មារាមត្ថេរ ... ... ... ... ... ... ... ... ... ... ... ៩៤
អានិសង្សបូជាបុគ្គលដែលគួរបូជា ... ... ... ... ... ៩៩
មោរជាតក ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១០១
រឿងនាយសុមនមាលាការ ... ... ... ... ... ... ... ... ១០២
រឿងអាយុវឌ្ឍនកុមារ ... ... ... ... ... ... ... ... ... ១១៥
សង្ខេបខ្លី ៗ ... ... ... ... ... ... ... ... ... ... ... ... ... ១១៧
សរុបសេចក្តីនៃមង្គលកថា គាថាទី ១ ក្នុងអដ្ឋកថា ១២១
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ ... ១៤១

# ធម្មគតិ

✍. មាតាបិតា ជាបូជនីយបុគ្គលរបស់បុត្តធីតា

✍. គ្រូ អាចារ្យ ឧបជ្ឈាយ៍ ជាបូជនីយបុគ្គលរបស់អន្តេវាសិក( សិស្សទាំងឡាយ )

✍. រាមច្បងជាបូជនីយបុគ្គលរបស់ប្អូន ៗទាំងឡាយ

✍. ស្វាមីជាបូជនីយបុគ្គលរបស់ភរិយា

✍. ព្រះរាជា ជាបូជនីយបុគ្គលរបស់ប្រជានុរាស្ត្រ

✍. ព្រះសង្ឃជាបូជនីយបុគ្គលរបស់ពុទ្ធបរិស័ទ

✍. ព្រះសម្មាសម្ពុទ្ធជាជាបូជនីយបុគ្គលរបស់ មនុស្ស និងទេវតា មារ ព្រហ្មទាំងឡាយ ។

# មង្គលទី ៣ បូជាបុគ្គលដែលគួរបូជា

ដើមឈើកាលនៅតូច វារស់នៅចាំបាច់ត្រូវមានបង្គោលសំរាប់ទល់ការពារ កុំឱ្យរំលំដួលដាច់ឫសស្លាប់ យ៉ាងណា អ្នកដែលសង្ឃឹមសេចក្តីចម្រើនទៅមុខ ក៏ចាំបាច់ត្រូវបូជាបុគ្គលដែលគួរបូជា ក្នុងការរៀបចំដំណើរជីវិតឱ្យបានត្រឹមត្រូវ ក្នុងការការពារសេចក្តីយល់ឃើញខុស និងអកុសលផ្សេង ៗមិនឱ្យកើតឡើងមកទៀត ក៏យ៉ាងនោះដែរ ។

## ការបូជាគឺជាអ្វី?

**ការបូជា** គឺជាការជ្រះថ្លា លើកសរសើរដោយកិរិយាអាការៈ សុភាពរាបសា ដែលយើងសម្តែងចេញចំពោះអ្នកដែលយើងគោរពបូជា **ទាំងចំពោះមុខនឹងកំបាំងមុខ** ការសម្តែងចេញចំពោះមុខ ជាការសម្តែងឱ្យដឹងថា យើងមានសេចក្តីគោរពនឹងដឹងច្បាស់នៅក្នុងគុណធម៌សេចក្តីល្អ ដែលមាននៅក្នុងខ្លួនលោកយ៉ាងពិតប្រាកដ ការសម្តែងចេញកំបាំងមុខជាការជាស់

តឿនចិត្តខ្លួនឯង អោយចងចិត្តទុកនិងគុណធម៌ដែលខ្ពង់ខ្ពស់ របស់លោក បណ្ដុំឱ្យកើតការរលឹកដឹងនឹងប្រាថ្នា នឹងធ្វើតាមចិត្ត របស់យើងនឹងបានខ្ពស់ឡើងជារឿយ ៗ មិនឱ្យធ្លាក់ទៅកាន់ផ្លូវ អាក្រក់ឡើយ ។

**ការបូជា** ជាកុសលឧបាយមួយ ***សំរាប់ហ្វឹកហាត់ចិត្តដែល នៅរឹងរូស ព្រោះមិនព្រមទទួលយកគុណសេចក្ដីល្អរបស់អ្នកដទៃ អោយល្អិតល្អន់*** អ្នកដែលនៅខ្សោយបញ្ញានៅមិនចូលចិត្តក្នុង គុណធម៌ សេចក្ដីល្អរបស់អ្នកដទៃដោយល្អិតល្អន់ អ្នកដែលនៅ ខ្សោយ បញ្ញានៅមិនចូលចិត្តក្នុងគុណធម៌ សេចក្ដីល្អរបស់អ្នក ដែលគួរ បូជាតែចំពោះអ្នកដែលធ្លាប់បូជាហើយនោះ នៅក្នុងទី បំផុត រមែងអាចឃើញដល់គុណធម៌ សេចក្ដីល្អដែលមាននៅក្នុង ខ្លួនរបស់អ្នក ដែលយើងបូជាបាន យ៉ាងពិតប្រាកដហើយប្រាថ្នា ធ្វើសេចក្ដីល្អ តាមលោកអ្នកធំ គួរប្រៀនប្រដៅកូនចៅឱ្យដឹងអំពី ការសូត្រមនស្ការបូជាព្រះរតនៈត្រ័យ ជាការបណ្ដុះសទ្ធាតាំងពី ក្មេង ៗទៅ ។

## ការបូជា

ការបូជានៅក្នុងព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថាមាន ២ យ៉ាងគឺ ៖

**១-អាមិសបូជា**

**២-បដិបត្តិបូជា។**

បណ្ដាការបូជា ២ យ៉ាងនោះ ការបូជាដោយគ្រឿងសក្ការទាំងឡាយ មានផ្កាឈើជាដើមនិងដោយបច្ច័យ ៤ ឈ្មោះថា **ការបូជាដោយអាមិស ។**

ការបូជា ដោយសេចក្ដីប្រតិបត្តិ( តាមពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះអង្គ ) ឈ្មោះថា **បដិបត្តិបូជា ។**

ចំណែកក្នុងអដ្ឋកថា លោកពោលថា "**ការធ្វើសក្ការគោរពរាប់អាន និងកិរិយាក្រាបថ្វាយបង្គំ** ឈ្មោះថា **ការបូជា ។** ដោយកំណត់យកបុគ្គលដែលប្រសើរខ្ពង់ខ្ពស់បំផុត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងអរិយសាវកទាំងឡាយ ឈ្មោះថាមានព្រះពុទ្ធជាដើមនោះ លោកហៅថា "ជាបូជនេយ្យបុគ្គល" ព្រោះធ្វើនូវភាវៈនៃការបូជាដែលបុគ្គលបានធ្វើហើយក្នុងខ្លួន សូម្បីមានចំនួនដ៏តិចតួចក៏ដោយ

នាំប្រយោជន៍និងសេចក្តីសុខ មកប្រគល់ឱ្យបានអស់កាលដ៏យូរអង្វែង ព្រោះហេតុជាទក្ខិណេយ្យបុគ្គល ។

## បុគ្គលដែលគួរបូជា

**បុគ្គលដែលគួរបូជា** បានដល់ អ្នកមានសីល សមាធិ បញ្ញាខ្ពស់ជាងយើងនោះឯង បើប្រមូលសរុបមកបានដល់ ៖

**១-ព្រះពុទ្ធ** ជាបណ្ឌិតដែលប្រសើរបំផុតនៅក្នុងលោក ព្រះអង្គមានគុណច្រើនណាស់មកលើសព្វសត្វ មិនអាចនឹងគណនាបានឡើយ តែបើយើងសរុបឱ្យខ្លីមកទ្រង់បរិបូណ៌ ដោយបញ្ញាធិគុណ ព្រះវិសុទ្ធិគុណនិងព្រះករុណាធិគុណ ចាត់ជាបុគ្គលដែលគួរបូជារបស់ពុទ្ធសាសនិកជនទាំងឡាយ ។

**២- ព្រះសង្ឃ** ជាអ្នកប្រព្រឹត្តបដិបត្តិដ៏ប្រពៃមុនហើយ ទើបមានការប្រៀនប្រដៅឱ្យអ្នកដទៃឱ្យប្រព្រឹត្តល្អ បដិបត្តិតាម នេះចាត់ជាបុគ្គលដែលគួរបូជា របស់ពុទ្ធសាសនិកជន ។

**៣-ព្រះមហាក្សត្រដែលជាធម្មិករាជជាអ្នកតាំង នៅក្នុងទសពិធរាជធម៌ ១០ ប្រការគឺ ៖**

**ទានៈ** ការធ្វើអំណោយដល់ប្រជាពលរដ្ឋក្រីក្រអត់ឃ្លាន និង ខ្វះខាតជាងគេដោយសេចក្ដីអាណិតអាសូរ ព្រោះព្រះមហាក្សត្រ ជាភ្នែកជាប្រមុខរបស់ប្រជារាស្ត្រ គប្បីដឹងសុខ ដឹងទុក្ខប្រជារាស្ត្រ ដោយតាំងព្រះទ័យថា សេចក្ដីទុក្ខរបស់ប្រជារាស្ត្រស្មើនឹងសេចក្ដី ទុក្ខរបស់ព្រះអង្គ ។ បើប្រជារាស្ត្រអត់ឃ្លាន ក៏រកមធ្យោបាយដោះ ស្រាយបំបាត់ការអត់ឃ្លាននោះ ។

**សីលៈ** រក្សាសីល ៥ ជានិច្ច មិនសម្លាប់ មិនលួច មិន រំលោភយកប្រពន្ធអ្នកដទៃ មិននិយាយកុហក មិនសេពសុរាគ្រឿង ស្រវឹង ។ សីល ៥ នោះជាមូលដ្ឋាននៃសីលធម៌ បានជាតម្រូវឱ្យ ប្រជាពលរដ្ឋ និងព្រះមហាក្សត្រត្រូវតែមានដូចគ្នា ។ បើអ្នកដឹក នាំមិនមានសីល៥នេះទេអាចបៀតបៀន ឬ សម្លាប់បុគ្គលណា ដែលប្រឆាំងអាចលួចប្រាក់ជាតិ ជាដើម ។

**បរិច្ចាគៈ** ការចំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេស និង ឧបត្ថម្ភសាសនាគឺសម្រាប់បណ្ដុះបណ្ដាលសីលធម៌ឱ្យមានវឌ្ឍន ភាពទន្ទឹមគ្នា នឹងការលូតលាស់ខាងសេដ្ឋកិច្ចជាតិ ។ នៅសម័យ ពុទ្ធកាល ក្រៅពីការស្ថាបនាជាតិនិងការពារជាតិ ព្រះបាទបសេន-

ទិកោសល ព្រះបាទពិម្ពិសារបានថ្វាយខ្លួនចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាញោមឧបដ្ឋាកទំនុកបំរុងព្រះពុទ្ធសាសនាយ៉ាងមុតមាំបំផុត បានជាគំរូដ៏ល្អដល់ប្រជារាស្ត្រទូទៅ ។

**អាជ្ជវៈ** ប្រែថា មានសេចក្តីត្រង់ គឺ មានសេចក្តីទៀងត្រង់ ឬស្មោះត្រង់ចំពោះប្រជារាស្ត្រ ។ គ្រប់កិច្ចការដែលអនុវត្តនធ្វើ ឬមានបញ្ជាឱ្យអនុវត្តធ្វើ គឺ ស្របទៅតាមផលប្រយោជន៍របស់ប្រជារាស្ត្រ និងសេចក្តីត្រូវការរបស់ប្រជារាស្ត្រ មិនប្រើល្បិចកិច្ចកលអ្វីមួយទៅលើរាស្ត្រដោយព្រះទ័យអកុសលឡើយ ។

**មទ្ទវៈ** ប្រែថា ការទន់ភ្លន់សុភាពរាបសាទៅកាន់ប្រជារាស្ត្រ គឺមានសេចក្តីរាប់អានប្រជារាស្ត្រទូទៅ ដូចជាបុត្របង្កើត ។ បានសេចក្តីថា មិនប្រកាន់តែងតែមានការស្និទ្ធស្នាល ជានិច្ចទៅលើមនុស្សទូទៅ តែងមានការសន្ទនាដកស្រង់យកយោបល់ប្រជារាស្ត្រ ដើម្បីរៀបចំផែនការស្រុកទេសឱ្យមានយុត្តិធម៌ ។ សកម្មភាពបែបនេះ ទើបឈ្មោះថា ព្រះអង្គដាក់ខ្លួនបំរើប្រជារាស្រតដោយស្មោះត្រង់ ។

**តបៈ** ការកាន់ឧបោសថសីលតាមកាលកំណត់ដើម្បីបន្ថយនូវកាមារម្មណ៍ គឺបន្ថយនូវការសប្បាយក្នុងរូបសម្លេង ក្លិន រសនិងសម្ផស្ស ធ្វើព្រះទ័យឱ្យស្ងប់ចាកកាមក្នុងថ្ងៃឧបោសថនោះ ព្រោះថា បើអ្នកដឹកនាំរដ្ឋជាន់ខ្ពស់ សប្បាយក្នុងកាមខ្លាំងពេក នាំឱ្យរវល់ច្រើនក្នុងកាម ខាតពេលវេលាទៅបំពេញកិច្ចការរដ្ឋ ។

**អក្កោធនៈ** មិនក្រេវក្រោធ មិនធ្វើឱ្យប្រជារាស្ត្រ ឬមនុស្សទូទៅក្តៅក្រហាយ គឺរម្ងាប់ក្តីកំហឹង មិនក្រោធតបនូវមនុស្សដែលក្រេវក្រោធ ។

**អវិហឹសា** មិនបៀតបៀនប្រជារាស្ត្រ និងមនុស្សទូទៅ គឺមិនធ្វើឱ្យប្រជារាស្ត្រមានទុក្ខដោយផ្លូវកាយនិងផ្លូវចិត្ត តែមានព្រះទ័យករុណាអាណិតអាសូរជួយដោះស្រាយគ្រប់បញ្ហាទុក្ខលំបាកគ្រប់យ៉ាងនិងចំពោះពាក្យរិះគន់គ្រប់បែប ដោយមិនតបតដោយអំពើហឹង្សាឡើយ ។

**អវិរោធនៈ** មិនបំពានច្បាប់ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍ព្រះញាតិមិនរំលោភច្បាប់ព្រះពុទ្ធសាសនានិងច្បាប់រដ្ឋ ។

ទសពិធរាជធម៌ទាំង ១០ ប្រការនេះ ពុំមែនប្រតិបត្តិ តែព្រះមហាក្សត្រទេ អ្នកដឹកនាំរដ្ឋជាន់ខ្ពស់ដទៃទៀត ក៏ត្រូវអនុវត្តន៍ ដូចគ្នា ព្រោះរាជៈនេះពុំមែនសំដៅតែព្រះមហាក្សត្រ សោយរាជ្យទេ គឺសំដៅយកជនណាដែលធ្វើឱ្យប្រជារាស្ត្រត្រេកអរបានគឺត្រេកអរដោយសារមានការធ្វើឱ្យជាតិអភិវឌ្ឍន៍ គ្រប់វិស័យ មានវិស័យសង្គមកិច្ច និងវប្បធម៌ជាដើម ។ តាមន័យនេះជនណាក៏អាចធ្វើជាព្រះមហាក្សត្របានដែរឱ្យតែប្រតិបត្តិឱ្យបានត្រឹមត្រូវតាមទស-ពិធរាជធម៌ទាំង ១០ ប្រការនេះ ។ បើប្រតិបត្តិតាមមិនបានទេ មិនអាចធ្វើជាព្រះមហាក្សត្រ ឬអ្នកដឹកនាំរដ្ឋជាន់ខ្ពស់បានឡើយ ។ ព្រះពុទ្ធសាសនាសំដែងថា ទំនាបនិងកំពស់របស់មនុស្សត្រូវស្ថិតនៅលើអំពើអាក្រក់ និងអំពើល្អដែលគេបានប្រព្រឹត្តធ្វើ ពុំមែនស្ថិតនៅ លើជាតិត្រកូល ទ្រព្យសម្បត្តិយសសក្តិឡើយ ។ នេះចាត់ជាបុគ្គលដែលគួរបូជា របស់ពុទ្ធសាសនិកជន ។

៤- **មាតាបិតានិងរាមច្បង** ដែលប្រព្រឹត្តធម៌ តាំងនៅក្នុងឋានៈជាព្រះព្រហ្មរបស់កូនចៅ ចាត់ជាបូជនីយបុគ្គលដែលគួរគោរពបូជាយ៉ាងក្រៃលែង ។

៥- គ្រូអាចារ្យដែលមានការប្រព្រឹត្តល្អ ជាបណ្ឌិតដែលតាំងនៅក្នុងឋានៈខ្ពង់ខ្ពស់ជាងសិស្ស ចាត់ជាបុគ្គលដែលគួរដល់ការបូជារបស់សិស្ស ។

៦- ចៅហ្វាយនាយឬអ្នកដែលគ្រប់គ្រងប្រព្រឹត្តល្អ ចាត់ជាបុគ្គលដែលគួរដល់ការបូជា របស់អ្នកដែលនៅក្រោមការបង្គាប់បញ្ជា ។

ក្រៅអំពីនេះបណ្ឌិតដែលមានភេទភាវៈខ្ពង់ខ្ពស់ ដែលតាំងនៅក្នុងឋានៈស្មើគ្នា សុទ្ធតែចាត់ជាបុគ្គលដែលគួរដល់ការបូជាទាំងអស់ ។

៦. វត្ថុដែលជាប់ទាក់ទង ដោយលោកទាំងនេះ ក៏ចាត់ជាវត្ថុដែលគួរបូជាដូចគ្នា ព្រោះកាលយើងបូជាវត្ថុពួកនេះ ក៏អាចធ្វើឱ្យយើងរលឹកនឹកដល់គុណ សេចក្ដីល្អរបស់បុគ្គលទាំងនេះមានដូចជា ៖

១- វត្ថុដែលទាក់ទងដោយព្រះពុទ្ធ ដូចជាព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ព្រះពុទ្ធរូប ព្រះបរមសារីរិកធាតុ សង្វេគ-ជនីយឋាន ។

**២- វត្ថុដែលទាក់ទងដោយព្រះសង្ឃ** ដូចជា ព្រះធាតុរូប ព្រះសង្ឃសាវ័កជាដើម ។

**៣- ពាក្យប្រៀនប្រដៅ រូបភាពរបស់មាតាបិតា គ្រូអាចារ្យ ចៅហ្វាយនាយ ព្រះមហាក្សត្រ ដែលប្រព្រឹត្តធម៌ ជាបណ្ឌិតចាត់** ជាវត្ថុដែលគួរបូជាទាំងអស់ ។

## ការសម្ដែងចេញនូវការបូជា

**១- ផ្លូវកាយ** មិនថាពេលឈរ ដើរ អង្គុយ ដេក ឬការប្រកប កិច្ចការណា ៗទេ ពេលនៅចំពោះមុខលោក ឬរូបតំណាងរបស់ លោក ដូចជា រូបបដិមា រូបភាព ក៏ត្រូវតែសង្រួមដែរ ។

**២-ផ្លូវវាចា** លើកសរសើរគុណសេចក្ដីល្អរបស់លោកទាំង ចំពោះមុខទាំងកំបាំងមុខ ដូចជាការសូត្រនមស្ការបូជា ព្រះរតនៈ ត្រ័យ ការនាំសេចក្ដីល្អរបស់លោកទៅលើកសរសើរជាដើម ។

**៣-ផ្លូវចិត្ត** តាមរលឹកនឹកដល់ពាក្យប្រៀនប្រដៅរបស់លោក ដោយសេចក្ដីគោរព នឹងជ្រាលជ្រៅជាទីបំផុត ។

## ប្រភេទរបស់ការបូជា

ការបូជាក្នុងផ្លូវបដិបត្តិមាន ២ ប្រភេទគឺ ៖

**១- អាមិសបូជា** គឺការបូជាដោយវត្ថុរបស់ ដូចជាកូនមានការទីករលឹកដល់គុណមាតាបិតា សិស្សរលឹកដល់គុណគ្រូអាចារ្យទើបបូជាដោយការនាំយកទ្រព្យសម្បត្តិរបស់របរ ប្រើប្រាស់ជាដើមទៅជូន ការបូជាព្រះរតនៈត្រ័យដោយផ្កាឈើ ធូបទៀន ក៏ចាត់ជាអាមិសបូជាដូចគ្នា ។

**២-បដិបត្តិបូជា** គឺការបូជាដោយការតាំងចិត្តប្រព្រឹត្តបដិបត្តិតាមពាក្យប្រៀនប្រដៅដែលល្អរបស់លោក ដូចជា ព្យាយាមកម្ចាត់សេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេង ដោយការឱ្យទានរក្សាសីល ចម្រើនភាវនា តាមពាក្យទូន្មានប្រៀនប្រដៅរបស់លោក **ការបដិបត្តិបូជានេះចាត់ជាការបូជាខ្ពង់ខ្ពស់បំផុត ព្រោះជាឧបាយដែលធ្វើឱ្យកាយ វាចា ចិត្ត របស់យើងថ្លាស្អាត អាចក្លាយទៅជាបណ្ឌិត តាមលោកបានដោយរហ័ស ។**

៦. សម្រាប់អ្នកសិក្សារៀនសូត្រ ឬអ្នកបដិបត្តិធម៌ គប្បីរលឹកឱ្យឃើញថា វត្ថុដែលយើងចេះដឹងនោះ បើយើងលើកស្ទួយ

បូជា ត្រូវតាំងចិត្តឱ្យល្អ មិននាំទៅធ្វើត្រាប់តាម ឬនិយាយលេង នោះ ផលនៃការសិក្សារៀនសូត្របហូតដល់ មានការបដិបត្តិធម៌ របស់យើង រមែងរីកចម្រើនទៅមុខ អាចសម្រេចផលបានយ៉ាង រហ័ស ។

ផ្ទុយទៅវិញ បើយើងមិនគោរព ត្រឡប់ទៅជាមើលងាយ គ្រូអាចារ្យវិញនោះវត្ថុដែលរៀនចេះដឹងនោះ ក៏ត្រឡប់ទៅវិនាស ទៅវិញភ្លាម ហើយកើតការមិនចេះដឹងភ្លាម ចិត្តដែលគួរត្រិះរិះនឹក ដល់ធម៌ ឬចំណេះដឹងផ្សេង ៗ ក៏ងងឹតជាការបិតយាំងផ្លូវរបស់ បញ្ញាដែលបញ្ញានេះ ជាពន្លឺភ្លឺស្វាងអាចនាំវិថី ជីវិតឱ្យឈានទៅ រកផ្លូវដែលត្រូវ ។

## ចំណុចគួរចងចាំ

កុំបូជាវត្ថុដែលមិនគួរបូជា ព្រោះវាអាចដឹកនាំឱ្យទៅកាន់ សេចក្តីល្ងង់ វង្វេងយល់ខុស ចិត្តស្រអប់ដូចពាលទៅដែលអាច ធ្វើ ដូច្នេះ ៖

**១- មិនត្រូវបូជាបុគ្គលពាល** គឺមិនលើកសរសើរ មិនគាំទ្រ

បុគ្គលពាល មិនថាបុគ្គលពាលនោះ មានយសសក្តិ ស្ថានភាពខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ។

**២- មិនបូជាវត្ថុដែលជាប់ទាក់ទងដោយបុគ្គលពាល** ដូចជារូបភាព រូបបដិមាករ គ្រឿងប្រើប្រាស់របស់បុគ្គលពាលឬធ្វើតាមពាក្យរបស់បុគ្គលពាល ដែលមានការណែនាំ ។

**៣- មិនបូជាវត្ថុដែលបូជាហើយ មិនឱ្យកើតសិរីមង្គល** ដូចជា រូបភាពផ្កាយ អ្នកលេងកីឡាដែលមានគុណធម៌ ភាពឃោសនាដែលជាប់ទាក់ទងនិងអបាយមុខជាដើម ។

**៤- មិនបូជាវត្ថុដែលបូជាហើយធ្វើឱ្យវង្វេងមិនកើតបញ្ញា** ដូចជា ដើមឈើធំ ៗភ្នំខ្ពស់ អ្នកតាភូមិ មនុស្សប្រចូល រូប ភូតបិសាច ឬសត្វដែលកើតមកមានលក្ខណៈខុសប្រក្រតីជាដើម ។

## ការក្រាបថ្វាយបង្គំ ៣ យ៉ាង

វិធីនៃការបូជាព្រះពុទ្ធរូប ដែលភាគច្រើនគឺ **ការក្រាបថ្វាយបង្គំ** ដែលមានច្រើនប្រភេទ ដូចនេះ ៖

**១-ការក្រាបថ្វាយបង្គំហត់ឬអស់កម្លាំង** គឺនៅពេលឃើញបុគ្គលដទៃក្រាបថ្វាយបង្គំព្រះក៏ក្រាបថ្វាយបង្គំតាមគេ យ៉ាងនេះ

គ្មានប្រយោជន៍ទាល់តែសោះ ហត់នឿយទទេ ៗ ។

**២- ការក្រាបថ្វាយបង្គំល្វង់** គឺនៅពេលដែលក្រាបថ្វាយបង្គំហើយ សូមនូវវត្ថុមិនសមគួរ ដូចជាការបូជា ការថ្វាយបង្គំព្រះសូមឆ្នោត ឬមិនព្យាយាមមើលសៀវភៅ ទន្ទេញ មេរៀនបែរ ទៅថ្វាយបង្គំព្រះ សូមឱ្យខ្លួនប្រឡងជាប់ជាដើម ។

**៣- ការក្រាបថ្វាយបង្គំឆ្លាត** គឺនៅពេលដែលក្រាបថ្វាយបង្គំព្រះរូបក៏ប្រកាន់យកព្រះធម៌ ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះអង្គមកជាបែបផែន ក្នុងការប្រព្រឹត្តបដិបត្តិតាម ដូចជា ៖

- **ការក្រាបថ្វាយបង្គំលើកទី ១ រលឹកដល់ព្រះបញ្ញាធិគុណរបស់ព្រះអង្គ**ដែលទ្រង់មានបញ្ញាច្រើន អាចពិចារណាឃើញទុក្ខនឹងគិតរកវិធីរំលត់ទុក្ខដោយព្រះអង្គឯងទាំងនេះ ព្រោះព្រះអង្គសិក្សាធម៌ និងហ្វឹកហាត់សមាធិមកច្រើន ទើបមានចិត្តថ្លៃថ្លារហូតអាចត្រាស់ដឹងធម៌ ប្រាសចាកកិលេសក្នុងខ្លួន បានអស់ចំណែកយើងក៏ត្រូវតាំងចិត្ត ឧស្សាហ៍ព្យាយាមហ្វឹកហាត់សមាធិសិក្សាធម៌តាមព្រះអង្គដែរ ។
- **ការក្រាបថ្វាយបង្គំលើកទី ២ រលឹកដល់ព្រះវិសុទ្ធិគុណ**

**របស់ព្រះអង្គ** ដែលទ្រង់មានសេចក្តីបរិសុទ្ធិ ទាំងកាយវាចាចិត្ត ព្រោះព្រះអង្គរក្សាសីលមកច្រើន មិនធ្លាប់ឱ្យសេចក្តីអាក្រក់ដល់អ្នកណាមួយឡើយ ជាតួយ៉ាងក្នុងការរក្សាសីល បានយ៉ាងល្អ ចំណែកយើងក៏ត្រូវតាំងចិត្តរក្សាសីលឱ្យបាន បរិសុទ្ធ ដូចព្រះអង្គដែរ ។

- **ការក្រាបថ្វាយបង្គំលើកទី ៣** រលឹកដល់ព្រះករុណាធិគុណរបស់ព្រះអង្គ ដែលទ្រង់ទេសនា ទូន្មានប្រៀនប្រដៅពួកមនុស្សទាំងឡាយ ដោយមិនខ្លាចលំបាកព្រះកាយឡើយ ព្រោះព្រះអង្គទ្រង់បំពេញទាន ជួយដល់សត្វលោកមក រាប់ភព រាប់ជាតិមិនអស់ ទើបព្រះអង្គមានសេចក្តីមេត្តា ករុណាជានិច្ច ចំណែកយើងក៏ត្រូវតាំងចិត្តឧស្សាហ៍ព្យាយាម ឱ្យទានមានសេចក្តីករុណាជួយអ្នកដទៃតាមព្រះអង្គដែរ ។

## សរុបបុគ្គលដែលគួរបូជានិងមិនគួរបូជា

ពិតមែន មនុស្សនៅលើពិភពលោកយើងនេះ មិនមែន សុទ្ធតែជាបុគ្គលដែលយើងត្រូវធ្វើសក្ការៈគោរពបូជានោះទេព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់ជាសាស្តាចារ្យនៃទេវតា និងមនុស្ស

ទ្រង់មានព្រះទ័យដឹងច្បាស់ទ្រង់ត្រាស់ថា បុគ្គលដែលយើងត្រូវគោរពបូជានោះគឺជាបុគ្គលដែលមានគុណធម៌ខ្ពង់ខ្ពស់ ប្រសើរឧត្តមដោយសីល សមាធិ បញ្ញា មានព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវក សាវិកានៃព្រះអង្គ ព្រះរាជាដែលជាអ្នកតាំងនៅក្នុងធម៌ មាតាបិតា រាមច្បងក្នុងត្រកូលជាដើម ។ កាលបើយើងមានការបូជានូវទាំងអស់នេះហើយ ឈ្មោះថា ជាការបូជាប្រពៃឧត្តមក្រៃប្រសើរ ព្រោះជាហេតុនាំឱ្យកើតមង្គលពោលគឺនាំមកនូវសេចក្ដីសុខទាំងក្នុងលោកនេះ និងលោកខាងមុខរហូតដល់បរមសុខ គឺព្រះនិព្វានទៀតផង ។ តែបើយើងមានការបូជាខុសបូជាបុគ្គលដែលមិនមានគុណសេចក្ដីល្អ ជាអ្នកមិនមានសេចក្ដីខ្មាសបាប ខ្លាចបាប សរសើរ លើកតម្កើង ឱ្យការរាប់អាន គោរពបូជាជាបុគ្គលមិច្ឆាទិដ្ឋិជាដើមនោះ ព្រះអង្គទ្រង់ត្រាស់សម្ដែងថា **បុគ្គលនោះកាលបែកធ្លាយរាងស្លាប់ទៅ រមែងធ្លាក់នរកដូចជា គេនាំយកទៅដាក់អីចឹង** មិនជាមង្គលទេ មានតែសេចក្ដីទុក្ខតែប៉ុណ្ណោះ ព្រោះហេតុនោះ កុលបុត្រទាំងឡាយ ដែលជាអ្នកប្រាថ្នានូវសិរីសួស្ដីសុភមង្គលនៃជីវិតនោះត្រូវបូជានូវបុគ្គលដែលគួរបូជា ដូចដែលបានរាប់មកនៅក្នុងមង្គលទី ៣ នេះឯងហើយ ។

# បិង្គិយានិសូត្រ

នៅក្នុងបិដលលេខ ៤៥, ទំព័រ ២២២ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**រតនៈដែលរកបានដោយកម្រ ៥ ប្រការ**] មានសេចក្ដីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងកូដាគារសាលាជិតព្រៃមហាវ័នក្បែរក្រុងវេសាលី ។ ក្នុងសម័យនោះ ឯងពួកស្ដេចលិច្ឆវីប្រមាណ ៥០០ អង្គ នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ ពួកស្ដេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ខៀវ មានសម្បុរខៀវ មានសំពត់ខៀវ មានគ្រឿងតាក់តែងខៀវ ពួកស្ដេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់លឿង មានសម្បុរលឿង មានសំពត់លឿង មានគ្រឿងតាក់តែងលឿង ពួកស្ដេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ក្រហម មានសម្បុរក្រហម មានសំពត់ក្រហម មានគ្រឿងតាក់តែងក្រហម ពួកស្ដេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ស មានសម្បុរស មានសំពត់ស មានគ្រឿងតាក់តែងស ព្រះដ៏មានព្រះភាគ រមែងរុងរឿងកន្លងស្ដេចលិច្ឆវីនោះដោយសម្បុរផង ដោយយសផង ។ គ្រានោះបិង្គិយានិ ព្រាហ្មណ៍ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈ

ផៀងស្មាម្ខាង ប្រណាមអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គសម្តែងបន្តិច បពិត្រព្រះសុគត ខ្ញុំព្រះអង្គសម្តែងបន្តិច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលបិង្គិយានិ អ្នកចូរសម្តែងចុះ ។ គ្រានោះឯង បិង្គិយានិព្រាហ្មណ៍ ក៏ពោលសរសើរ ដោយសារូបគាថា ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា ៖

បទុមំ យថា កោកនុទំ សុគន្ធំ
បាតោ សិយា ផុល្លមវីតគន្ធំ
អង្គីរសំ បស្ស វិរោចមានំ
តបន្តមាទិច្ចមិវន្តលិក្ខេតិ ។

ផ្កាឈូកឈ្មោះកោកនុទៈ មានក្លិនក្រអូបរីកអំពីព្រឹកមានក្លិនមិនបានទៅប្រាស យ៉ាងណាមិញ អ្នកចូរមើលព្រះដ៏ព្រះមានព្រះភាគ មានរស្មីផ្សាយចេញពីព្រះអង្គ ដ៏រុងរឿងដូចព្រះអាទិត្យដែលរុងរឿងក្នុងកណ្តាលពពក ក៏យ៉ាងនោះឯង ។

គ្រានោះឯងពួកស្តេចលិច្ឆវីទាំងនោះ បានញុំាងបិង្គិយានិព្រាហ្មណ៍ឱ្យស្លៀកដណ្តប់ ដោយសំពត់ឧត្តរាសង្គៈ ៥០០ ។

លំដាប់នោះឯង បិង្គិយានិព្រាហ្មណ៍ បានព្រាហ្មណ៍ បានញុំាងព្រះដ៏មានព្រះភាគដោយសំពត់ឧត្តរាសង្គៈ ៥០០ នោះ ។ វេលានោះព្រះដ៏មានព្រះភាគ បានត្រាស់ទៅនឹងពួកស្តេចលិច្ឆវី ទាំងនោះដូច្នេះថា ការកើតប្រាកដនៃរតនៈ ៥ យ៉ាង រកបានដោយកម្រក្នុងលោក ។ **ការកើតប្រាកដនៃរតនៈទាំង៥យ៉ាងតើដូចម្តេចខ្លះ ។**

១-តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវោ ទុល្លភោ លោកស្មឹ គឺការកើតប្រាកដនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ រកបានដោយកម្រក្នុងលោក ។

២-តថាគតប្បវេទិតស្ស ធម្មវិនយស្សទេសិតាបុគ្គលោ ទុល្លភោ លោកស្មឹ បុគ្គលដែលចេះសម្តែងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ រកបានដោយកម្រក្នុងលោក ។

៣- តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតស្ស វិញ្ញាតាបុគ្គលោ ទុល្លភោ លោកស្មឹ បុគ្គលដែលដឹងច្បាស់លាស់នូវធម្មវិន័យដែលព្រះតថាគតប្រកាសហើយ សម្តែងហើយរកបានដោយកម្រក្នុងលោក ។

៤- ធម្មានុធម្មប្បដិបន្នោ បុគ្គលោ ទុល្លភោ លោកស្មឹ បុគ្គលដែលដឹងច្បាស់លាស់នូវធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយសម្តែងហើយ ប្រតិបត្តិនូវធម៌តាមធម៌រកបានដោយកម្រក្នុងលោក ។

៥- កតញ្ញូកតវេទី បុគ្គលោ ទុល្លភោ លោកស្មឹ កតញ្ញូកតវេទីបុគ្គល រកបានដោយកម្រក្នុងលោក ។

ម្នាលលិច្ឆវីទាំងឡាយ ការកើតប្រាកដនៃរតនៈទាំង ៥ យ៉ាងនេះឯង រកបានដោយកម្រក្នុងលោក ។

## អដ្ឋកថា

ពាក្យថា នីលា នេះរួមពណ៌ខៀវទុកទាំងអស់ ។ ពាក្យថា នីលវណ្ណា ជាដើម សម្តែងការបែកពណ៌នោះ ។ ក្នុងបទថា នីលាវណ្ណា នោះតាមប្រក្រតីវណ្ណៈរបស់ស្តេចលិច្ឆវី ទាំងនោះមិនខៀវ តែលោកពោលពាក្យនោះ ព្រោះស្តេចទាំងនោះ លាបដោយគ្រឿងលាបពណ៌ខៀវ ។ បទថា នីលវត្ថា បានដល់ សូម្បីសំពត់សាច់ល្អនិងសំពត់សូត្រជាដើមរបស់ ស្តេចទាំងនោះក៏ជា

ពណ៌ខៀវទាំងអស់ ។ បទថា នីលាលង្ការា បានដល់ ប្រដាប់ដោយកែវមណីខៀវនិងផ្កាឈើខៀវ សូម្បីគ្រឿងប្រដាប់ដ៏ទៃ សេះ រថ រាំងនន ពិដារ និងសម្លៀកបំពាក់របស់ស្តេចទាំងនោះក៏ខៀវទាំងអស់ ។ គប្បីជ្រាបសេចក្តីក្នុងគ្រប់បទដោយន័យនេះ ។

បទថា បទុមំ យថា បានដល់ ដូចផ្កាបទុមពណ៌ក្រហមមាន ១០០ សន្លឹក ដូច្នោះ ។ បទថា កោកនទំ ជាវេវចនៈរបស់ពាក្យថា បទុមំ នោះឯង ។ បទថា បាតោ បានដល់ ព្រឹកគឺក្នុងវេលាដែលព្រះអាទិត្យរះឡើង ។ បទថា សិយា ប្រែថា គប្បីមាន ។ បទថា អវីតគន្ធំ បានដល់ មិនបាត់ ក្រអូប ។ បទថា អង្គីរសំ សេចក្តីថា ព្រះរស្មីផ្សាយចេញពីព្រះវរកាយតូចធំរបស់ព្រះដ៏មានព្រះភាគ ព្រោះដូច្នោះទើប ហៅថាព្រះអង្គីរស ។ បទថា តបន្តមាទិច្ចមិវន្តលិក្ខេ សេចក្តីថា ព្រាហ្មណ៍បិង្គិយានិពោលថា លោកចូរមើលព្រះអង្គីរសដ៏រុងរឿងដូចជាព្រះអាទិត្យបញ្ចេញពន្លឺរស្មីក្នុងអាកាស អាចធ្វើឱ្យភ្លឺក្នុងទ្វីបធំទាំង ៤ ដែលមានទ្វីបតូច ២,០០០ ជាបរិវារ ព្រាហ្មណ៍បិង្គិយានីពោលយ៉ាងនេះ សំដៅដល់ខ្លួន ឬមហាជន ។

## ឆវាលាតសូត្រ

នៅក្នុងបិដលេខ ៤២, ទំព័រ ២៣៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**បុគ្គល ៤ ពួក**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ **បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។**

១- នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ គឺ បុគ្គលមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។

២- បរហិតាយបដិបន្នោ នោ អត្តហិតាយបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ។

៣- អត្តហិតាយ បដិបន្នោ នោ បរហិតាយ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។

៤- អត្តហិតាយ ច បដិបន្នោ នោ បរហិតាយ ច បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ។

➲. ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអង្កត់ឧសដុតខ្មោចដែលភ្លើងឆេះទន្ទាលទាំងសងខាង មានលាមកប្រឡាក់ត្រង់កណ្តាល រមែងមិនសម្រេចជាឧសក្នុងស្រុកបាន ទាំងមិនសម្រេចជាឧសក្នុងព្រៃបានមានឧបមាយ៉ាងមិញ ម្នាលភិក្ខុទាំងឡាយ **បុគ្គលណាជាអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ**តថាគតពោលថាបុគ្គលនេះ មានឧបមេយ្យយ៉ាងនេះដែរ ។

➲. ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ **បុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន** បណ្តាបុគ្គលទាំងពីរនេះ បុគ្គលនេះចាត់ថា ល្អជាងប្រសើរជាង ។

➲. ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះបុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ បណ្តាបុគ្គលទាំងបីពួកនេះ បុគ្គលនេះចាត់ថា ល្អជាងប្រសើរជាង ។

➲. ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ

បុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃ បណ្តាបុគ្គលទាំង ៤ នេះ បុគ្គលនេះចាត់ថា ជាអ្នកលើសលុប ជាចំបង ជាប្រធាន ឧត្តម ប្រសើរ ។

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាទឹកដោះស្រស់ ទឹកដោះខាប់ជុំនៃទឹកដោះថ្លា ក្លាយមកអំពីទឹកដោះថ្លា បណ្តាទឹកដោះទាំងនោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃផង បណ្តាបុគ្គលទាំង ៤ នេះ បុគ្គលនេះចាត់ថាជាអ្នកលើសលុប ជាចំបង ជាប្រធាន ឧត្តម ប្រសើរ យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

## ខគ្គជិតញ្ញូសូត្រ

នៅក្នុងបិដលេខ ៤២, ទំព័រ ៣៤៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**បុគ្គល ៤ ពួក**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ **បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។**

១- ឧគ្ឃដិតញ្ញូបុគ្គល

២- វិបចិតញ្ញូបុគ្គល

៣- នេយ្យបុគ្គល

៤- បទបរមបុគ្គល ។

*ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកឯង រមែងមានប្រាកដក្នុងលោក ។*

## អដ្ឋកថា

*គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃបុគ្គលសូម្បី ៤ ពួកនេះដោយសូត្រនេះ ដូច្នេះ ៖*

**១. *ឧគ្ឃដិតញ្ញូបុគ្គលយ៉ាងណា*** *? បុគ្គលដែលត្រាស់ដឹងធម៌ឆាប់រហ័សក្នុងវេលាដែលធម្មកថិក បង្ហើបសម្ដែងឡើងហៅថា* ***ឧគ្ឃដិតញ្ញូបុគ្គល*** *។*

**២. *វិបចិតញ្ញូបុគ្គលយ៉ាងណា*** *? បុគ្គលដែលត្រាស់ដឹងធម៌ ក្នុងកាលដែលធម្មកថិកបំបែកសេចក្ដីឱ្យពិស្ដារ ហៅថា* ***វិបចិតញ្ញូបុគ្គល*** *។*

**១.នេយ្យបុគ្គលយ៉ាងណា** ?បុគ្គលលុះតែរៀនសាក សួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចូលទៅសេពគប់អង្គុយជិតកល្យាណមិត្ត ទើបត្រាស់ដឹងធម៌ដោយលំដាប់ ហៅថា **នេយ្យបុគ្គល** ។

**១.បទបរមបុគ្គលយ៉ាងណា** ? បុគ្គលដែលស្តាប់ច្រើនក្តី រៀនសូត្រច្រើនក្តី ចងចាំច្រើនក្តី បង្ហាញច្រើនក្តី ក៏មិនត្រាស់ដឹងធម៌ក្នុងជាតិនោះឡើយ ហៅថា **បទបរមបុគ្គល** ។

## បដិភាណសូត្រ

នៅក្នុងបិដលលេខ៤២, ទំព័រ ៣៤៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី[**បុគ្គល៤ ពួក**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ **បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។**

១- យុត្តប្បដិភាណោ ន មុត្តប្បដិភាណោ បុគ្គលមានប្រាជ្ញាគួរ តែមិនមានប្រាជ្ញារហ័ស[1]

---

១. បានដល់ បុគ្គលកាលដោះស្រាយប្រស្នា ក៏ដោះស្រាយត្រឹមត្រូវតែដោះស្រាយមិនរហ័ស គឺនិយាយសន្សឹម ៗ ។

២- មុត្តប្បដិភាណោ ន យុត្តប្បដិភាណោ មានប្រាជ្ញារហ័ស តែមិនមានប្រាជ្ញាគួរ

៣- យុត្តប្បដិភាណោ ច យុត្តប្បដិភាណោ ច មានប្រាជ្ញាគួរផង មានប្រាជ្ញារហ័សផង

៤- នេវ យុត្តប្បដិភាណោ ន មុត្តប្បដិភាណោ មានប្រាជ្ញាមិនគួរ មានប្រាជ្ញាមិនរហ័ស ។

*ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។*

## សុន្ទរិកសូត្រ

*នៅក្នុងបិដលេខ ៣០, ទំព័រ ១០២ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**ការបូជាភ្លើង**] មានសេចក្ដីថា ៖*

*សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅទៀបឆ្នេរស្ទឹងសុន្ទរិកាក្នុងដែនកោសល ។*

*សម័យនោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ តែងបូជាភ្លើង បំរើនូវការបូជាភ្លើងទៀបឆ្នេរសុន្ទរិកា ។*

លុះសុន្ទរិកភារទ្វាជព្រាហ្មណ៍បូជាភ្លើង បំរើនូវការបូជាភ្លើង ហើយក៏ក្រោកអំពីអាសនៈងាកមើលជុំទិសទាំង ៤ គិតថា អ្នកណាហ្ន៎ គួរបរិភោគនូវបាយាសដែលសល់ពីបូជានេះ ។

សុន្ទរិកភារទ្វាជព្រាហ្មណ៍បានឃើញព្រះមានព្រះភាគទ្រង់គង់ទទូរព្រះសិរ ក្រោមម្លប់ឈើមួយ លុះឃើញហើយក៏កាន់នូវបាយាសដែលសល់អំពីការបូជាដោយដៃឆ្វេង ហើយកាន់នូវកុណ្ឌីទឹកដោយដៃស្តាំ ចូលទៅរកព្រះមានព្រះភាគ ។

លំដាប់នោះឯងព្រះមានព្រះភាគ ទ្រង់បើកព្រះសិរដោយឮសូរជើងនៃសុន្ទរិកភារទ្វាជព្រាហ្មណ៍ ។

សុន្ទរិកភារទ្វាជព្រាហ្មណ៍ ក៏ពោលថា លោកដ៏ចម្រើន នេះក្បាលត្រងោល លោកដ៏ចម្រើន នេះក្បាលត្រងោល ដូច្នេះ ហើយចង់ត្រឡប់អំពីទីនោះមកវិញ ។

( លំដាប់នោះ )សុន្ទរិកភារទ្វាជព្រាហ្មណ៍ មានសេចក្តីត្រិះរិះដូច្នេះថា ព្រាហ្មណ៍ទាំងឡាយ ពួកមួយក្នុងលោកនេះ មានក្បាលត្រងោលដែរ បើដូច្នោះមានតែអាត្មាអញត្រូវចូលទៅរកលោកដ៏ចម្រើន នោះហើយសួរនូវជាតិវិញ ។

លំដាប់នោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះ នឹងព្រះមានព្រះភាគថា លោកដ៏ចម្រើន ជាជាតិអ្វី ។

ព្រះអង្គត្រាស់ថា ៖

ចូរអ្នកកុំសួររកជាតិឡើយ ចូរសួរតែការប្រព្រឹត្តវិញ ភ្លើងតែងកើតអំពីឈើ ឯអ្នកប្រាជ្ញទោះបីកើតក្នុងត្រកូលទាប ក៏គង់មានសេចក្តីព្យាយាមជាបុរសអាជានេយ្យ ជាអ្នកហាមឃាត់នូវបាបដោយហិរិ ទូន្មានដោយបរមត្ថសច្ចៈ ប្រកបដោយការទូន្មាននូវឥន្ទ្រិយដល់នូវទីបំផុតនៃចតុវេទ គឺមគ្គ ៤ មានព្រហ្មចរិយៈនៅរួចហើយ បុគ្គលណាតាក់តែងនូវយ័ញ្ញ ជនគប្បីហៅបុគ្គលនោះ (ថាជាព្រាហ្មណ៍ដ៏ឧត្តម) បុគ្គលនោះរមែងបូជានូវទក្ខិណេយ្យបុគ្គលទាំងឡាយតាមកាល ។

សុន្ទរិកភារទ្វាជព្រាហ្មណ៍ពោលថា ៖

វត្ថុនេះ ខ្ញុំបូជាហើយដោយប្រពៃ វត្ថុនេះខ្ញុំគំនាប់ហើយដោយប្រពៃដោយពិតខ្ញុំមិនបានឃើញបុគ្គលណាដែលដល់នូវវេទដូចជាព្រះអង្គសោះព្រោះថាជនឯទៀតលុះតែមិនឃើញពួកបុគ្គល

**ដូចជាព្រះអង្គទើបបរិភោគបាយាសដែលសល់អំពីការបូជា ។**

( សុន្ទរិកភារទ្វាជព្រាហ្មណ៍ក្រាបទូលថា ) សូមព្រះគោតមដ៏ចម្រើន ជាព្រាហ្មណ៍ដ៏ចំរើន បរិភោគចុះ ។

ព្រះអង្គត្រាស់ថា ៖

**តថាគតមិនគួរបរិភោគភោជន ដែលបានអំពីពោលគាថាដូចជាចម្រៀងទេ ម្នាលព្រាហ្មណ៍ធម៌នេះ មិនមែនជាធម៌របស់ពួកបុគ្គលអ្នកឃើញធម៌អាចីទេ ព្រះពុទ្ធទាំងឡាយតែងបន្ទោរបង់នូវការពោលគាថា ដូចជាចម្រៀង ម្នាលព្រាហ្មណ៍ កាលបើធម៌មានហើយនេះឯង ជាការចិញ្ចឹមជីវិត ចូរអ្នកទំនុកបំរុងព្រះខីណាស្រព ដែលមានគុណបរិបូរណ៍ អ្នកស្វែងរកនូវគុណដ៏ធំ អ្នករម្ងាប់នូវសេចក្តីរពឹសដោយបាយនិងទឹកដទៃចុះព្រោះថា នោះជាខេត្តរបស់បុគ្គលអ្នកប្រាថ្នានូវបុណ្យ ។**

( លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ក្រាបទូលថា ) បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះខ្ញុំព្រះអង្គនឹងឱ្យនូវបាយាសដែលសល់អំពីការបូជានេះដល់អ្នកណា ។

ម្នាលព្រាហ្មណ៍ក្នុងលោក ព្រមទាំងទេវលោកមារលោក

ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញមានបុគ្គលណាដែលបរិភោគបាយាសល់អំពីការបូជាហើយ គប្បីដល់នូវការទ្រុឌទ្រោមទៅដោយស្រួល ក្រៅពីតថាគតឬ ក្រៅពីសាវ័កតថាគតនោះឡើយ ម្នាលព្រាហ្មណ៍បើដូច្នោះ អ្នកចូរចាក់ចោលនូវបាយាស ដែលសល់អំពីការបូជានោះ ក្នុងទីគ្មានស្មៅស្រស់ ឬបាចទៅក្នុងទឹកដែលគ្មានសត្វចុះ ។

លំដាប់នោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ក៏បាចបាយាសដែលសល់អំពីការបូជានោះ( ទៅក្នុងទឹកដែលមិនមានសត្វ ) ។

លុះព្រាហ្មណ៍បានបាចទៅក្នុងទឹកហើយ ក៏ធ្វើសំឡេងឰ្ញ វិចិដ វិចិដ ហុយផ្សែងឡើង ហុយផ្សែងថ្កោល ។ ដូចជាផាលគេហាលអស់មួយថ្ងៃ ហើយដាក់ទៅក្នុងទឹក ធ្វើនូវសំឡេងឰ្ញវិចិដ វិចិដ ហុយផ្សែងឡើង ហុយផ្សែង ថ្កោល យ៉ាងណាមិញបាយាសដែលសល់អំពីការបូជានោះ ព្រាហ្មណ៍បានបាចទៅក្នុងទឹក ហើយធ្វើនូវសំឡេង ឰ្ញវិចិដ វិចិដ ហុយ ផ្សែងឡើង ហុយផ្សែង ថ្កោល យ៉ាងនោះឯង ។

លំដាប់នោះសុន្ទរិកភារទ្វាជព្រាហ្មណ៍មានសេចក្ដីសង្វេគ កើតសេចក្ដីព្រឺរោម ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឋិតនៅក្នុងទីសមគួរ ។

លុះសុន្ទរិកភារទ្វាជព្រាហ្មណ៍ឋិតក្នុងទីសមគួរហើយទើបព្រះមានព្រះភាគ បានត្រាស់ដោយព្រះគាថាទាំងឡាយថា ៖

ម្នាលព្រាហ្មណ៍ អ្នកកុំដុតឧស សំគាល់ថាបរិសុទ្ធឡើយ ព្រោះថា ការដុតនុ៎ះ ជាខាងក្រៅទេ បុគ្គលណាប្រាថ្នានូវសេចក្ដីបរិសុទ្ធព្រោះហេតុនោះ ម្នាលព្រាហ្មណ៍ តថាគតលះបង់នូវការដុតឧសហើយ ដុតតែភ្លើងខាងក្នុងទេ តថាគតមានភ្លើងរុងរឿងជានិច្ច មានចិត្តតាំងមាំជានិច្ច ជាអរហន្តប្រព្រឹត្តនូវព្រហ្មចរិយៈ ម្នាលព្រាហ្មណ៍ មានះរបស់អ្នកដូចជាអម្រែក ដ៏ធ្ងន់សេចក្ដីក្រោធដូចជាផ្សែង ពាក្យកុហកដូចជាផេះ អណ្ដាត ដូចជាវែកហទយវត្ថុដូចជាកន្លែងភ្លើង ចិត្តដែលបុគ្គលទូន្មានល្អហើយដូចជាភ្លើងរបស់បុរស ពួកបុគ្គលដល់នូវវេទងូតក្នុងអន្លង់ណា មិនទទឹកខ្លួនសោះ តែងឆ្លងដល់ត្រើយគឺព្រះនិព្វាន ម្នាលព្រាហ្មណ៍អន្លង់នោះគឺធម៌មានសីលជាកំពង់ មិនល្អក់ ដែលសប្បុរសទាំងឡាយ ម្នាល

ព្រាហ្មណ៍ សច្ចៈក្តី ធម្មៈ[១]ក្តី សយមៈក្តី[២] ព្រហ្មចរិយៈក្តី ជាធម្មជាតិតាំងនៅជាកណ្តាល ជាចំណែកដ៏ប្រសើរ ចូរអ្នកធ្វើនូវការមនស្ការចំពោះព្រះខីណាស្រព ដែលមានចិត្តស្លូតត្រង់ទាំងឡាយចុះតថាគតហៅជននោះថា ជាអ្នករឭកនូវធម៌ដូច្នេះឯង ។

កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយសុន្ទរិកភារទ្វាជព្រាហ្មណ៍ បានពោលនូវពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើនច្បាស់ពេកណាស់ ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ភារទ្វាជៈមានអាយុ ក៏ជាអរហន្ត មួយរូបដែរ ។

## អដ្ឋកថា

បទថា សុន្ទរិកភារទ្វាជោ បានដល់ អ្នកមានឈ្មោះយ៉ាងនោះព្រោះបូជាភ្លើងក្បែរមាត់ទន្លេឈ្មោះថា **សុន្ទរិកា** ។

បទថាសុន្ទរិកាយបានដល់ទន្លេមានឈ្មោះយ៉ាងនោះ ។

---

១ ធម្មៈបានដល់ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ ២. ការសង្រួម បានដល់ សម្មាកម្មន្តៈ សម្មាអាជីវៈ ។

បទថា អគ្គឹ ជុហតិ បានដល់ ឱ្យភ្លើងឆេះសន្ធោរឡើង ដោយការដាក់របស់បូជា ។

បទថា អគ្គិហុត្តំ បានដល់ចូលទៅកាន់រោងភ្លើងដោយការ ខាត់ពណ៌បូកលាប និងពលីកម្មជាដើម ។

បទថា គោ នុ ខោ ឥមំ ហព្យសេសំ កុញ្ជេយ្យ សេចក្តីថា បានឮថា ព្រាហ្មណ៍នោះឃើញបាយបាយាសដែលសល់អំពីការ បូជាភ្លើងហើយគិតថា បាយបាយាសដែលដាក់ចុះក្នុងភ្លើង ដែល មហាព្រហ្មបរិភោគមុនហើយ តែបាយបាយាសនេះនៅសល់ បើ ថា យើងគប្បីឱ្យបាយបាយាសនោះដល់ព្រាហ្មណ៍ ដែលកើតពី មាត់ព្រះព្រហ្ម កាលបើដូច្នេះ សូម្បីបុត្រព្រមទាំងបិតា ក៏ជាអ្នក ដែលយើងចិញ្ចឹមឆ្អែតគ្រប់គ្រាន់ហើយ និងផ្លូវទៅព្រហ្មលោកក៏ យើងបានធ្វើឱ្យបរិសុទ្ធិល្អហើយ ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍នោះ ក្រោកអំពីអាសនៈ ក្រឡេកមើលទិសទាំង ៤ ដោយជុំវិញដើម្បី នឹងមើលព្រាហ្មណ៍ ដោយគិតថា អ្នកណាហ្ន៎គួរបរិភោគបាយ បាយាសដែលសល់អំពីការបូជានេះ ។

បទថា រុក្ខមូលេ សេចក្ដីថា ត្រង់គល់ឈើធំក្នុងជនព្រៃនោះ ។

បទថា សសីសំ បារុតំ និសិន្នំ សេចក្ដីថា គង់ប្រថាប់គ្របព្រះវរកាយព្រមទាំងព្រះសិរសា ។

សួរថា ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគគង់ប្រថាប់ក្នុងទីនោះ ។

ឆ្លើយថា បានឮថា ព្រះមានព្រះភាគទ្រង់ត្រួតមើលលោកក្នុងវេលាជិតភ្លឺ ឃើញព្រាហ្មណ៍នេះហើយ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះកាន់បាយបាយាសដ៏ប្រសើរ បែបនេះយកទៅដុតភ្លើង ដោយតាំងចិត្តនឹងឱ្យមហាព្រហ្មបរិភោគ ឈ្មោះថា ធ្វើវត្ថុដែលគ្មានផល ។ល ។ យើងនឹងឱ្យមគ្គ ៤ ផល ៤ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគស្ដេចក្រោកឡើងពីព្រឹកព្រលឹមតែម្ដង ទ្រង់ជម្រះព្រះវរកាយសម្រេចហើយទ្រង់កាន់បាត្រចីវរ ស្ដេចទៅគង់ប្រថាប់ក្បែរគល់ដើមឈើនោះ ដោយន័យដូចពោលហើយ

នុ៎ះឯង ។

សួរថា កាលបើដូច្នោះ ហេតុអ្វី បានជាព្រះអង្គទ្រង់គ្រប ដរាបដល់អស់ព្រះសិរសា ។

ឆ្លើយថា ដើម្បីការពារសន្សើមធ្លាក់និងខ្យល់ត្រជាក់ ។ ព្រះតថាគតទ្រង់អាចអត់ធន់សន្សើមធ្លាក់ និងខ្យល់ត្រជាក់នោះបាន តែបើទ្រង់គង់នៅមិនបានគ្របព្រះវរកាយ ព្រាហ្មណ៍ចាំបានអំពីឆ្ងាយក៏នឹងត្រឡប់ទៅវិញ ។ កាលបើដូច្នេះក៏នឹងមិនបាននិយាយចរចាគ្នាដូច្នោះ ព្រះមានព្រះភាគមានព្រះតម្រិះថា កាលព្រាហ្មណ៍មក តថាគតនឹងបើកសីសៈ ពេលនោះព្រាហ្មណ៍ ក៏នឹងឃើញតថាគត នឹងបាននិយាយចរចាគ្នា តថាគតនឹងសម្ដែងធម៌តាមជួរដែលនិយាយចរចាគ្នាដល់ព្រាហ្មណ៍ដូច្នេះ ទើបបានទ្រង់ធ្វើយ៉ាងនោះ ដើម្បីនឹងបាននិយាយចរចាគ្នា ។

បទថា ឧបសង្កមិ សេចក្ដីថា ព្រាហ្មណ៍គិតថា លោកអ្នកនេះគ្របដរាបដល់អស់សីសៈប្រកបសេចក្ដីព្យាយាមមួយ យប់

ទាល់ភ្លឺ យើងនឹងថ្វាយទក្ខិណោទក ហើយថ្វាយបាយបាយាស ដែលសល់ពីការបូជាភ្លើងនេះ ដល់លោកនេះ ដូច្នេះមានសេចក្តីសម្គាល់ថា លោកជាព្រាហ្មណ៍ទើបចូលទៅរក ។

បទថា មុណ្ឌោ អយំ ភវំ មុណ្ឌកោ អយំ ភវំ សេចក្តីថា លុះមព្រះមានព្រះភាគបើកព្រះសិរសា ព្រាហ្មណ៍ឃើញព្រះអង្គមានសក់ខ្លី ទើបពោលថា អ្នកនេះជាព្រះសមណៈត្រងោល ។ កាលត្រូតមើលយល់ច្បាស់ក្រៃលែងជាងនោះ ក៏មិនបានឃើញសូម្បីចុងសក់លុះមទីងញ់របាន ទើបពោលតិះដៀលថា សមណៈត្រងោល ។

បទថា តតោវ បានដល់អំពីប្រទេសដែលខ្លួនឈរ ឃើញនោះឯង ។

បទថា មុណ្ឌាបិ ហិ សេចក្តីថា ព្រោះហេតុយ៉ាងណាមួយព្រាហ្មណ៍មានសីសៈត្រងោលក៏មាន ។

បទថា មា ជាតឹ បុច្ឆ សេចក្តីថា បើលោកប្រាថ្នាថា ទាន

មានផលច្រើន ក៏កុំសួរដល់ជាតិឡើយ ។ ព្រោះជាតិមិនមែនហេតុនៃភាពជាព្រះទក្ខិណេយ្យបុគ្គល ។

បទថា ចរណញ្ច បុច្ឆ សេចក្តីថា មា្យ៉ាងទៀតចូរសួរដល់ការប្រព្រឹត្តគឺប្រភេទនៃគុណមានសីលជាដើម ។ ព្រោះនោះ ជាហេតុនៃភាពជាព្រះទក្ខិណេយ្យបុគ្គល ។ ឥឡូវនេះកាលនឹងទ្រង់ធ្វើសេចក្តីនោះ ឱ្យជាក់ច្បាស់ដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា កដ្ឋា ហវេ ជាយតិ ជាតវេទោជាដើម ។ ក្នុងសេចក្តីនោះ មានអធិប្បាយដូចតទៅនេះ ៖

ក្នុងទីនេះភ្លើង រមែងកើតអំពីឈើ និងភ្លើងដែលកើតអំពីឈើមានសាលាជាដើមនោះមិនបានធ្វើនាទីរបស់ភ្លើង ភ្លើងដែលកើតអំពីឈើមានបំពង់ទឹកផឹកជាដើម មិនបានធ្វើនាទីរបស់ភ្លើង តែភ្លើងដែលកើតពីទីណាមួយក៏ដោយ រមែងធ្វើនាទីរបស់ភ្លើងពិតដោយគុណសម្បត្តិ មានអណ្តាតរបស់ខ្លួនជាដើម ។ ដោយប្រការដូច្នេះ អ្នកដែលកើតក្នុងត្រកូលព្រាហ្មណ៍ជាដើម រមែងជាទក្ខិណេ-យ្យបុគ្គល អ្នកដែលកើតក្នុងត្រកូលចណ្ឌាលជាដើមជាទក្ខិណេយ្យបុគ្គលមិនបាន ។ មា្យ៉ាងទៀត អ្នកដែលកើតក្នុងត្រកូលទាបក៏ដោយ

អ្នកដែលកើតក្នុងត្រកូលខ្ពស់ក៏ដោយ ជាមុនីអ្នកមានអាសវៈអស់ហើយ មានសេចក្តីព្យាយាម កម្ចាត់ទោសដោយហិរិ ជាអ្នកដឹងច្បាស់ដល់ហេតុ រមែងជាអ្នកមានជាតិ គឺជាទក្ខិណេយ្យបុគ្គលខ្ពស់បំផុត ដោយគុណសម្បត្តិដែលមានសេចក្តីព្យាយាមនិងហិរិជាប្រធាននេះ ។

ដោយថា គេរមែងទ្រទ្រង់ទុកនូវគុណទាំងឡាយដោយសេចក្តីព្យាយាម រមែងហាមឃាត់ទោសទាំងឡាយ ដោយហិរិ ។ ម្យ៉ាងទៀត បទថា មុនី ក្នុងទីនេះ បានដល់ អ្នកប្រកបដោយមោនធម៌ ( ភាពជាអ្នកស្ងៀម ) ។

បទថា ធិតិមា បានដល់ មានសេចក្តីព្យាយាម ។

បទថា អាជានីយោ បានដល់ ដឹងដល់ហេតុ ។

បទថា ហិរិនិសេធោ បានដល់ ហាមអំពីសេចក្តីអាក្រក់ដោយហិរិ ។

បទថា សច្ចេន ទន្តោ បានដល់ ទូន្មានខ្លួនដោយបរមត្ថសច្ចៈ ។

បទថា ទមសា ឧបេតោ បានដល់ ចូលដល់ដោយការ

ទុទ្ធានឥន្ទ្រិយ ។

បទថា វេទន្តគូ សេចក្តីថា ដល់ទីបំផុតនៃវេទគឺមគ្គ ៤ ឬដល់ទីបំផុតនៃកិលេសដោយវេទគឺ មគ្គ ៤ ។

បទថា វុសិតព្រហ្មចរិយោ បានដល់ នៅចប់មគ្គព្រហ្ម-ចរិយ ។

បទថា យញ្ញូបនីតោ បានដល់ បង្អោននាំយញ្ញឬចាត់ចែងយញ្ញ ។

បទថា តមុបវ្ហយេថ សេចក្តីថា អ្នកដែលចាត់ចែងយញ្ញនោះ ឈ្មោះថា បូជាព្រាហ្មណ៍នោះ គឺព្រាហ្មណ៍ដោយបរមត្ថ ។ ក៏ពាក្យថា ខ្ញុំហៅគឺ ហៅព្រះឥន្ទ ហៅព្រះសោមៈ រៀនព្រះវរុណ ហៅព្រះឦសានៈជាពាក្យស្រែកហៅដែលគ្មានប្រយោជន៍ ។

បទថា កាលេន សេចក្តីថា ព្រាហ្មណ៍កាលសម្តែងការបូជាគប្បីបូជាព្រាហ្មណ៍នោះខាងក្នុងវេលាត្រាច់ប៉ុណ្ណោះ ដោយពាក្យថា ដល់វេលាហើយលោកម្ចាស់ ភត្តាហារសម្រេចហើយ ។

បទថា សោ ជុហាតិ ទក្ខិណេយ្យេ សេចក្តីថា អ្នកណានិមន្តព្រះខីណាស្រពមកថ្វាយទក្ខិណាគឺ បច្ច័យបួនក្នុងព្រះខីណា

ស្រពនោះ អ្នកនោះឈ្មោះថា បូជាព្រះទក្ខិណេយ្យបុគ្គលក្នុងកាល ដោយប្រការដូច្នេះមិនមែនដាក់ចូលក្នុងភ្លើងដែលមិនមានចិត្ត ។

ព្រាហ្មណ៍ ស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ជ្រះថ្លាហើយ ឥឡូវនេះ កាលនឹងធ្វើសេចក្តីជ្រះថ្លារបស់ខ្លួនឱ្យជាក់ច្បាស់ ទើបក្រាបទូលថា អទ្ធា សុយិដ្ឋំ ជាដើម ។ ពាក្យនោះមានសេចក្តីដូចតទៅនេះ ។

ការបូជារបស់ខ្ញុំព្រះអង្គនេះ ឥឡូវនេះនឹងជាការបូជាដោយល្អ សែនបួងសួងដោយល្អពិតប្រាកដ តែកាលមុនខ្ញុំព្រះអង្គយកដុតភ្លើងជាវត្ថុដែលគ្មានប្រយោជន៍ ។

បទថា អញ្ញោ ជនោ បានដល់ បុថុជ្ជនអ្នកអន្ធពាលនិយាយទៅថា យើងជាព្រាហ្មណ៍ យើងជាព្រាហ្មណ៍ ។

បទថា ហព្យសេសំ បានដល់ នៅសល់អំពីការបូជា ។ ពាក្យថា កុញ្ជូតុ តវំ ជាដើមគប្បីជ្រាបដោយន័យដែលពោលហើយក្នុងសូត្រមុន ។

បទថា ន ខ្វាហំ កាត់ជា ន ខោ អហំ ។

សួរថាក៏ព្រោះហេតុអ្វីព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។

ឆ្លើយថា បានឮថា លួមព្រហ្មណ៍បង្អោនភោជននោះចូលទៅប៉ុណ្ណោះទេវតាក្នុងទ្វីបធំ ៤ ទ្វីបតូច ២,០០០ កាន់យកផ្កា ឈើផ្លែឈើនិងទឹកដោះថ្លា ទឹកដោះខាប់ ប្រេងទឹកឃ្មុំ ទឹកអំពៅជាដើម ដោយសម្គាល់ថាព្រះសាស្តានឹងសោយ ទើបកាន់យកឱជៈដែលឱ្យកើតដោយអានុភាពដែលជាទិព្វដាក់ចូល ដូចប្របាច់ក្បាលទឹកឃ្មុំកាន់យកទឹកឃ្មុំ ។ ព្រោះដូច្នោះ ភោជននោះ ទើបដល់ភាពជារបស់ល្អិត ។ ក៏ភោជននោះជាវត្ថុគ្រោតគ្រាត សម្រាប់មនុស្សដូច្នោះ ទើបមិនដល់ការរលួយទៅដោយល្អសម្រាប់មនុស្សទាំងនោះព្រោះជាវត្ថុគ្រោតគ្រាតនុ៎ះឯង ។ តែផ្សំពូជ ៣ យ៉ាងចុះក្នុងដោះគោភោជននោះទើបក្លាយជាលាយ ដោយរបស់គ្រោតគ្រាត ។ មួយទៀតភោជននោះជាវត្ថុល្អិតសម្រាប់ពួកទេវព្រោះដូច្នោះទើបមិនដល់សេចក្តីរលួយទៅដោយល្អ សម្រាប់ទេវតាពួកនោះ ព្រោះជាវត្ថុល្អិត ។ សូម្បីក្នុងផ្ទៃរបស់ព្រះខីណាស្រពជាសុក្ខវិបស្សកក៏មិនរលួយទៅ ។ តែព្រះខីណាស្រពដែលបានសមាបត្តិ៨គប្បីរលួយ

ទៅដោយអំណាចសមាបត្តិ ។ តែសម្រាប់ព្រះមានព្រះភាគ គប្បីរលួយ ទៅដោយតេជោធាតុកើតពីកម្មតាមប្រក្រតីតែម្យ៉ាង ។

បទថា អបហរិតេ ប្រែថា ប្រាសចាករបស់ខៀវ ។ ក៏បើគប្បីដាក់ចុះក្នុងស្មៅខៀវ ស្មៅទាំងឡាយក៏នឹងគប្បីស្អុយ ដោយបាយបាយាសដែលល្អិត ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនប្រព្រឹត្តកន្លងភូតគាមសិក្ខាបទ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ តែគួរដាក់ចូលក្នុងទីមានស្មៅដើមធំ ៗ ខ្ពស់ប្រមាណត្រឹមក ។

បទថា អប្បាណកេ សេចក្តីថា ដោយថា កាលដាក់ចុះក្នុងទឹកតិចដែលមានសត្វ សត្វក៏នឹងស្លាប់ព្រោះទឹកនោះ ទើបត្រាស់យ៉ាងនោះ តែទីណាមានទឹកជ្រៅច្រើន សូម្បីកាលដាក់ទាំង១០០ថាស ១,០០០ថាស ទឹករមែងមិនខូច គួរដាក់ក្នុងទឹកដូច្នោះ ។

បទថា ឱបិលាបេសិ សេចក្តីថា ឱ្យលិចចុះព្រមនឹងថាសមាស ។

បទថា វិចិដាយតិ វិដិចិដាយតិ សេចក្តីថា រមែងធ្វើ

សំឡេងយ៉ាងនោះ ។

សួរថា ក៏នោះជាអានុភាពរបស់បាយបាយាស ឬជាអានុភាពរបស់ព្រះតថាគត ។

ឆ្លើយថា ជាអានុភាពរបស់ព្រះតថាគត ។ ក៏ព្រាហ្មណ៍នេះឱ្យបាយបាយាសលិចចុះហើយ ក៏នឹងដើរក្រៅផ្លូវ មិនមកកាន់សំណាក់ព្រះសាស្តា ដើរហួសទៅ ។

លំដាប់នោះ ព្រះមានព្រះភាគមានព្រះតម្រិះថា ព្រាហ្មណ៍ឃើញសេចក្តីអស្ចារ្យនេះហើយ នឹងមកកាន់សំណាក់របស់តថាគត កាលបើដូច្នោះ តថាគតនឹងទម្លាយការប្រកាន់មិច្ឆាទិដ្ឋិរបស់គេដោយព្រះធម៌ទេសនា ឱ្យធ្លាក់ចុះក្នុងព្រះសាសនាឱ្យផឹកទឹកអម្រឹតដូច្នេះហើយបានទ្រង់ធ្វើយ៉ាងនោះដោយកម្លាំងអធិដ្ឋាន ។

បទថា ទារុសមាទហានោ បានដល់ ដុតឈើ ។

បទថា ពហិទ្ធា ហិ ឯតំ សេចក្តីថា ឈ្មោះថា ការដុតឈើនេះមានខាងក្រៅពីអរិយធម៌ បើសេចក្តីបរិសុទ្ធិគប្បីមាន ដោយ

ការដុតឈើនេះ ពួកដុតព្រៃជាដើមដុតឈើជាច្រើន ក៏នឹងដល់ភាពបរិសុទ្ធិមុនគេ ។

បទថា កុសលា បានដល់ អ្នកឆ្លាតក្នុងខ្លួនជាដើម ។

បទថា អជ្ឈត្តមេវ ជលយាមិ ជោតឹ សេចក្ដីថា យើងនឹងញុំាងភ្លើងគឺ ញាណឱ្យឆេះសន្ធោខាងក្នុងខ្លួន គឺក្នុងសន្ដានរបស់ខ្លួន ។

បទថា និច្ចគ្គិនី បានដល់ មានភ្លើងឆេះសន្ធោជានិច្ច ដោយសព្វញ្ញុតញ្ញាណដែលជាប់ដោយអាវជ្ជនចិត្ត ។

បទថា និច្ចសមាហិតត្តោ បានដល់ អ្នកមានចិត្តតាំងនៅដោយប្រពៃជានិច្ច ។

បទថា ព្រហ្មចរិយំ ចរាមិ បានដល់ ព្រះអង្គទ្រង់ប្រកាន់ព្រហ្មចរិយ ដែលទ្រង់ប្រព្រឹត្តក្បែរពោធិមណ្ឌស្ថាន ទើបត្រាស់យ៉ាងនេះ ។

បទថា មានោ ហិ តេ ព្រាហ្មណ ខារិភារោ សេចក្ដីថា ភារៈ គឺអម្រែកដែលបុគ្គលនាំទៅដោយយកសូម្បីនៅខាងលើក៏

រមែងពាល់ត្រូវនឹងផែនដីក្នុងទីដែលជាន់ទៅ ៗយ៉ាងណា មានះដែលលើកឡើងព្រោះអាស្រ័យវត្ថុដែលកាន់គ្នា មាន ជាតិគោត្រត្រកូលជាដើមដូច្នោះ កាលញុំាងសេចក្តីប្ញស្យាឱ្យកើតឡើងទីនោះ ៗរមែងឱ្យលិចចុះក្នុងអបាយ៤ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ព្រាហ្មណ៍ក៏មានះរបស់លោកដូចជាភារៈគឺ អម្រែក ។

បទថា កោធោ ធូមោ សេចក្តីថា សេចក្តីក្រោធ ឈ្មោះថាដូចជាផ្សែងភ្លើង ព្រោះអត្ថថា ជាសេចក្តីសៅហ្មងនៃភ្លើង គឺញាណរបស់លោក ។ ព្រោះហេតុនោះឯង ភ្លើងគឺញាណដែលសៅហ្មងរបស់លោក ទើបមិនរុងរឿង ។ ដោយបទថា ភស្មនិម្មោសវជ្ជំ លោកសម្តែងថា **មុសាវាទ** ឈ្មោះថា កម្ទេចផេះ ។ ព្រោះអត្ថថាប្រាសចាកឱជៈ ។ លោកអធិប្បាយថាដូចភ្លើងដែលកម្ទេចផេះបិទទុក រមែងមិនរុងរឿងយ៉ាងណា ញាណរបស់លោកដែលមុសាវាទបិទទុកក៏យ៉ាងនោះ ។ ដោយពាក្យថា ជិវ្ហា សុជា លោកពោលថា លោកមានវែកដែលធ្វើដោយមាសប្រាក់លោហៈឈើនិងដីយ៉ាងណាមួយទុកដើម្បីនឹងបូជាយញ្ញ យ៉ាងណា យើងមាន

អណ្ដាតធំ ដូចជាវែកគ្រឿងបូជា ដើម្បីប្រយោជន៍ដល់ការបូជាធម៌ ដូច្នោះ ។

បទថា ហទយំ ជោតិដ្ឋានំ សេចក្ដីថា ហទយៈរបស់សត្វទាំងឡាយ ជាទីតាំងនៃគំនរភ្លើង ដោយអត្ថថា ជាទីតាំងនៃការបូជាធម៌របស់យើង ដូចហទយៈរបស់លោកជាទីតាំងនៃគំនរភ្លើង ក្បែរមាត់ទន្លេ ។

បទថា អត្តា បានដល់ ចិត្ត ។

បទថា ធម្មោ រហទោ សេចក្ដីថា លោកបម្រើភ្លើង មានរាងកាយប្រលាក់ដោយផ្សែង កម្ទេចផេះនិងញើសចុះងូតទឹកក្នុងទន្លេសុន្ទរិកាយ៉ាងណា យើងមិនត្រូវការដោយអន្លង់ទឹកខាងក្រៅដូចទន្លេសុន្ទរិកា តែតថាគតមានធម៌គឺ មគ្គមានអង្គ ៨ ជាអន្លង់ទឹកយើងឱ្យសត្វ១០០ ខ្លះ១,០០០ ខ្លះ ៨៤,០០០ ខ្លះ ឱ្យងូតក្នុងធម៌គឺ មគ្គមានអង្គ ៨ នោះព្រម ៗគ្នា ដូច្នោះ ។ ដោយបទថា សីលតិត្ថោ លោកសម្ដែងថា បារិសុទ្ធិសីល ៤ ជាកំពង់នៃអន្លង់ទឹកគឺ ធម៌របស់តថាគតនោះ ។

បទថា អនាវិលោ សេចក្ដីថា ទន្លេសុន្ទរិការបស់លោក

កាលមនុស្ស ៤-៥ នាក់ឆ្លងព្រមគ្នា មានទ្រាយទាំងខាងក្រោមខាងលើកករល្អក់ យ៉ាងណា អន្លង់ទឹករបស់តថាគតមិនជាដូច្នោះទេ សូម្បីកាលសត្វច្រើនពាន់ចុះទៅឆ្លងអន្លង់ទឹកនោះក៏មិនកករល្អក់គង់ នៅថ្លាដដែល ។

បទថា សព្ភិ សតំ បសដ្ឋោ សេចក្ដីថា ធម៌របស់បណ្ឌិតទាំងឡាយ ដែលពួកបណ្ឌិតសរសើរ ។ម្យ៉ាងទៀត ធម៌នោះរបស់សប្បុរសទាំងឡាយ លោកហៅថា **សព្ភិ** ព្រោះអត្ថថា ខ្ពស់បំផុត លោកហៅថា បសដ្ឋៈ ព្រោះបណ្ឌិតសរសើរ ។

បទថា តរន្តិ ធារំ បានដល់ ដល់ត្រើយ គឺព្រះនិព្វាន ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់លើកអង្គនៃអន្លង់ទឹក គឺអរិយមគ្គឡើងសម្ដែង ទើបត្រាស់ពាក្យថា សច្ចំ ធម្មោ ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះបទថា សច្ចំ បានដល់ វចីសច្ច ។ ដោយបទថា ធម្មោ ធម៌នេះទ្រង់សម្ដែងសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈសម្មាសតិ សម្មាសមាធិ ។ ដោយបទថា សំយមោ នេះទ្រង់សំដៅយកសម្មាកម្មន្តៈ និងសម្មាអាជីវៈ ។ ម្យ៉ាងទៀត ដោយបទថា សច្ចំ នេះទ្រង់សំដៅយកមគ្គសច្ច ។ ធម៌ គឺមគ្គសច្ច

នោះដោយអត្ថបានដល់សម្មាទិដ្ឋិ ។ សមដូចពាក្យដែលត្រាស់ទុកថាសម្មាទិដ្ឋិជាមគ្គផងជាហេតុផង, តែកាលសំដៅយកសម្មាទិដ្ឋិក៏ទ្រង់សំដៅយកសម្មាសង្កប្បៈដូចគ្នា ព្រោះមានគតិដូចសម្មាទិដ្ឋិនោះ ។ ដោយបទថា ធម្មោ នេះ ទ្រង់សំដៅយកសម្មាវាយាមៈ សម្មាសតិនិងសម្មាសមាធិ ។ ដោយបទថា សំយមោ នេះ ទ្រង់សំដៅយកសម្មាវាចា សម្មាកម្មន្តៈនិងសម្មាអាជីវៈរួមសេចក្តី ថាទ្រង់សម្តែងមគ្គមានអង្គ ៨ ដោយប្រការដូច្នេះ ។ម្យ៉ាងទៀតបទថា សច្ចំបានដល់បរមត្ថសច្ច ។ បរមត្ថសច្ចនោះដោយសេចក្តីបានដល់ ព្រះនិព្វាន ។ ដោយបទថា ធម្មោ លោកសំដៅយកអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ ដោយបទថា សំយមោ សំដៅយកអង្គ ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ រមែងជាការលោកសម្តែងមគ្គមានអង្គ ៨ សូម្បីដោយប្រការដូច្នេះ ។

បទថា ព្រហ្មចរិយំ នេះក៏គឺ ឈ្មោះថា ព្រហ្មចរិយ ។

បទថា មជ្ឈេសិតា បានដល់ វៀរសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិអាស្រ័យនៅត្រង់កណ្តាល ។

បទថា ព្រហ្មបត្តិ បានដល់ដល់ភាពជាអ្នកប្រសើរ ។ ត អក្សរក្នុងពាក្យថា សត្ថុជ្ជក្ខតេសុ ឯមោ ករោហិ នេះ ធ្វើបទសន្ធិ ។ អធិប្បាយថា លោកនោះចូរធ្វើសេចក្ដីនមស្ការ ក្នុងព្រះទីណាស្រេពទាំងឡាយអ្នកត្រង់ ។

បទថា តម្ហំ ឯវំ ធម្មសារីតិ ព្រូមិ សេចក្ដីថា យើងហៅបុគ្គលដែលបដិបត្តិយ៉ាងនេះថា អ្នកនេះជាធម្មសារីនិងថា អ្នកនេះបដិបត្តិដើម្បីធម្មសារី ឬថាអ្នកនេះលះអកុសលធម៌ដោយកុសលធម៌តាំងនៅ ដូច្នេះ ។

សរុបបូជនេយ្យបុគ្គលទាំងឡាយ យ៉ាងនេះថា "បណ្ដាបព្វជិត អាចារ្យនិងឧបជ្ឈាយ៍ ជាបូជនេយ្យបុគ្គលរបស់អន្តេវាសិកទាំងឡាយជាដើម, ពួកភិក្ខុដែលចាស់ជាង ជាបូជនេយ្យបុគ្គលរបស់ពួកភិក្ខុដែលថ្មី, ពួកបព្វជិតទាំងអស់ ជាបូជនេយ្យរបស់ពួកគ្រហស្ថ ។ ចំណែកបណ្ដាគ្រហស្ថ បងប្អូនប្រុសស្រីជាបូជនេយ្យបុគ្គលរបស់ពួកប្អូនប្រុសស្រី មាតាបិតាជាបូជនេ-

យ្យបុគ្គលរបស់បុត្រទាំងឡាយ ស្វាមី ឪពុកក្មេកនិងម៉ែក្មេក ជាបូជនេយ្យរបស់ស្ត្រីក្រមុំក្នុងត្រកូល ។

ក៏ការបូជាចំពោះបូជនេយ្យបុគ្គលទាំងនោះឯងឈ្មោះ ថាជាមង្គលទាំងអស់ ព្រោះជាការសមាទាននូវកុសលធម៌និង ព្រោះជាហេតុនៃសេចក្ដីចំរើន ដោយធម៌មានអាយុជាដើម ។

ព្រោះហេតុនោះ ក្នុងចក្កវត្តិសូត្រ ទើបព្រះដ៏មានព្រះមានព្រះភាគទ្រង់ត្រាស់ថា "មនុស្សទាំងឡាយនោះនឹងជាអ្នកប្រតិបត្តិដោយប្រពៃចំពោះមាតា ជាអ្នកប្រតិបត្តិប្រពៃចំពោះបិតា ជាអ្នកប្រតិបត្តិដោយប្រពៃចំពោះសមណៈ ជាអ្នកប្រតិបត្តិដោយប្រពៃចំពោះព្រាហ្មណ៍ ជាអ្នកប្រព្រឹត្តកោតក្រែងដល់បុគ្គលដែលចំរើនក្នុងត្រកូលជាប្រក្រតី នឹងសមាទានប្រព្រឹត្តនូវកុសលធម៌នេះ មនុស្សទាំងឡាយនោះ នឹងចំរើនដោយអាយុខ្លះ នឹងចំរើនដោយពណ៌នាសម្បុរខ្លះ ព្រោះហេតុសមាទាននូវកុសលទាំងឡាយ" ។

ម្នាលភិក្ខុទាំងឡាយ ! មនុស្សទាំងឡាយណា ជាបុត្តរបស់

មាតានិងបិតាដែលមានអាយុប្រមាណ ២ ម៉ឺនឆ្នាំ ទីងជាមនុស្ស ដែលមានអាយុ ៤ ម៉ឺនឆ្នាំ ពួកមនុស្សដែលកើតមកជាបុត្រទាំង នោះ ។ កូនទាំងនោះជាអ្នកទំនុកបម្រុងមាតា គឺជាអ្នកប្រតិបត្តិ ប្រពៃចំពោះមាតា ជាអ្នកទំនុកបម្រុងបិតា ជាអ្នកទំនុកបម្រុងចំពោះ សមណៈ ជាអ្នកទំនុកបម្រុងចំពោះព្រាហ្មណ៍ ។

បុត្រដែលជាអ្នកប្រព្រឹត្តគោរព កោតក្រែងជាប្រក្រតី គឺ ប្រព្រឹត្តបន្ទាបខ្លួនចំពោះជនទាំងឡាយដែលជាច្បង គឺជាអ្នកបម្រើន មានឪពុកធំ ឪពុកមានិងបងប្រុសជាដើមក្នុងត្រកូលរបស់ខ្លួន ។

## វត្ថុដែលគួរបូជា

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ព្រះជន្មនៅ មានភិក្ខុ ភិក្ខុនី ឧបាសកឧបាសិកា ទេវតាទាំងឡាយជាច្រើនបាននិមន្តនិងអញ្ជើញ មកគ្រប់ទិសទាំង ៤ ដើម្បីចូលគាល់ថ្វាយបង្គំ ធ្វើសក្ការៈបូជា ដោយផ្កាភ្ញីទាំងឡាយជាច្រើនដល់ព្រះអង្គ ដែលបុគ្គលដ៏ប្រសើរ ខ្ពង់ខ្ពស់បំផុតនៅក្នុងលោក គោលបំណងគឺ ប្រាថ្នាចង់ស្តាប់នូវ ព្រះធម៌ ប្រាថ្នាឃើញប្រាថ្នាបម្រើ ប្រាថ្នាថ្វាយទានជាដើម ដែល

ជាហេតុនាំមកនូវសេចក្តីសុខនៅក្នុងជីវិតនេះ ។ មែនពិតព្រះអង្គទ្រង់បានចូលបរិនិព្វានទៅហើយ យើងគ្រប់គ្នាដែលជាអ្នកមានសទ្ធា ជាអនុជាតបុត្រ( បុត្រដែលចេះស្តាប់បង្គាប់ ) ប្រាថ្នាចង់ចូលទៅគាល់ ឃើញព្រះរូបកាយផ្ទាល់ដូចកាលពីមុននោះ ឬប្រាថ្នាធ្វើសក្ការៈបូជាព្រះអង្គផ្ទាល់ ដូចកាលព្រះអង្គនៅមានព្រះជន្មនោះក៏មិនបានដែរ តែព្រះអង្គបានបន្សល់ទុកនូវវត្ថុដែលយើងត្រូវធ្វើសក្ការៈបូជាមានព្រះធម៌ ៨៤,០០០ ពាន់ព្រះធម្មក្ខន្ធ ទីកន្លែងដែលព្រះអង្គធ្លាប់ស្តេចយាងទៅ ព្រមទាំងទីកន្លែងដែលព្រះអង្គប្រសូតជាដើម ។ ពិតមែនតែព្រះអង្គរំលត់ខន្ធចូលបរិនិព្វានទៅហើយ តែបើកុលបុត្រដែលជាអ្នកសទ្ធា បានធ្វើសក្ការៈបូជាព្រះអង្គ ដោយការឧទ្ទិសថ្វាយនឹករលឹកទៅដល់ព្រះគុណរបស់ព្រះអង្គ មានព្រះ**បញ្ញាគុណ ព្រះវិសុទ្ធិគុណ** និង**ព្រះករុណា**គុណជាដើមនោះ ផលដ៏បរិបូណ៌ដែលជាបុណ្យកុសល រមែងសម្រេចដល់បុគ្គលនោះយ៉ាងពិតប្រាកដ បុគ្គលនោះរមែងជួបប្រទះតែសិរីសួស្តី សេចក្តីសុខរហូតដល់បានសម្រេចនូវបរមត្ថប្រយោជន៍គឺព្រះនិព្វាន ។

# មហាបរិនិព្វានសូត្រ

*នៅក្នុងបិដកលេខ ១៦, ទំព័រ ២៩៤ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឆ្លើយសំនួរព្រះអានន្ទ ដោយមានសេចក្តីថា ៖*

*ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ពួកភិក្ខុនៅចាំវស្សាក្នុងទិសទាំងឡាយ រួចហើយតែងមកដើម្បីគាល់ព្រះតថាគត យើងខ្ញុំព្រះអង្គតែងបានជួបនឹងពួកភិក្ខុអ្នកចម្រើនដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចម្រើន លុះអំណើតអំពីព្រះមានព្រះភាគទៅ យើងខ្ញុំនឹងលែងបានជួប លែងបានចូលទៅអង្គុយជិតពួកភិក្ខុអ្នកចម្រើន ដោយចិត្តហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សំវេគនីយដ្ឋាន ( ទីដែលគួរកើតសង្វេគ )ដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធានេះ៤កន្លែង ។* ***សំវេគនីយដ្ឋាន៤កន្លែង តើដូចម្តេច ។***

**១.** *ម្នាលអានន្ទ* ***សំវេគនីយដ្ឋានដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធា*** *ដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះ ដូច្នេះ ១ ។*

៦. ម្នាលអានន្ទ សំវេគនីយដ្ឋានដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណក្នុងទីនេះ ដូច្នេះ ១ ។

៦. ម្នាលអានន្ទ សំវេគនីយដ្ឋានដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគតបានសម្ដែងនូវអនុត្តធម្មចក្កក្នុងទីនេះ ដូច្នេះ ១ ។

៦. ម្នាលអានន្ទ សំវេគនីយដ្ឋានដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះ ដូច្នេះ១ ។

ម្នាលអានន្ទ នេះឯង សំវេគនីយដ្ឋានដែលគួរឃើញ ៤ កន្លែង របស់កុលបុត្រអ្នកមានសទ្ធា នឹងមកដោយរឭកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតត្រាស់ដឹងនូវអនុត្តរធម្មចក្កក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតបរិនិព្វានដោយអនុ-បាទិសេសនិព្វានធាតុក្នុងទីនេះ ដូច្នេះក្តី ម្នាលអានន្ទ ពួកជនណាមួយ នឹងបានដើរមកកាន់ទីចារិកនៃចេតិយក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅ ពួកជនទាំងនោះ លុះមានរាងកាយ

បែកធ្លាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្ស សុគតិ នឹងឋានសួគ៌ ។

## ការដល់សរណគមន៍

ដើម្បីភាពជាអ្នកឆ្លាតក្នុងសរណគមន៍ទាំងនោះ ឥឡូវនេះគប្បីជ្រាបវិធីនេះថា សរណៈ សរណគមន៍ អ្នកដែលចូលដល់សរណៈ ប្រភេទនៃសរណគមន៍ ផលនៃសរណគមន៍ សេចក្តីសៅហ្មងនិងការបែកធ្លាយ, តើសេចក្តីនេះយ៉ាងណា ?

**នឹងពង្រីកសេចក្តីដោយអត្ថនៃបទមុន ។**

ឈ្មោះថា **សរណៈ** ព្រោះអត្ថថាបៀតបៀន អធិប្បាយថាសម្លាប់ បៀតបៀនធ្វើឱ្យវិនាសដែលសេចក្តីខ្លាចសេចក្តីតក់ស្លុតសេចក្តីទុក្ខ ទុគ្គតិ សេចក្តីសៅហ្មងគ្រប់ផ្នែក ដោយការចូលដល់សរណៈនោះឯង ។

ពាក្យថា**សរណៈនេះ** ជាឈ្មោះរបស់ព្រះរតនត្រ័យទុំះឯង ។

ម្យ៉ាងទៀត ឈ្មោះថា **ពុទ្ធៈ** ព្រោះអត្ថថា កម្ចាត់ភ័យរបស់សត្វទាំងឡាយ ជាហេតុឱ្យដំណើរទៅក្នុងវត្ថុដែលជាប្រយោជន៍ និងឱ្យបែរត្រឡប់អំពីវត្ថុដែលមិនជាប្រយោជន៍ ។

ឈ្មោះថា **ធម៌** ព្រោះអត្ថថា កម្ចាត់ភ័យរបស់សត្វទាំងឡាយ ហេតុឱ្យឆ្លងកន្តារគឺ ភពបាន និងឱ្យសេចក្តីក្សេមក្សាន្តវិភាគ ។

ឈ្មោះថា **សង្ឃ** ព្រោះអត្ថថា កម្ចាត់ភ័យរបស់សត្វទាំងឡាយ ហេតុធ្វើវត្ថុដែលធ្វើសូម្បីតិចឱ្យបានផលបរិបូណ៌ ។

ព្រោះដូច្នោះ ព្រះរតនត្រ័យទើបឈ្មោះថា ជាសរណៈ ដោយបរិយាយនេះ ។

ចិត្តុប្បាទដែលដំណើរទៅ ដោយអាការមានព្រះរតនត្រ័យនោះជាខាងមុខមានកិលេសដែលសេចក្តីជ្រះថ្លា និងសេចក្តីគោរពក្នុងព្រះរតនត្រ័យនោះកម្ចាត់ហើយ ឈ្មោះថា *សរណគមន៍* ។

សត្វអ្នកមានព្រះរតនត្រ័យនោះដល់ព្រមហើយ រមែងដល់សរណៈ អធិប្បាយថា រមែងចូលដល់យ៉ាងនេះថា "រតនៈទាំង ៣ នេះជាទីពឹងរបស់យើង ទាំងនេះជាទីរាប់អានរបស់យើង" ដូច្នេះ ដោយចិត្តុប្បាទមានប្រការដូចពោលហើយ ។ គប្បីជ្រាប ៣ យ៉ាងនេះ គឺសរណៈ ១ សរណគមន៍ ១ និងអ្នកចូលដល់សរណៈ ១ ប៉ុណ្ណោះជាមុន ។

ក៏ក្នុងប្រភេទនៃសរណគមន៍ មានវិនិច្ឆ័យដូចតទៅនេះ ៖

**សរណគមន៍មាន ២ យ៉ាង** គឺ លោកុត្តរសរណគមន៍ និងលោកិយសរណគមន៍ ។

៤. បណ្ដា ២ យ៉ាងនោះ លោកុត្តរសរណគមន៍ ពោលអំពីអារម្មណ៍មាននិព្វានជាអារម្មណ៍ រមែងសម្រេចដោយកាត់ផ្ដាច់ឧបក្កិលេសរបស់សរណគមន៍ ក្នុងមគ្គខណៈនៃព្រះអរិយបុគ្គលអ្នកឃើញសច្ចៈហើយ ពោលដោយកិច្ច រមែងសម្រេចក្នុងព្រះរតនត្រ័យទាំងអស់ ។ លោកិយសរណគមន៍ពោលអំពីអារម្មណ៍មានព្រះពុទ្ធគុណជាដើមជាអារម្មណ៍ រមែងសម្រេចដោយការគ្របសង្កត់ឧបក្កិលេសរបស់សរណគមន៍របស់បុថុជ្ជនទាំងឡាយ ។ លោកិយសរណគមន៍នោះពោលដោយអត្ថ បានដល់ ការបានចំពោះនូវសទ្ធាក្នុងវត្ថុទាំងឡាយ មានព្រះពុទ្ធជាដើមនិងសម្មាទិដ្ឋិដែលមានសទ្ធាជាមូល ដែលលោកហៅថា ទិដ្ឋុជុកម្ម ក្នុងបុញ្ញកិរិយាវត្ថុ ១០ ។

**លោកិយសរណគមន៍នេះចែកជា ៤ យ៉ាង** គឺ ដោយប្រគល់កាយថ្វាយជីវិត ១ ដោយមានព្រះរតនត្រ័យនោះជាខាងមុខ ១ ដោយប្រគល់ខ្លួនជាសិស្ស ១ ដោយការនមស្ការ ១ ។

៦. បណ្ដា ៤ យ៉ាងនោះ ដែលឈ្មោះថា **ប្រគល់កាយថ្វាយជីវិត** បានដល់ការលះបង់ខ្លួនដល់ព្រះពុទ្ធជាដើមយ៉ាងនេះថា "តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំសូមប្រគល់ខ្លួនចំពោះព្រះពុទ្ធ ចំពោះព្រះធម៌ ចំពោះព្រះសង្ឃ" ។

៦. ដែលឈ្មោះថា **មានព្រះរតនត្រ័យនោះជាខាងមុខ** បានដល់ភាពជាអ្នកមានព្រះរតនត្រ័យជាខាងមុខយ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយមេត្តាចាំទុកថា ខ្ញុំជាអ្នកមានព្រះពុទ្ធ មានព្រះធម៌និងមានព្រះសង្ឃជាទីទៅក្នុងខាងមុខ ។

៦. ដែលឈ្មោះថា **ប្រគល់ខ្លួនជាសិស្ស** បានដល់ ចូលដល់ភាពជាសិស្សយ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយមេត្តាចាំទុកថា ខ្ញុំជាអន្តេវាសិករបស់ព្រះពុទ្ធរបស់ព្រះធម៌ របស់ព្រះសង្ឃ' ។

៦. ដែលឈ្មោះថា **ការនមស្សការ** បានដល់ ការគោរពយ៉ាងក្រៃលែងក្នុងព្រះពុទ្ធជាដើមយ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយ មេត្តាចាំទុកថា ខ្ញុំនឹងធ្វើការក្រាបថ្វាយបង្គំ ការក្រោកទទួល អញ្ជលីកម្មសាមីចិកម្មចំពោះវត្ថុទាំង ៣ មាន

ព្រះពុទ្ធជាដើមប៉ុណ្ណោះ ។

✵. ក៏កាលធ្វើអាការ៤ យ៉ាងនេះសូម្បីណាមួយ រមែងជាការកាន់យកសរណៈហើយដោយពិត ។

ម្យ៉ាងទៀត **គប្បីជ្រាបការប្រគល់កាយថ្វាយជីវិតសូម្បីយ៉ាងនេះថា** ខ្ញុំលះបង់ខ្លួនចំពោះព្រះមានព្រះភាគ លះបង់ខ្លួនចំពោះព្រះធម៌ ចំពោះព្រះសង្ឃ ខ្ញុំលះបង់ជីវិត ខ្ញុំលះបង់ខ្លួន លះបង់ជីវិតពិតប្រាកដ ខ្ញុំដល់ព្រះពុទ្ធជាទីពឹងរហូតអស់ជីវិត ព្រះពុទ្ធជាទីពឹង ជាទីពួនសម្ងំពីភ័យ ជាទីការពារភ័យរបស់ខ្ញុំ ។

**ការប្រគល់ខ្លួនជាសិស្ស** គប្បីជ្រាបដូចការដល់សរណៈរបស់ព្រះមហាកស្សបៈសូម្បីយ៉ាងនេះថា អើហ្ន៎ ប្រសិនបើអាត្មាអញបានចួបនឹងបុគ្គលដែលជាគ្រូក៏សូមឱ្យចួបតែនឹងព្រះមានព្រះភាគ, អើហ្ន៎ ប្រសិនបើអាត្មាអញបានចួបនឹងបុគ្គលដែលត្រាស់ដឹងធម៌ ក៏សូមឱ្យចួបតែនឹងព្រះមានព្រះភាគ ។

**ការមានព្រះរតនត្រ័យនោះជាខាងមុខ** គប្បីជ្រាបដូចការដល់សរណៈរបស់អឡវកយក្ខជាដើមយ៉ាងនេះថា ខ្ញុំព្រះអង្គនឹងត្រាច់ទៅអំពីស្រុក កាន់ស្រុក អំពីបុរីកាន់បុរី សូមថ្វាយបង្គំនូវ

ព្រះសមុទ្ទ( នោះ )ផង នូវសភាពដ៏ល្អរបស់ព្រះធម៌ផង ។

**សេចក្ដីនមស្ការ** គប្បីជ្រាបសូម្បីយ៉ាងនេះថា គ្រានោះឯង ព្រហ្មាយុព្រាហ្មណ៍ក៏ក្រោកពីអាសនៈធ្វើនូវសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ក្រាបទៀបព្រះបាទានៃព្រះមានព្រះភាគដោយក្បាល ជប់ព្រះបាទានៃព្រះមានព្រះភាគដោយមាត់ផង ប្របាច់ដោយដៃផង បន្លឺឈ្មោះរបស់ខ្លួនថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថា ព្រហ្មាយុព្រាហ្មណ៍ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថា ព្រហ្មាយុព្រាហ្មណ៍ ៣ ដង ដូច្នេះ ។

ក៏ការនមស្ការនេះ មាន ៤ យ៉ាង គឺ ព្រោះជាញាតិ ១ ព្រោះខ្លាច ១ ព្រោះជាអាចារ្យ ១ និងព្រោះកាន់ថា ជាទក្ខិណេយ្យបុគ្គល ១ ។

បណ្ដា ៤ យ៉ាងនោះ ព្រោះនមស្ការថា ជាទក្ខិណេយ្យបុគ្គល បាត់ជាសរណគមន៍ ក្រៅពីនេះ មិនមែនជាការមស្ការ ។

ពិតមែន ព្រោះការរាប់អានព្រះរតនត្រ័យយ៉ាងប្រសើរនុ៎ះឯង បុគ្គលរមែងកាន់សរណៈបាននិងដាច់បាន ព្រោះដូច្នោះ អ្នកណាដែលជាសក្យៈក៏ដោយ កោលិយៈក៏ដោយ ថ្វាយបង្គំដោយ

គិតថា "ព្រះពុទ្ធជាញាតិរបស់យើង" ដូច្នេះ រមែងមិនជាការកាន់សរណៈឡើយ ឬអ្នកណាថ្វាយបង្គំដោយសេចក្ដីខ្លាចថា "ព្រះសមណគោតមជាអ្នកដែលព្រះរាជាទ្រង់បូជា មានអានុភាពច្រើន កាលយើងមិនថ្វាយបង្គំ នឹងគប្បីធ្វើសូម្បីសេចក្ដីវិនាសឱ្យ" ដូច្នេះ រមែងមិនជាការកាន់សរណៈឡើយ ឬអ្នកណារឭកដល់មន្ដអ្វី ៗ ដែលខ្លួនរៀនក្នុងសំណាក់របស់ព្រះមានព្រះភាគ ក្នុងកាលជាព្រះពោធិសត្វ ឬក្នុងកាលជាព្រះពុទ្ធ រៀនអនុសាសនីបែបនេះថា

**កុលបុត្រដែលចែកភោគៈទាំងឡាយជា ៤ ចំណែក គឺបរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារ ២ ចំណែក តាំងតម្កល់ទុកនូវចំណែកទី៤ដោយក្រែងមានអន្តរាយទាំងឡាយ[១] ដូច្នេះ ។**

ហើយថ្វាយបង្គំដោយគិតថា "អាចារ្យរបស់យើង" ដូច្នេះ មិនជាការកាន់សរណៈឡើយ ។ តែអ្នកណាថ្វាយបង្គំដោយគិតថា "លោកនេះជាទក្ខិណេយ្យបុគ្គលប្រសើរក្នុងលោក" ដូច្នេះ អ្នកនោះឯងបានកាន់សរណៈហើយ ។

ក៏កាលឧបាសក ឬ ឧបាសិកាអ្នកកាន់សរណៈយ៉ាងនេះ

ហើយ លុះថ្វាយបង្គំញាតិសូម្បីបួសក្នុងអន្យតិរ្ថិយ ដោយគិតថា "អ្នកនេះជាញាតិរបស់យើង" ដូច្នេះ រមែងមិនដាច់សរណគមន៍ មិនចាំបាច់ត្រូវពោលដល់អ្នកដែលមិនបានបួស ។ អ្នកថ្វាយបង្គំព្រះរាជាដោយសេចក្ដីខ្លាចក៏ដូចគ្នា ព្រោះព្រះរាជានោះ កាលអ្នកណាមិនថ្វាយបង្គំ នឹងគប្បីធ្វើសូម្បីសេចក្ដីវិនាសឱ្យក៏បាន ព្រោះជាអ្នកដែលរដ្ឋបូជាហើយ ដូច្នេះ ។ សូម្បីថ្វាយបង្គំតិរ្ថិយអ្នកទូន្មានសិល្បៈណាមួយ ដោយពាក្យថា "អ្នកនេះ ជាអាចារ្យរបស់យើង" ដូច្នេះ ក៏មិនដាច់សរណគមន៍ ។ គប្បីជ្រាបប្រភេទនៃសរណគមន៍ ដោយប្រការដូច្នេះ ។

ក៏ក្នុងទីនេះ សរណគមន៍ដែលជាលោកុត្តរៈ មានសាមញ្ញផល ៤ ជាវិបាកផលមានសេចក្ដីអស់ទៅនៃទុក្ខទាំងពួង ជាអានិសង្សផល ។ សមដូចដែលពោលទុកថា ៖

"លុះតែបុគ្គលណាយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ចៈ ១ ទុក្ខសមុទយសច្ចៈ ១ និរោធសច្ចកន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះ

ឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចផុតចាកទុក្ខទាំងពួងបាន"១ ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបអានិសង្សផលនៃសរណគមន៍នេះ សូម្បីដោយការដែលគេមិនចូលដល់ភាវៈ មាននិច្ចសញ្ញាជាដើម សមដូចដែលពោលទុកថា ៖

"ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គឺសោតាបន្នៈគប្បីប្រកាន់នូវសង្ខារណាមួយ ថាជាវត្ថុទៀង, ប្រកាន់នូវសង្ខារណាមួយ ថាជាសុខ, ប្រកាន់នូវសង្ខារណាមួយ ថាជាខ្លួន,គប្បីផ្តាច់បង់ជីវិតមាតា,គប្បីផ្តាច់បង់ជីវិតបិតា, គប្បីផ្តាច់បង់ជីវិតព្រះអរហន្ត, មានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតឱ្យពុះពង,បំបែកសង្ឃ,ឧទ្ទិសខ្លួនចំពោះគ្រូដទៃ, ដោយហេតុណាហេតុនុ៎ះ មិនមែនហេតុ មិនមែនជាបច្ច័យឡើយ គឺថា ហេតុនុ៎ះមិនដែលមានឡើយ ។"

ក៏សរណគមន៍ដែលជាលោកិយៈមានភវសម្បត្តិខ្លះ ភោគ-សម្បត្តិខ្លះ ជាផលពិតប្រាកដ ។ សមដូចដែលពោលទុកថា ៖

**"ជនទាំងឡាយណាមួយបានដល់នូវព្រះពុទ្ធ ជាទីរឭក ជនទាំងនោះនឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយ**

ជារបស់មនុស្សហើយ នឹងទៅកើតក្នុងពួកនៃទេវតាមិនខាន”១ ដូច្នេះ ។

សម្បីផលយ៉ាងដទៃរបស់សរណគមន៍ដែលជាលោកិយៈ លោកក៏ពោលទុកថា “គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨ ម៉ឺនអង្គ ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះសក្កទេវានមិន្ទ ឋិតនៅក្នុងទីដ៏សមគួរហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយដូច្នេះថា ‘បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វដទៃដោយឋានៈទាំង ១០ យ៉ាង គឺអាយុជាទិព្វ ១ ពណ៌សម្បុជាទិព្វ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ (រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ដូច្នេះ) ។

ម្យ៉ាងទៀត គប្បីជ្រាបផលវិសេសនៃសរណគមន៍ សូម្បីដោយអំណាចវេលាមសូត្រជាដើម ។ គប្បីជ្រាបផលនៃសរណគមន៍យ៉ាងនេះ ។

ក្នុងសរណគមន៍ទាំងលោកិយៈនិងលោកុត្តរៈនោះសរណគមន៍ដែលជាលោកិយៈ រមែងសៅហ្មងដោយសេចក្ដីមិនដឹង សេចក្ដីសង្ស័យ និងសេចក្ដីយល់ខុសក្នុងព្រះរតនត្រ័យជាដើម មិនរុងរឿងច្រើនទៅបាន មិនបែកស្ទែកធំទូលាយទៅបាន ។

សរណគមន៍ដែលជាលោកុត្តរៈមិនមានសេចក្ដីសៅហ្មង ។

មួយទៀត សរណគមន៍ដែលជាលោកិយៈមាន ២ ប្រភេទ គឺ ដែលមានទោស ១ ដែលមិនមានទោស ១ ។

ក្នុង ២ យ៉ាងនោះដែលមានទោស រមែងមានបានដោយហេតុជាដើមថា ប្រគល់ខ្លួនក្នុងសាស្ដាដទៃជាដើម ។ សរណគមន៍ដែលមានទោសនោះ មានផលមិនគួរប្រាថ្នា ។ សរណគមន៍ដែលមិនមានទោស រមែងមានដោយកាលកិរិយា ។ សរណគមន៍ដែលមិនមានទោសនោះ មិនមានផល ព្រោះមិនជាវិបាក ។

ចំណែកសរណគមន៍ដែលជាលោកុត្តរៈ មិនប្លែកឆ្ងាយ

ឡើយ ។ ព្រោះព្រះអរិយសាវកមិនឧទ្ទិសចំពោះសាស្តាដទៃ សូម្បីក្នុងភព ។ គប្បីជ្រាបសេចក្តីសៅហ្មងនិងការបែកធ្លាយនៃសរណគមន៍ ដោយប្រការដូច្នេះ ។

## គោលបំណងនៃការបូជា

ក៏ឈ្មោះថា ការបូជាក្នុងបូជនេយ្យបុគ្គលទាំងឡាយ មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវក សាវិកានិងបុគ្គលទាំងឡាយដែលជាសប្បុរស និងបុគ្គលទាំងឡាយដែលជាអ្នកគួរដល់ការបូជាទាំងអស់ សូម្បីតែទេយ្យធម៌តិចតួច ក៏រមែងនាំប្រយោជន៍សុខមកប្រគល់ឱ្យអស់កាលដ៏យូរអង្វែង ។ គោលបំណងនៃការបូជារបស់មនុស្សទាំងឡាយ នៅក្នុងលោកនេះគឺសុទ្ធតែជាអ្នកប្រាថ្នានូវសេចក្តីសុខចំរើននៅក្នុងជីវិតទាំងអស់ តួយ៉ាងដូចជា [**ស្តេចសក្កទេវរាជសម្តែងធម៌ដល់ពួកទេព្តា**] ស្តេចសក្កទេវរាជទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ កាលនឹងសម្តែងធម៌ដល់ពពួកទេវតា មានមាតលិទេវបុត្រជាប្រធាន ទើបទ្រង់ពោលនូវគាថាទាំងឡាយនេះថា ៖

**ម្នាលមាតលិអ្នកចូរមើលនូវសេចក្តីអស្ចារ្យនេះជាផល**

នៃកម្មដ៏វិចិត្រ ទោះបីជាមិនសូម្បីតែបន្តិចបន្តួចដែលបុគ្គលបានធ្វើហើយ បុណ្យត្រឡប់ទៅជាមានផលច្រើន កាលបើចិត្តជ្រះថ្លាហើយ ចំពោះព្រះតថាគត ជាព្រះសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ឬសាវករបស់ព្រះតថាគតនោះ ទក្ខិណាទានឈ្មោះថា មានផលតិចតួចមិនមានសោះឡើយ ម្នាលមាតលិ អ្នកចូរមកចុះ សូម្បីយើងទាំងឡាយក៏នឹងបូជាព្រះធាតុរបស់ព្រះតថាគត ឱ្យលើសលុជាងនេះទៅទៀត ការសន្សំនូវបុណ្យទាំងឡាយ ជាហេតុនាំមកនូវសេចក្តីសុខ សូម្បីកាលព្រះមានព្រះភាគទ្រង់ឋិតនៅក្តី បរិនិព្វានទៅហើយក្តី បើតាំងចិត្តស្មើ ផលក៏មានស្មើ ដ្បិតថា សត្វទាំងឡាយអ្នកមានការតម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជាចំពោះព្រះតថាគតទាំងឡាយណា ព្រះតថាគតទាំងឡាយនោះទ្រង់កើតឡើងក្នុងលោកដើម្បីប្រយោជន៍ដល់ជនច្រើនហ្ន៎ ។

កាលសក្កទេវរាជ លុះទ្រង់ត្រាស់សម្តែងយ៉ាងដូច្នេះហើយ ទ្រង់រម្ងាប់នូវព្រះឧស្សាហ៍ ក្នុងការស្តេចយាងទៅប្រពាតក្នុងព្រះឧទ្យាន ស្តេចយាងត្រឡប់អំពីទីនោះឯងហើយ ទ្រង់ធ្វើការបូជាក្នុងព្រះចូឡាមណីចេតិយរហូតមួយសប្តាហ៍ ក្នុងកាលក្រោយមក

ទ្រង់បានត្រាស់នូវរឿងរ៉ាវនោះដល់ព្រះនារទត្ថេរដ៏មានអាយុ ដែលកំពុងតែត្រាច់ទៅកាន់ទីចារិក ក្នុងទេវលោកដោយគាថាទាំងឡាយនេះ ។ ក្នុងពេលដែលធ្វើបឋមសង្គាយនា ព្រះថេរៈបានសម្តែងប្រាប់ហើយ ដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ។ ព្រះថេរៈទាំងឡាយ បានលើកយកពាក្យនោះឡើង កាន់សង្គាយនាហើយ យ៉ាង ដូច្នោះឯង ។

**ពុទ្ធបូជា** រមែងនាំមកនូវប្រយោជន៍សុខ អស់កាលដ៏យូរអង្វែង ដូចបានពណ៌នាមកហើយនេះឯង ។

ម្យ៉ាងទៀត គោលបំណងនៃការបូជាគ្រប់យ៉ាង សុទ្ធតែប្រាថ្នាចង់បានសេចក្តីសុខ ចង់បានសិរីមង្គលនៅក្នុងវិថីនៃជីវិតទាំងអស់ ។ បុគ្គលណាបូជាលើកតម្កើងធ្វើសេចក្តីគោរពបុគ្គលដែលគួរគោរពបូជា បុគ្គលនោះលុះស្លាប់ទៅរមែងឡើងស្ថានសួគ៌ដូចជាគេនាំយកទៅដាក់ ។

## **ខណ្ណសូត្រ**

នៅក្នុងបិដលលេខ ៤២, ទំព័រ ២០៧ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**ធម៌ដែល**

**នាំឱ្យកើតក្នុងនរកនិងសួគ៌** ) មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ **ប្រកបដោយធម៌ ៤ យ៉ាង** តើដូចម្តេចខ្លះ ។

**១- អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ** គឺបុគ្គលមិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយ ពោលសរសើរបុគ្គលដែលគួរតិះដៀល ។

**២- អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ** មិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយ ពោលតិះដៀលបុគ្គលដែលគួរសរសើរ ។

**៣- អននុវិច្ច អបរិយោគាហេត្វា អប្បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ** មិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយ បណ្តុះសេចក្តីជ្រះថ្លាក្នុងទីដែលមិនគួរជ្រះថ្លា ។

**៤- អននុវិច្ច អបរិយោគាហេត្វា បសាទនីយេ ឋានេ**

បសាទំ ឧបធំសេតិ មិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយបណ្ដុះសេចក្ដីមិនជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងធ្លាក់ប្រុងទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌៤យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ **ប្រកបដោយធម៌ ៤ យ៉ាង** តើដូចម្ដេចខ្លះ ។

១- អនុវិច្ច បរិវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ បុគ្គលបានពិនិត្យមើល បានស្ទង់មើលរួចហើយ ទើបពោលទោសចំពោះបុគ្គលដែលប្រកបដោយទោស ។

២- អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភសតិ បានពិនិត្យមើល បានស្ទង់មើលរួចហើយ ទើបពោលគុណចំពោះបុគ្គលដែលប្រកបដោយគុណ ។

៣- អនុវិច្ច បរិយោគាហេត្វា អប្បសាទនីយេ ឋានេ អប្បសាទំ ឧបធំសេតិ បានពិនិត្យមើល បានស្ទង់មើល រួច

ហើយ ទើបបណ្ដុះសេចក្ដីមិនជ្រះថ្លាក្នុងទីដែលមិនគួរជ្រះថ្លា ។

**៤- អនុវិច្ច បរិយោគាហេត្វា បសាទនីយេ ឋានេ** បសាទំ ឧបទំសេតិ បានពិនិត្យមើល បានស្ទង់មើលរួចហើយ ទើបបណ្ដុះ សេចក្ដីជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះតែងទៅកើតក្នុងឋានសួគ៌ដូចជាគេនាំយកទៅដាក់ ។

## ឧជ្ជយសូត្រ

នៅក្នុងបិដកលេខ៤២,ទំព័រ១០១ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**ឧជ្ជយព្រាហ្មណ៍ទូលសួរបញ្ហា**] មានសេចក្ដីថា ៖

គ្រានោះ ឧជ្ជយព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧជ្ជយព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា ព្រះគោតមដ៏ចំរើន សរសើរការបូជារបស់យើងដែរឬទេ ។

ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាទាំងអស់ទេ ម្នាលព្រាហ្មណ៍ តែតថាគតមិនមែនជាសរសើរ ការបូជាទាំងអស់ទេ ។ ម្នាលព្រាហ្មណ៍ គេសម្លាប់គោទាំងឡាយ សម្លាប់ពពែនឹងចៀមទាំងឡាយ សម្លាប់មាន់នឹងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេង ៗ ក៏ដល់នូវសេចក្តីស្លាប់ ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរ ការបូជាប្រកបដោយសេចក្តីអន្តរាយយ៉ាងនោះឡើយ ។ ដំណើររនោះព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថាព្រះអរហន្តទាំងឡាយក្តីបុគ្គលទាំងឡាយអ្នកដល់នូវអរហន្តមគ្គក្តី មិនដើរទៅជិតការបូជាប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះឡើយ ។ ម្នាលព្រាហ្មណ៍ គេមិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែនឹងចៀមទាំងឡាយ មិនសម្លាប់មាន់ នឹងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេង ៗ ក៏មិនស្លាប់ ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគត តែងសរសើរការបូជាដែលមិនប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះ គឺនិច្ចទាន នឹងការបូជាតាមលំអានត្រកូល ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះ

ថា ព្រះអរហន្តទាំងឡាយក្តី បុគ្គលទាំងឡាយអ្នកដល់នូវអរហន្ត-មគ្គក្តី តែងពេញចិត្តការបូជាដែលមិនប្រកបដោយសេចក្តីអន្តរាយមានសភាព យ៉ាងនេះ ។

**ការបូជាធំ** មានកិច្ចដែលត្រូវធ្វើច្រើន គឺការសម្លាប់សេះ សម្លាប់បុរស ការទុកដាក់មនុស្សដោយប្រពៃ ការពោលពាក្យជាទីស្រឡាញ់ ផ្ទះមិនបាច់មានគន្លឹះទ្វារ ការបូជាធំទាំងនោះ មិនមានផលឡើយ គេសម្លាប់ពពែនឹងចៀមក្តី គោទាំងឡាយក្តី ពួកសត្វផ្សេង ៗក្តី ព្រោះការបូជាណា ពួកបុគ្គលអ្នកដល់នូវអរហត្តមគ្គ នឹងបុគ្គលអ្នកស្វែងរកនូវគុណដ៏ធំ (ព្រោះអរហន្ត) តែងមិននិយមនូវការបូជានោះទេ ។ ពួកជនបូជាសព្វកាលនូវយញ្ញណា ដែលមិនប្រកបដោយសេចក្តីអន្តរាយតាមលំអាននៃត្រកូលក្តី គេមិនសម្លាប់ពួកពពែនឹងចៀម ឬពួកគោ ឬក៏ពួកសត្វផ្សេង ៗ ព្រោះការបូជាណាក្តី ពួកបុគ្គលអ្នកដល់នូវអរហត្តមគ្គនឹងបុគ្គលអ្នកស្វែងរកនូវគុណដ៏ធំ (ព្រោះអរហន្ត) ទើបពេញចិត្តការបូជានោះ ៗ ។ អ្នកប្រាជ្ញត្រូវបូជាយ៉ាងនេះ ការបូជានុ៎ះមានផលច្រើន ។ ក៏កាលបុគ្គលបូជាយ៉ាងនេះ ទើបប្រសើរមិនមានបាប ការបូជាឈ្មោះថាមានផលច្រើនផង ទេវតាទាំងឡាយ តែងជ្រះថ្លាផង ។

## រឿងព្រាហ្មណ៍អ្នកជាអ៊ំរបស់ព្រះសារីបុត្តត្ថេរ

ព្រះសាស្ដាកាលប្រថាប់នៅក្នុងព្រះវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកជាអ៊ំរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា "មាសេ មាសេ" ជាដើម ។

### [ព្រះថេរៈចូលទៅគាល់ព្រះសាស្ដា]

បានឮថា ព្រះថេរៈ ទៅកាន់សំណាក់របស់ព្រាហ្មណ៍នោះ ហើយ សួរថា "ព្រាហ្មណ៍ លោកធ្វើកុសលអ្វី ៗ ខ្លះឬហ្ន៎ ។

ព្រាហ្មណ៍. ធ្វើករុណា ។

ព្រះថេរៈ. ធ្វើកុសលអ្វី

ព្រាហ្មណ៍. សក់ក៏ឱ្យទាន ដោយបរិច្ចាគទ្រព្យមួយពាន់គ្រប់ ៗ ខែ ។

ព្រះថេរៈ. ឱ្យដល់អ្នកណា ?

ព្រាហ្មណ៍. ឱ្យដល់ខ្ញុំព្រះករុណា ។

ព្រះថេរៈ. ប្រាថ្នាអ្វី ?

ព្រាហ្មណ៍. ព្រហ្មលោក ករុណា ។

ព្រះថេរៈ. ក៏នេះជាផ្លូវនៃព្រហ្មលោកឬ ?

ព្រាហ្មណ៍. យ៉ាងនោះ ករុណា ។

ព្រះថេរ:. អ្នកណាពោលយ៉ាងនេះ ?

ព្រាហ្មណ៍. ពួកអាចារ្យរបស់ខ្ញុំពោល ករុណា ។

ព្រះថេរៈពោលថា លោកអ្នកមិនដឹងផ្លូវនៃព្រហ្មលោកតែម្តង សូម្បីពួកអាចារ្យរបស់លោកក៏មិនដឹង ព្រះសាស្តាព្រះអង្គតែមួយប៉ុណ្ណោះទ្រង់ដឹង មកចុះព្រាហ្មណ៍ ខ្ញុំនឹងទូលអារាធនាឱ្យព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់លោក ដូច្នេះហើយ នាំព្រាហ្មណ៍នោះ នាំទៅកាន់សំណាក់របស់ព្រះសាស្តា ក្រាបទូលរឿងនោះថា ព្រាហ្មណ៍នេះ ពោលយ៉ាងនេះព្រះអង្គ ហើយក្រាបទូលថា សូមព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់ព្រាហ្មណ៍នោះ ។

## [ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសព្រាហ្មណ៍]

ព្រះសាស្តាត្រាស់សួរថា បានឮថា យ៉ាងនោះឬ ? កាលព្រាហ្មណ៍នោះទូលថា យ៉ាងនោះ ព្រះគោតមដ៏ចម្រើន ទើបត្រាស់ថា ព្រាហ្មណ៍ ការក្រឡេកមើលសាវករបស់យើងដោយចិត្តដែលជ្រះថ្លាត្រឹមតែមួយភ្លេត ឬការថ្វាយអាហារវត្ថុត្រឹមតែភិក្ខាមួយ

វែក មានផលច្រើនជាងទានដែលលោកឱ្យយ៉ាងនោះ ហើយឱ្យអស់ ១០០ ឆ្នាំ" កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

មាសេ មាសេ សហស្សេន យោ យជេថ សតំ
សមំ ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

អ្នកណាបូជា ( លោកិយមហាជន ) ដោយទ្រព្យមួយពាន់រាល់ខែ ៗអស់ ១ រយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយតែម្នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់អ្នកដែលបូជាអស់ ១ រយឆ្នាំនោះ ការបូជាអស់ ១ រយឆ្នាំនោះ មិនប្រសើរឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា សហស្សេន សេចក្តីថា ដោយការបរិច្ចាគទ្រព្យមួយពាន់ ។

បាទគាថាថា យោ យជេថ សតំ សមំ សេចក្តីថា អ្នក

ណាកាលបរិច្ចាគទ្រព្យមួយពាន់រាល់ ៗខែ ឱ្យទានដល់លោកិយ៍មហាជន អស់ ១០០ ឆ្នាំ ។

បាទគាថាថា ឯកញ្ច ភាវិតត្តានំ សេចក្តីថា ចំណែកបុគ្គលណាគប្បីបូជាអ្នកដែលមានខ្លួនអប់រំហើយ ដោយអំណាចនៃគុណមានសីលគុណជាដើមថ្នាក់ទាបត្រឹមព្រះសោតាបន្ន ថ្នាក់ខ្ពស់ជាព្រះអរហន្ត ដែលមកឈរទៀបទ្វារផ្ទះដោយអំណាចការប្រគេនភិក្ខាមួយវែក ដោយអំណាចការប្រគេនអាហារល្មមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅបាន ឬដោយត្រឹមតែថ្វាយសំពត់ដែលមានសាច់គ្រោតគ្រាត, ការបូជារបស់អ្នកនោះប្រសើរ គឺល្អឯកបានដល់ ខ្ពង់ខ្ពស់ជាងការបូជាដែល បុគ្គលក្រៅនេះបូជាហើយអស់ ១០០ ឆ្នាំ ។

ក្នុងវេលាចប់ធម៌ទេសនា ព្រាហ្មណ៍នោះបានសម្រេចសោតាបត្តិផល, សូម្បីជនដទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

## រឿងព្រាហ្មណ៍អ្នកជាក្មួយរបស់ព្រះសារីបុត្រ

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធក្មួយរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា "យោ ច វស្សសតំ ជន្តុ"ជាដើម ។

### [ព្រះថេរៈនាំក្មួយទៅគាល់ព្រះសាស្ដា]

សេចក្ដីពិស្ដារថា ព្រះថេរៈចូលទៅរកក្មួយសូម្បីនោះហើយសួរថា "ព្រាហ្មណ៍ លោកធ្វើកុសលឬ ?"

ព្រាហ្មណ៍. យ៉ាងនោះករុណា

ព្រះថេរៈ. ធ្វើកុសលអ្វី ?

ព្រាហ្មណ៍. សម្លាប់សត្វចិញ្ចឹមមួយក្បាល ហើយបម្រើភ្លើងគ្រប់ ៗ ខែ ។

ព្រះថេរៈ. ធ្វើយ៉ាងនោះ ដើម្បីអ្វី ?

ព្រាហ្មណ៍. គេថា នោះជាផ្លូវនៃព្រហ្មលោក ។

ព្រះថេរៈ. អ្នកណា ថាយ៉ាងនោះ ?

ព្រាហ្មណ៍. ពួកអាចារ្យរបស់ខ្ញុំករុណា ។

ព្រះថេរៈពោលថា លោកមិនដឹងផ្លូវនៃព្រហ្មលោកឡើយ សូម្បីពួកអាចារ្យរបស់លោកក៏មិនដឹង ។ មកចុះ យើងនឹងទៅសំណាក់របស់ព្រះសាស្តាដូច្នេះហើយនាំក្មួយនោះទៅកាន់សម្នាក់របស់ព្រះសាស្តា ទូលរឿងនោះហើយ ក្រាបទូលថា ព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់ផ្លូវទៅកាន់ព្រហ្មលោកដល់ព្រាហ្មណ៍នេះ” ។

(ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសព្រាហ្មណ៍)

ព្រះសាស្តាត្រាស់សួរថា បានឮថា យ៉ាងនោះឬ ? កាលព្រាហ្មណ៍នោះទូលថា យ៉ាងនោះ ព្រះគោតមដ៏ចម្រើន ទើបត្រាស់ថា ព្រាហ្មណ៍ការបម្រើភ្លើងរបស់លោកអ្នកបម្រើភ្លើងយ៉ាងនោះអស់ ១០០ ឆ្នាំ រមែងមិនដល់សូម្បីការបូជាសាវ័ករបស់យើងត្រឹមតែខណៈតែមួយ កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

ជនណាបម្រើភ្លើងក្នុងព្រៃអស់ ១០០ ឆ្នាំ ចំណែកអ្នក

ណាបូជាលោក ដែលមានខ្លួនអប់រំហើយតែម្នាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

### អធិប្បាយគាថា

បណ្ដាបទទាំងនោះបទថា ជន្តុ នេះជាឈ្មោះរបស់សត្វ ។ បាទគាថាថា អគ្គឹ បរិចរេ វនេ សេចក្ដីថា សូម្បីចូលទៅកាន់ព្រៃដោយប្រាថ្នាភាពជាអ្នកមិនមានធម៌ ជាគ្រឿងយឹតយូរ គប្បីបម្រើភ្លើងក្នុងព្រៃនោះ ។

ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ក្នុងវេលាចប់ទេសនា ព្រាហ្មណ៍បានសម្រេចសោតាបត្តិ-ផល ជនដទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

## រឿងព្រាហ្មណ៍អ្នកជាសម្លាញ់របស់ព្រះសារីបុត្តត្ថេរ

ព្រះសាស្ដាកាលប្រថាប់នៅក្នុងព្រះវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកជាសម្លាញ់របស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា “យង្កិញ្ចិ យិដ្ឋំ វ” ជាដើម ។

[ព្រះថេរៈនាំព្រាហ្មណ៍ទៅគាល់ព្រះសាស្តា]

សេចក្តីពិស្តារថា ព្រះថេរៈចូលទៅរកព្រាហ្មណ៍សូម្បីនោះ ហើយសួរថា "ព្រាហ្មណ៍ លោកធ្វើបុណ្យកុសលខ្លះយ៉ាងឬ ?"

ព្រាហ្មណ៍. យ៉ាងនោះ ករុណា ។

ព្រះថេរៈ. ធ្វើកុសលអ្វី ?

ព្រាហ្មណ៍. បូជាយញ្ញដែលគេបូជា ។

បានឮថា គ្រានោះជនទាំងឡាយរមែងបូជាយញ្ញនោះដោយការបរិច្ចាគយ៉ាងច្រើន ។ ចំពោះសេចក្តីនេះ ព្រះថេរៈសួរដោយន័យមុននុ៎ះឯង ហើយនាំព្រាហ្មណ៍នោះទៅកាន់សំណាក់របស់ព្រះសាស្តាទូលរឿងនោះហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោក ដល់ព្រាហ្មណ៍នេះ ។

[ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសព្រាហ្មណ៍]

ព្រះសាស្តាត្រាស់សួរថា បានឮថាយ៉ាងនោះឬ ?ព្រាហ្មណ៍ កាលព្រាហ្មណ៍ទូលទទួលថា យ៉ាងនោះហើយ ទើបត្រាស់ថា ព្រាហ្មណ៍ ទានដែលលោកបូជាយញ្ញដែលគេធ្លាប់បូជា ឱ្យដល់លោកិយមហាជនអស់ឆ្នាំ រមែងមិនដល់សូម្បីត្រឹមតែចំណែកទី

៤ នៃកុសលចេតនាដែលកើតឡើងដល់អ្នកទាំងឡាយ អ្នកថ្វាយបង្គំសាវករបស់តថាគតដោយចិត្តដែលជ្រះថ្លា កាលនឹងទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

យង្កិញ្ចិ យិដ្ឋ វ ហុតំ វ លោកេ សំវច្ឆរំ យជេថ បុញ្ញបេក្ខោ

សព្វំបិ តំ ន ចតុភាគមេតិ អភិវាទនា ឧជុគតេសុ សេយ្យោ ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ចំពោះលោកទាំងឡាយដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា យង្កិញ្ចិ នេះ ជាពាក្យកំណត់ដែលមិនមានចំណែកសេសសល់ ។

បទថា យិដ្ឋំ បានដល់ ទានដែលគេឱ្យក្នុងថ្ងៃធ្វើវិធីមង្គល

ជាដើម ដោយច្រើន ។

បទថា ហុតំ បានដល់ ទានដើម្បីភ្ញៀវ ដែលគេចាត់ចែងធ្វើ និងទានដែលគេជឿកម្ម និងផលរបស់កម្មហើយធ្វើ ។

ពីរបទថា សំវច្ឆរំ យជេថ សេចក្តីថា គប្បីឱ្យទាន មានប្រការដូចពោលហើយ ដល់លោកិយមហាជន សូម្បីក្នុងចក្រវាឡទាំងអស់ រហូតដល់មួយឆ្នាំមិនមានចន្លោះ ។

បទថា បុញ្ញបេក្ខោ បានដល់ អ្នកប្រាថ្នាបុណ្យ ។

បទថា ឧជុគតេសុ សេចក្តីថា យ៉ាងទាបបំផុត ក្នុងព្រះសោតាបន្ន យ៉ាងខ្ពស់បំផុត, ក្នុងព្រះខីណាស្រព ។ ពាក្យនេះជាពាក្យដែលព្រះសាស្តាត្រាស់ទុកថា “ទាននោះទាំងអស់ មិនដល់ចំណែកទី ៤ នៃកុសលចេតនារបស់អ្នកបង្អោនសរីរៈថ្វាយបង្គំដោយចិត្តដែលជ្រះថ្លាបែបនោះ,ព្រោះដូច្នោះការអភិវាទន៍ចំពោះបុគ្គលអ្នកប្រព្រឹត្តត្រង់ប៉ុណ្ណោះ ជាការប្រសើរបំផុត” ។

ក្នុងវេលាចប់ទេសនា ព្រាហ្មណ៍សម្រេចសោតាបត្តិផល ជនដទៃជាច្រើន ក៏សម្រេចអរិយផលជាដើម ដូច្នេះឯង ៕

# រូបសូត្រ

នៅក្នុងបិដកលេខ ៤២, ទំព័រ ១៧៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**បុគ្គលជ្រះថ្លា ៤ ជំពូក**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ **បុគ្គល ៤ ពួកដូចម្តេចខ្លះ** ។

១- រូបប្បមាណោ រូបប្បសន្នោ បុគ្គលជ្រះថ្លាក្នុងរូប ឈ្មោះថារូបប្បមាណ ។

២- ឃោសប្បមាណោ ឃោសប្បសន្នោ ជ្រះថ្លាក្នុងសំឡេង ឈ្មោះថាឃោសប្បមាណោ ។

៣- លូខប្បមាណោ លូខប្បសន្នោ ជ្រះថ្លាក្នុងវត្ថុសៅហ្មង ឈ្មោះថាលូខប្បមាណ ។

៤- ធម្មប្បមាណោ ធម្មប្បសន្នោ ជ្រះថ្លាក្នុងធម៌ ឈ្មោះថា ធម្មប្បមាណ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គល៤ពួកនេះ រមែងមាននៅក្នុងលោក ។

យេ ច រូបេន បាវីសុ យេ ច ឃោសេន អនុគូ
ឆន្ទរាគវសូបេតា ឆាភិជានន្តិ តេ ជនា
អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច ន បស្សតិ
សមន្តាវរណោ ពាលោ សវេ ឃោសេន វុយ្ហតិ ។

ជនទាំងឡាយណាពប់អានដោយរូប និយមទៅតាមសំឡេង លុះក្នុងអំណាចនៃឆន្ទរាគ ជនទាំងនោះឈ្មោះថា មិនដឹង ( តាមដឹង ) បុគ្គលពាលអ្នកមានធម៌ជាគ្រឿងរាំងដោយជុំវិញ រមែងមិនដឹងនូវគុណខាងក្នុង ទាំងមិនឃើញសេចក្តីប្រតិបត្តិខាងក្រៅ បុគ្គលពាលនោះ រមែងអណ្តែត ( ចិត្ត ) ទៅតាមសំឡេង ។

អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច វិបស្សតិ
ពហិទ្ធា ផលទស្សាវី សោបិ ឃោសេន វុយ្ហតិ
អជ្ឈត្តញ្ច បជានាតិ ពហិទ្ធា ច វិបស្សតិ
ឯវំ វិនីវរណទស្សាវី ន សោ ឃោសេន វុយ្ហតិ ។

មួយទៀត បុគ្គលពាលនោះមិនដឹងនូវគុណខាងក្នុង តែឃើញច្បាស់នូវសេចក្តីប្រតិបត្តិខាងក្រៅ បុគ្គលពាលនោះ ឈ្មោះ

ថា ជាអ្នកឃើញផលខាងក្រៅជាប្រក្រតី រមែងអណ្តែត( ចិត្ត ) ទៅតាមសំឡេង ។ ឯជនដឹងច្បាស់នូវគុណខាងក្នុង ជននោះឈ្មោះថា ជាអ្នកឃើញធម៌ ជាគ្រឿងប្រាសចាកនូវនីវរណៈជាប្រក្រតី រមែងមិនអណ្តែត( ចិត្ត )ទៅតាមសំឡេងឡើយ ។

## រឿងនាក់នងនឹងបដិបត្តិបូជា

ដូចដែលបានបរិយាយពីខាងដើម ជាហូរហែរមកហើយថា ការបូជាដោយសេចក្តីគោរព ប្រតិបត្តិទៅតាមពាក្យរបស់ព្រះអង្គ ឈ្មោះថា **បដិបត្តិបូជា** ។ បដិបត្តិបូជារបស់បព្វជិត និងឧបាសក ឧបាសិកាមានលក្ខណៈខុសគ្នាគឺបព្វជិត អ្នកបូជាអាមិសមិនឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ឡើយ យ៉ាងណាមិញ,គ្រហស្ថមិនមែនជាអ្នកយ៉ាងដូច្នោះឡើយ ។ ព្រោះថា **គ្រហស្ថ** សូម្បីជាអ្នកបូជាដោយអាមិស ក៏ឈ្មោះថា ជាអធិការនៃការប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថាមហាបរិនិព្វានសូត្រ ទើបលោកពោលថា គ្រហស្ថអ្នកបូជាដោយអាមិសឈ្មោះថា រមែងធ្វើតាមព្រះឱវាទ ដែលព្រះសាស្តាទ្រង់បានប្រទានហើយដល់ខ្លួន និងអ្នកដែលធ្វើតាមព្រះឱវាទឈ្មោះ

ថា តែងបូជា, ព្រោះហេតុនោះគ្រហស្ថនោះ ទើបឈ្មោះថា រមែង
បូជាព្រះសាស្តាដោយគុណរបស់ខ្លួន ពោលគឺការធ្វើអាមិសបូជា
ដែលខ្លួនធ្វើឱ្យសមគួរដល់ព្រះឱវាទរបស់ព្រះសាស្តាដូច្នេះឯង ។

បុគ្គលណារមែងបូជា ធ្វើសក្ការៈ សរសើរនូវសប្បុរស
ទាំងឡាយ មានព្រះពុទ្ធជាដើម ជាអ្នកប្រសើរខ្ពង់ខ្ពស់ចូលដល់
ភាពជាអ្នកគួរបូជាតាមលំដាប់ដោយការមិនសេពគប់នូវជនពាល
និងដោយការសេពគប់នូវបណ្ឌិត ដូចបានពោលហើយ បុគ្គល
នោះរមែងប្រសព្វនូវប្រយោជន៍សុខ ដូចពណ៌នាមកនេះឯង ។

បដិបត្តិបូជាប៉ុណ្ណោះ គប្បីឃើញថា "**ជាការបូជាដែល
ព្រះសាស្តា ទ្រង់បានត្រាស់សរសើរហើយ និងជាការបូជាយ៉ាង
ប្រសើរខ្ពង់ខ្ពស់**" ។

## រឿងព្រះអត្តទត្ថត្ថេរ

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះអត្ត-
ទត្ថត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា អត្តទត្ថំ បរត្ថេន ជាដើម ។

### [ព្រះថេរៈព្យាយាមបំពេញប្រយោជន៍]

ដូចបានឮមក កាលព្រះសាស្តាត្រាស់ក្នុងកាលជិតនឹង

បរិនិព្វានថា ម្នាលភិក្ខុទាំងឡាយ អំណើ្ឋ ៤ ខែទៀតអំពីថ្ងៃនេះ តថាគតនឹងបរិនិព្វានៈ ភិក្ខុប្រមាណ ៧០០ រូបដែលនៅជាបុថុជ្ជន កើតសេចក្តីសង្វេគ មិនលះសំណាក់ព្រះសាស្តាឡើយ ត្រាច់ប្រឹក្សាគ្នាថា អ្នកមានអាយុ ពួកយើងនឹងធ្វើដូចម្តេចហ្ន៎ ។

ចំណែកព្រះអត្តទត្តត្ថេរគិតថា ឮថា ព្រះសាស្តានឹងបរិនិព្វាន ដោយកាលកន្លងទៅ ៤ ខែទៀត, ក៏ខ្លួនយើងនៅជាអ្នកមានរាគៈ, កាលព្រះសាស្តានៅទ្រង់ព្រះជន្មនៅនេះឯង យើងនឹងព្យាយាមដើម្បីព្រះអរហត្ត ។ ព្រះថេរៈនោះ ទើបមិនបានទៅកាន់សំណាក់របស់ភិក្ខុទាំងឡាយ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា អ្នកមានអាយុ ហេតុអ្វី ទើបលោកមិនមកសំណាក់របស់ពួកខ្ញុំ, លោកមិនប្រឹក្សាអ្វី ៗ ? ហើយក៏នាំទៅកាន់សំណាក់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គភិក្ខុរូបនេះធ្វើយ៉ាងនេះ ។

ព្រះអត្តទត្តត្ថេរនោះ សូម្បីព្រះសាស្តាត្រាស់ថា ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ឮថា ព្រះអង្គនឹងបរិនិព្វាន ដោយកាលកន្លងទៅ ៤ ខែទៀត, ខ្ញុំព្រះអង្គព្យាយាមដើម្បីសំរេចព្រះអរហត្ត ក្នុងកាលព្រះអង្គនៅទ្រង់ព្រះជន្មនៅនេះឯង ។

## [ អ្នកបដិបត្តិធម៌ឈ្មោះថាបូជាព្រះសាស្តា ]

ព្រះសាស្តាប្រទានសាធុការដល់ព្រះថេរៈនោះហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកណាស្រឡាញ់តថាគត, អ្នកនោះគួរដូចជាអត្ថទត្ថ ព្រោះថា ជនទាំងឡាយបូជាដោយវត្ថុទាំងឡាយផ្សេង ៗ មានគ្រឿងក្រអូបជាដើម មិនឈ្មោះថា បូជាតថាគតឡើយ, តែអ្នកបូជាដោយការបដិបត្តិធម៌ដ៏សមគួរដល់ធម៌ទើបឈ្មោះថាបូជាតថាគត, ព្រោះដូច្នោះ សូម្បីភិក្ខុរូបដទៃ ក៏គប្បីដូចជាអត្ថទត្ថ ហើយត្រាស់ព្រះគាថានេះថា ៖

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។

បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឱ្យវិនាស ព្រោះអាស្រ័យប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយគប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួននោះ ។

### អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះថា ៖

បុគ្គលដែលជាគ្រហស្ថ មិនគប្បីញុំាងប្រយោជន៍របស់ខ្លួនសូម្បីប្រមាណមួយកាកណិក ឱ្យសាបសូន្យឡើយ ព្រោះតែ

ប្រយោជន៍របស់អ្នកដទៃ សូម្បីប្រមាណតម្លៃទាំងពាន់ក៏ដោយ ។ ដោយថាប្រយោជន៍របស់ខ្លួននៃបុគ្គលនោះឯង សូម្បីប្រមាណកាកណិកមួយក៏ញ៉ាំងរបស់គួរទំពាឬរបស់គួរបរិភោគឱ្យសម្រេចបាន ។ ប្រយោជន៍របស់អ្នកដទៃ មិនឱ្យសម្រេចទេ ។

ចំណែកពីរបាទព្រះគាថាទាំងនេះ ព្រះដ៏មានព្រះភាគ មិនត្រាស់យ៉ាងនោះ ត្រាស់ដោយប្រធាននៃកម្មដ្ឋាន ។ ព្រោះដូច្នោះភិក្ខុតាំងចិត្តថា យើងនឹងមិនញ៉ាំងប្រយោជន៍របស់ខ្លួនឱ្យសាបសូន្យឡើយ, ដូច្នេះហើយ ក៏មិនគប្បីញ៉ាំងកិច្ច មានការជួសជុលព្រះចេតិយជាដើម ដែលកើតឡើងដល់សង្ឃ ឬវត្ត មានឧបជ្ឈាយវត្តជាដើមឱ្យសាបសូន្យ, ដោយថាភិក្ខុបំពេញអភិសមាចារិកវត្តឱ្យសម្បូរ រមែងធ្វើឱ្យច្បាស់នូវផលទាំងឡាយ មានអរិយផលជាដើម ។ ព្រោះដូច្នោះការបំពេញ វត្តឱ្យបរិបូណ៌ សូម្បីនេះ ទើបឈ្មោះថា ជាប្រយោជន៍របស់ខ្លួនពិត ។

មួយទៀត ភិក្ខុណាមានវិបស្សនាដែលប្រារព្ធក្រៃលែងហើយ ប្រាថ្នាការជាក់ច្បាស់ថា យើងនឹងធ្វើឱ្យចាក់ធ្លុះនូវគុណធម៌ក្នុងថ្ងៃនេះ ៗឯងដូច្នេះហើយប្រព្រឹត្ត, ភិក្ខុនោះសូម្បីញ៉ាំងវត្តមានឧបជ្ឈាយវត្តជាដើមឱ្យវិនាសហើយ ក៏គប្បីធ្វើកិច្ចរបស់ខ្លួន

ឱ្យបាន ។ ក៏ភិក្ខុស្គាល់ប្រយោជន៍របស់ខ្លួនបែបនោះ គឺកំណត់បានថា នេះជាប្រយោជន៍ខ្លួនយើងគប្បីជាអ្នកខ្វល់ខ្វាយប្រកបក្នុងប្រយោជន៍របស់ខ្លួននោះ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈនោះ បានតាំងនៅក្នុងព្រះអរហត្តផល ។ ទេសនាបានជាប្រយោជន៍សូម្បីដល់ភិក្ខុអ្នកប្រជុំគ្នាទាំងឡាយ ដូច្នេះឯង ៕

## រឿងព្រះតិស្សត្ថេរ

ព្រះសាស្ដា កាលគង់នៅក្នុងក្រុងវេសាលី ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា បវិវេករសំ ជាដើម ។

**[បានជ្រាបដំណឹងបរិនិព្វានហើយបំពេញសមណធម៌]**

សេចក្ដីពិស្ដារថា កាលព្រះសាស្ដាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ៤ ខែទៀត តថាគតនឹងបរិនិព្វានហើយ” ។

ភិក្ខុ ៧០០ ក្នុងសម្នាក់នៃព្រះសាស្ដាដល់នូវសេចក្ដីតក់ស្លុតយ៉ាងខ្លាំង ។ ធម្មសង្វេគ កើតដល់ព្រះខីណាស្រពទាំងឡាយ ។ ភិក្ខុបុថុជ្ជនទាំងឡាយមិនអាចនឹងទប់ទល់នូវទឹកភ្នែកបាន ។ ភិក្ខុទាំងឡាយជាពួក ៗ ប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើដូចម្ដេចហ្ន៎

គ្រានោះ ភិក្ខុមួយរូបឈ្មោះតិស្សត្ថេរគិតថា បានឮថា ព្រះសាស្ដានឹងបរិនិព្វាន ដោយកាលកន្លងទៅ ៤ ខែទៀត, អញសោតជាអ្នកមានរាគៈមិនទាន់ទៅប្រាស, កាលព្រះសាស្ដានៅទ្រង់ព្រះជន្ម, អញគួរតែកាន់យកព្រះអរហត្ត( ឱ្យបាន ) លុះគិតដូច្នោះហើយ ក៏ជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ ក្នុងឥរិយាបថទាំង៤ ។ ការទៅកាន់សម្នាក់ភិក្ខុទាំងឡាយ ឮការសន្ទនាប្រាស្រ័យជាមួយនឹងភិក្ខុរូបណាមួយ រមែងមិនមាន ។

គ្រានោះ ភិក្ខុទាំងឡាយពោលនឹងភិក្ខុនោះថា ម្នាលអាវុសោតិស្សៈ ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាងនេះ ? លោកមិនស្ដាប់សំដីរបស់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះក្រាបទូលរឿងនោះចំពោះព្រះសាស្ដា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះតិស្សៈនោះ មិនមានសេចក្ដីស្រឡាញ់ចំពោះព្រះអង្គទេ ។ ព្រះសាស្ដាត្រាស់ឱ្យហៅព្រះតិស្សត្ថេរមកហើយ ត្រាស់សួរថា ម្នាលតិស្សៈព្រោះហេតុអ្វី ? ទើបអ្នកធ្វើយ៉ាងនេះ ។ កាលព្រះតិស្សៈក្រាបទូលសេចក្ដីប្រាថ្នារបស់ខ្លួនហើយ ទ្រង់ប្រទានសាធុការថា សាធុ តិស្សៈ ។ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកដែលស្រឡាញ់តថាគត ចូរជាអ្នកដូចជាតិស្សចុះ សូម្បីអ្នកធ្វើការបូជា

ដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម មិនឈ្មោះថា បូជាតថាគតសោះឡើយ, លុះតែអ្នកណាបដិបត្តិធម៌ដ៏សមគួរដល់ធម៌ ទើបឈ្មោះថា បូជាតថាគត ហើយត្រាស់ព្រះគាថានេះថា ៖

បវិវេករសំ បិត្វា រសំ ឧបសមស្ស ច

និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វានជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្ដីក្រវល់ក្រវាយ មិនមានសេចក្ដីសៅហ្មងឡើយ ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ បទថា បវិវេករសំ សេចក្ដីថា នូវរសដែលកើតហើយអំពីវិវេក, អធិប្បាយថា ដែលសេចក្ដីសុខកើតអំពីភាពជាអ្នកម្នាក់ឯង ។

បទថា បិត្វា សេចក្ដីថាផឹកហើយដោយអំណាចនៃអ្នកធ្វើកិច្ចមានកំណត់ដឹងនូវទុក្ខជាដើម ធ្វើឱ្យច្បាស់ដោយភាពជាអារម្មណ៍ ។

បាទគាថាថា រសំឧបសមស្ស ច សេចក្ដីថា ផឹកហើយ

នូវរសនៃព្រះនិព្វាន ដែលជាទីចូលទៅស្ងប់កិលេសផង ។

ពីរបទថា **និទ្ទរោ ហោតិ** សេចក្តីថា ភិក្ខុជាខីណាស្រព ឈ្មោះថាជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយនិងមិនមានបាប ព្រោះភាពមិនមានសេចក្តីក្រវល់ក្រវាយគឺ រាគៈ ជាដើម ក្នុងខាងក្នុង ព្រោះផឹករសទាំងពីរយ៉ាងនោះ ។ ពីរបទថា **រសំ បិវំ** សេចក្តីថា សូម្បីកាលផឹករសនៃបីតិ ដែលកើតឡើងហើយ ដោយអំណាចនៃលោកុត្តរធម៌ ៩ យ៉ាង រមែងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយនិងមិនមានបាប ។

ក្នុងកាលចប់ទេសនា ព្រះតិស្សត្ថេរៈសម្រេចព្រះអរហត្តហើយ ។ ទេសនាបានជាប្រយោជន៍សូម្បីដល់មហាជនដូច្នេះ ។

# រឿងព្រះធម្មារាមត្ថេរ

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ព្រះធម្មារាមត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា "ធម្មារាមោ ធម្មរតោ" ជាដើម ។

## (ពួកភិក្ខុប្រឹក្សារឿងបរិនិព្វានរបស់ព្រះសាស្តា)

បានឮមកថា កាលព្រះសាស្តាត្រាស់ប្រាប់ថា "ការបរិ-

និព្វានរបស់តថាគតនឹងមានដោយកន្លងទៅ ៤ ខែទៀត ចាប់តាំងពីថ្ងៃនេះទៅ", ភិក្ខុច្រើនពាន់រូបត្រាច់ចោមរោមព្រះសាស្តា ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជន មិនអាចនឹងទប់ទឹកភ្នែកបាន ។ ធម្មសង្វេគកើតឡើងដល់ភិក្ខុជាព្រះខីណាស្រពទាំងឡាយ ។ ភិក្ខុទាំងពួងប្រឹក្សាគ្នាថា "យើងនឹងធ្វើដូចម្តេចហ្ន៎" ដូច្នេះហើយ ក៏ត្រាច់ទៅដោយរួមគ្នាជាពួក ៗ ។

## [ ព្រះធម្មារាមៈមិនទាក់ទង ]

ចំណែកភិក្ខុមួយរូប ឈ្មោះធម្មារាមៈ មិនចូលទៅកាន់សម្នាក់ភិក្ខុទាំងឡាយ, កាលភិក្ខុទាំងឡាយសួរថា "អ្នកមានអាយុ អ្នកកើតអ្វី ?" មិនឆ្លើយតប ដោយគិតថា "ឮថាព្រះសាស្តានឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែទៀត, ចំណែកយើងជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះសាស្តាទ្រង់ព្រះជន្មនៅ យើងនឹងព្យាយាមដើម្បីឱ្យបានសម្រេចព្រះអរហត្ត" ដូច្នេះហើយ ក៏ជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ រមែងរំពឹងនឹកគិត រឭកដល់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ។ ភិក្ខុទាំងឡាយក្រាបទូល ( រឿងនោះ ) ចំពោះព្រះតថាគតថា "បពិត្រព្រះអង្គ ព្រះធម្មារាមៈមិនបានធ្វើសេចក្តីស្នេហាក្នុងព្រះអង្គសូម្បីតែបន្តិចបន្តួច មិនធ្វើការប្រឹក្សា

ជាមួយនឹងពួកខ្ញុំព្រះអង្គសូម្បីតែបន្តិចបន្តួចថា "អ្នកមានអាយុទាំងឡាយ បានឮថា ព្រះសាស្តានឹងបរិនិព្វាន, តើពួកយើងនឹងធ្វើដូចម្តេច ?" ។

## [ព្រះសាស្តាទទួលបញ្ហាឱ្យរកខ្លួន]

ព្រះសាស្តាត្រាស់ឱ្យហៅព្រះធម្មារាមៈ មកគាល់ព្រះសាស្តាត្រាស់ឱ្យហៅលោកមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុ អ្នកបានធ្វើយ៉ាងនោះពិតមែនឬ ?" ។

ព្រះធម្មារាមៈ. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. ព្រោះហេតុអ្វី ?

ព្រះធម្មារាមៈ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮថា ព្រះអង្គនឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែទៀត, ចំណែកខ្ញុំព្រះអង្គជាអ្នកមានរាគៈមិនទាន់ទៅប្រាស, កាលព្រះអង្គទ្រង់ព្រះជន្មនៅនោះឯង ខ្ញុំព្រះអង្គនឹងព្យាយាមដើម្បីឱ្យបានសម្រេចព្រះអរហត្ត ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គរំពឹងនឹក គិតដល់ធម៌ដែលព្រះអង្គទ្រង់សម្តែងហើយ ។

## [ព្រះសាស្តាទ្រង់អនុមោទនា]

ព្រះសាស្តាទ្រង់ប្រទានសាធុការដល់លោកថា " សាធុ សាធុ"ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុណា ស្រឡាញ់តថាគត គប្បីធ្វើដូចជាធម្មារាមភិក្ខុនេះចុះ, ពិតណាស់ ភិក្ខុណាបូជាដោយកម្រងផ្កា និងគ្រឿងក្រអូបជាដើម មិនឈ្មោះ ថាបូជាតថាគតឡើយ, អ្នកបដិបត្តិធម៌ដ៏សមគួរដល់ធម៌ ប៉ុណ្ណោះ ទើបឈ្មោះថាបូជាតថាគត", ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថា នេះថា ៖

**ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ**
**ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។**

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារ-ណាធម៌ រឭកធម៌រឿយ ៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ឡើយ ។

### អធិប្បាយគាថា

គប្បីជ្រាបវិគ្គហៈក្នុងបទទាំងនោះថា ធម៌ គឺសមថៈនិង វិបស្សនា ជាទីត្រេកអររបស់ភិក្ខុនោះ ព្រោះអត្ថថា ជាទីនៅព្រោះ

ហេតុនោះ ទើបឈ្មោះថា អ្នកមានធម៌ជាទីត្រេកអរ, ត្រេកអរហើយក្នុងធម៌នោះ ព្រោះហេតុនោះ ទើបឈ្មោះថា អ្នកត្រេកអរហើយក្នុងធម៌, ដែលឈ្មោះថាអនកពិចារណាធម៌ ព្រោះរឭកដល់ធម៌នោះរឿយ ៗ, អធិប្បាយថា អ្នកនឹកដល់ធម៌នោះ ។

បទថា អនុស្សរំ បានដល់ រឭកដល់ធម៌នោះឯង ។

បទថា សទ្ធម្មា សេចក្ដីថា ភិក្ខុនោះ រមែងសាបសូន្យចាកពោធិបក្ខិយធម៌ ៣៧ ប្រការ និងលោកុត្តរធម៌ ៩ ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងព្រះអរហត្ត, ទេសនាបានជាគុណជាតិមានប្រយោជន៍ សូម្បីដល់បរិស័ទដែលប្រជុំគ្នាហើយ ដោយប្រការដូច្នេះ ។

## អានិសង្សបូជាបុគ្គលដែលគួរបូជា

ការបូជា ចំពោះបូជនេយ្យបុគ្គលទាំងនោះឯង ឈ្មោះថាជាមង្គលទាំងអស់ ព្រោះជាការសមាទាននូវកុសលធម៌ និងព្រោះជាហេតុនៃសេចក្ដីចំរើន ដោយធម៌មានអាយុជាដើម ។ ព្រោះហេតុនោះនៅក្នុងចក្កវត្តិសូត្រ ទើបព្រះដ៏មានព្រះមានភាគទ្រង់ត្រាស់ថា "មនុស្សទាំងឡាយនោះនឹងជាអ្នកប្រតិបត្តិដោយប្រពៃចំពោះ

មាតា ជាអ្នកប្រតិបត្តិដោយប្រពៃចំពោះបិតា ជាអ្នកប្រតិបត្តិដោយប្រពៃចំពោះសមណព្រាហ្មណ៍ ជាអ្នកប្រព្រឹត្តកោតក្រែងដល់បុគ្គលដែលចំរើនដោយវ័យ (រៀមច្បង)ក្នុងត្រកូល ជាប្រក្រតី, នឹងសមាទានប្រព្រឹត្តនូវកុសលធម៌នេះ មនុស្សទាំងនោះនឹងចម្រើនដោយអាយុខ្លះ នឹងចម្រើនដោយពណ៌សម្បុរខ្លះ ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ" ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយណា ជាបុត្ររបស់មាតានិងបិតា ដែលមានអាយុប្រមាណ ២ ម៉ឺនឆ្នាំ នឹងជាមនុស្សដែលមានអាយុ ៤ ម៉ឺនឆ្នាំ, ពួកមនុស្សដែលកើតមកជាបុត្រទាំងនោះ ព្រោះជាអ្នកបានទំនុកបម្រុងមាតានិងបិតា សមណព្រាហ្មណ៍ រៀមច្បង គឺជាអ្នកចម្រើន មានឪពុកធំ ឪពុកមានិងបងប្រុសជាដើម ក្នុងត្រកូលរបស់ខ្លួន ។

ម្យ៉ាងទៀត ការបូជា នូវបុគ្គលដែលគួរបូជា ឈ្មោះថាជាមង្គល ព្រោះជាហេតុនៃព្រះនិព្វាននិងសុគតិ ។

# មោរជាតក

(ក្ងោកពោធិសត្វពោលថា) សុរិយទេវបុត្រណា ជាឯកករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដីកំពុងរះឡើង, ខ្ញុំសូមមនស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី, ខ្ញុំសូមឱ្យលោកគ្រប់គ្រងរក្សាអស់វេលាថ្ងៃក្នុងនេះ, ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវវេទក្នុងធម៌ទាំងពួង, សូមព្រាហ្មណ៍ទាំងឡាយនោះ រក្សាខ្ញុំ, ការនមស្ការ ចូរមានដល់លោក អ្នកត្រាស់ដឹងទាំងឡាយ ការមនស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង, ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ, ក្ងោកពោធិសត្វនោះធ្វើបរិត្ត នេះរួចហើយ ទើបត្រាច់ទៅស្វែងរកអាហារ ។

(សុរិយទេវបុត្រណា) ជាឯករាជមានចក្ខុ មានសម្បុរដូចមាសមានពន្លឺផ្សាយទៅលើផែនដី កំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឱ្យលោកគ្រប់គ្រងរក្សា អស់រាត្រី

ក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វធ្វើបរិត្តនេះរួចហើយ ទើបបានសម្រេចការនៅ ។

## រឿងនាយសុមនមាលាការ

នៅក្នុងអដ្ឋកថាភាគ ៤១, ទំព័រ ២០៤ ព្រះអង្គសម្ដែងទាក់ទង់ទៅនឹងអានិសង្សនៃការបូជា ដោយមានសេចក្ដីថា ៖

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនាយមាលាការឈ្មោះសុមនៈត្រាស់ព្រះធម៌ទេសនានេះថា "តញ្ច កម្មំ កតំ សាធុ" ជាដើម ។

(ព្រះសាស្ដាស្ដេចបិណ្ឌបាត)

ដូចបានស្ដាប់មក នាយមាលាការនោះ បម្រើព្រះបាទពិម្ពិសារដោយផ្កាម្លិះ ៨ នាឡិពីព្រឹកព្រលឹមរាល់ថ្ងៃ រមែងបាន

កហាបណៈមួយថ្ងៃ ៨ កហាបណៈ កាលនាយមាលាការនោះកាន់ផ្កាឈើ ល្មមចូលទៅកាន់ព្រះនគរព្រះមានព្រះភាគដែលភិក្ខុសង្ឃពួកធំហែហម ទ្រង់ផ្សាយព្រះរស្មីពណ៌ ៦ ស្ដេចចូលកាន់ព្រះនគរ ដើម្បីបិណ្ឌបាត ដោយព្រះពុទ្ធានុភាពដែលធំដោយព្រះពុទ្ធលីលាដែលធំ ។ ពិតមែន ក្នុងកាលពេលខ្លះ ព្រះមានព្រះភាគទ្រង់បិទរស្មីមានពណ៌ ៦ ដោយចីវរហើយស្ដេចទៅដូចភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្តរូបណាមួយ ដូចស្ដេចទៅទទួលព្រះអង្គុលិមាល អស់ផ្លូវតាំង ៣០ យោជន៍, ក្នុងកាលវេលាខ្លះទ្រង់ផ្សាយព្រះរស្មីមានពណ៌ៈ ៦ ដូចទ្រង់ផ្សាយក្នុងវេលាស្ដេចចូលទៅកាន់ក្រុងកបិលភស្តុជាដើម ។

សូម្បីក្នុងថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ផ្សាយរស្មីមានពណ៌ ៦ ចាកពីព្រះសរីរៈ ស្ដេចចូលទៅកាន់ក្រុងរាជគ្រឹះ ដោយព្រះពុទ្ធានុភាពដែលធំ ដោយពុទ្ធលីលាដែលធំ ។

## (នាយមាលាការបូជាព្រះសាស្ដាដោយផ្កាឈើ)

គ្រានោះ នាយមាលាការឃើញអត្តភាពព្រះមានព្រះភាគដូចនឹងដោយរតនៈដែលមានតម្លៃ និងមាសដែលមានតម្លៃ ក្រឡេក

មើលព្រះសរីរៈដែលប្រដាប់ហើយ ដោយមហាបុរិសលក្ខណៈ ៣២ មានចំណែកសេចក្ដីល្អដោយព្រះសិរីគឺ អនុព្យញ្ជនៈ ៨០ មានចិត្តជ្រះថ្លាហើយ គិតថា យើងនឹងធ្វើការបូជាក្រៃលែងចំពោះព្រះសាស្ដាយ៉ាងណាហ្ន៎ ? កាលមិនឃើញវត្ថុដទៃ ទើបគិតថា យើងនឹងបូជាព្រះមានព្រះភាគដោយផ្កាឈើទាំងនេះ គិតទៀតថា ផ្កាឈើទាំងនេះជាផ្កាឈើសម្រាប់បម្រើព្រះរាជាប្រចាំ, ព្រះរាជាកាលទ្រង់មិនបានផ្កាឈើទាំងនេះ គប្បីឱ្យឃុំឃាំងយើងខ្លះ គប្បីឱ្យសម្លាប់យើងខ្លះ គប្បីបណ្ដេញចេញពីព្រំដែនខ្លះ, យើងនឹងធ្វើយ៉ាងណាហ្ន៎ ? គ្រានោះ សេចក្ដីគិតយ៉ាងនេះបានមានដល់នាយមាលាការនោះថា ព្រះរាជានឹងទ្រង់សម្លាប់យើងក៏ដោយ បណ្ដេញចេញពីដែនក៏ដោយ, ក៏ព្រះរាជានោះ សូម្បីកាលព្រះរាជទានដល់យើង គប្បីព្រះរាជទានទ្រព្យត្រឹមតែជាចិញ្ចឹមជីវិតក្នុងអត្តភាពនេះ ដល់យើងក្នុងកោដិកប្បជាអនេកមិនតែមួយ យើងលះបង់ជីវិតរបស់យើងចំពោះព្រះតថាគតហើយ ។ នាយមាលាការនោះ គិតថា ចិត្តជ្រះថ្លារបស់យើងមិនត្រឡប់ក្លាយត្រឹមណា យើងនឹងធ្វើការបូជាត្រឹមនោះតែម្ដង ជាអ្នករីករាយសប្បាយហើយមានចិត្តរីករាយនិងក្លៀវក្លារីករាយបូជាព្រះសាស្ដាហើយ ។

(សេចក្តីអស្ចារ្យរបស់ផ្កាឈើដែលជាពុទ្ធបូជា)

នាយមាលាការនោះបូជាយ៉ាងណា ? ទីដំបូង នាយមាលាការបោះផ្កាឈើ ២ បាច់ឡើងទៅក្នុងខាងលើរបស់ព្រះតថាគតមុន ។ ផ្កាឈើ ២ បាច់នោះ បានតាំងជាពិតានក្នុងខាងលើព្រះសិរសា ។ គេបោះផ្កាឈើ២ បាច់ឡើងទៀត ។ ផ្កាឈើ ២ បាច់នោះ បានចុះមកនៅផ្លូវខាងស្តាំព្រះហស្ត ដោយអាការដែលមាលាបាំងទុក ។ គេបោះបាច់ផ្កាឈើ២ បាច់ដទៃទៀត ។ ផ្កាឈើ ២ បាច់នោះ បានព្យួរចុះមកតាំងនៅផ្លូវផ្នែកខាងព្រះបិដ្ឋិ ( ខ្នង ) យ៉ាងនោះដូចគ្នា ។ គេបោះផ្កាឈើ ២ បាច់ដទៃទៀត ។ ផ្កាឈើ ២ បាច់ព្យួរចុះមកតាំងនៅផ្នែកខាងព្រះហស្តឆ្វេង យ៉ាងនោះដូចគ្នា ។ ផ្កាឈើ៨ នាឡិជា ៨ បាច់ លោមព័ទ្ធព្រះតថាគតក្នុងឋានៈទាំង ៤ ដោយប្រការដូច្នេះ ។ មានផ្លូវល្មមជាទ្វារដើរទៅខាងមុខប៉ុណ្ណោះ ។ ទងផ្កាឈើទាំងឡាយបានបែរមុខចូលទៅខាងក្នុង បែរត្របកចេញខាងក្រៅ ។ ព្រះមានព្រះភាគជាហាក់បីដូចជាហែហមហើយដោយផែនប្រាក់ ស្តេចទៅហើយ ។ ផ្កាឈើទាំងឡាយសូម្បីមិនមានចិត្ត អាស្រ័យបុគ្គលដែលមានចិត្តមិនបែកគ្នា មិន

ធ្លាក់ចុះ រមែងទៅជាប់នឹងព្រះសាស្តានោះ ហើយរមែងឈប់ក្នុងទីប្រថាប់ឈរ ។ រស្មីហាក់បីដូចជាខ្សែផ្លេកបន្ទោរទាំងសែន ខ្សែចេញពីព្រះសរីរៈរបស់ព្រះសាស្តា ។ ព្រះរស្មីដែលចេញ( ចាកពីព្រះកាយនោះ ) ចេញទាំងខាងមុខទាំងខាងក្រោយ ទាំងបាយស្តាំនិងបាយឆ្វេង ទាំងខាងលើព្រះសិរសា ។ ព្រះរស្មីសូម្បីតែខ្សែមួយ មិនបាត់ទៅផ្លូវដែលត្រង់ខាងព្រះភ័ក្ត្រ សូម្បីទាំងអស់ធ្វើប្រទក្សិណព្រះសាស្តា ៣ ជុំវិញហើយ រួមជាព្រះរស្មី មានប្រមាណប៉ុនដើមត្នោតកម្ពោះបាញ់ត្រង់ទៅខាងមុខផ្លូវតែមួយ ។

[ នាយមាលាការប្រាប់ដល់ភរិយា ]

នគរទាំងអស់សាយសុះហើយ ។ បណ្តាជន ១៨ កោដិ គឺក្នុងខាងក្នុងនគរ ៩ កោដិ ខាងក្រៅនគរ ៩ កោដិ ប្រុសឬស្រីសូម្បីម្នាក់ ឈ្មោះថា នឹងមិនកាន់យកភិក្ខាចេញទៅ រមែងមិនមាន ។ មហាជនបន្លឺសីហនាទ ធ្វើការលើកកំណាត់សំពត់ ឡើងទាំងពាន់នៅខាងមុខព្រះសាស្តា ពិតមែន សូម្បីព្រះសាស្តាដើម្បីនឹងទ្រង់ធ្វើគុណរបស់នាយមាលាការឱ្យប្រាកដ បានស្តេចត្រាច់ទៅក្នុងព្រះនគរប្រមាណ ៣ គាវុត ដោយផ្លូវជាទីត្រាច់ទៅដោយ

ស្គរទុំះឯង ។ សរីរៈទាំងអស់របស់នាយមាលាការពេញប្រៀប ដោយបីតិមានវណ្ណៈទាំង ៥ ។ នាយមាលាការត្រាច់ទៅនឹងព្រះតថាគតបន្តិចមួយប៉ុណ្ណោះ ចូលទៅក្នុងខាងក្នុងនៃពុទ្ធរស្មី ហាក់បីដូចជាលិចចុះក្នុងរសនៃមនោសិលា សរសើរថ្វាយបង្គំព្រះសា-ស្តាហើយបានកាន់យកកន្ត្រកទទេទុំះឯង ទៅកាន់ផ្ទះ ។

គ្រានោះ ភរិយាសួរគេថា ផ្កាឈើនៅទីណា

មាលាការ. យើងបូជាព្រះសាស្តាហើយ ។

ភរិយា. ឥឡូវនេះលោកនឹងធ្វើអ្វីចំពោះព្រះរាជាហ្ន៎ ?

មាលាការ.ព្រះរាជានឹងទ្រង់សម្លាប់យើងក៏ដោយ បណ្តេញចាកពីព្រំដែនក៏ដោយ, យើងលះបង់ជីវិតបូជាព្រះសាស្តាហើយ, ផ្កាឈើទាំងអស់មាន ៨ បាច់, បូជាឈ្មោះបែបនេះកើតហើយ, មហាជនធ្វើការស្រែកទាំងពាន់ ត្រាច់ទៅជាមួយនឹងព្រះសាស្តា, នោះ សំឡេងស្រែកមហាជនក្នុងទីនោះ ។

## [ភរិយាមិនជ្រះថ្លាចោទព្រះរាជា]

លំដាប់នោះ ភរិយារបស់គេជាអ្នកស្រីអន្ធពាល មិនញុំាងសេចក្តីជ្រះថ្លាក្នុងព្រះបាដិហារ្យបែបនោះក៏កើតការ ជេរគេហើយពោលថា ធម្មតាព្រះរាជាទាំងឡាយ ជាអ្នកប្រទុសរ៉ាយ ក្រោធ

គ្រាតែមួយក៏ធ្វើសេចក្ដីវិនាសសូម្បីច្រើន ដោយការកាត់ដៃនិងជើងជាដើម, សេចក្ដីវិនាសគប្បីមានសូម្បីដល់យើង ព្រោះកម្មដែលលោកធ្វើ នាំពួកបុត្រទៅកាន់រាជត្រកូល អ្នកដែលព្រះរាជាត្រាស់ហៅមកសួរថា អ្វីគ្នានេះ ? ទើបក្រាបទូលថា ស្វាមីរបស់នាងខ្ញុំយកផ្កាឈើសម្រាប់បម្រុងព្រះអង្គបូជា ព្រះសាស្ដាហើយមានដៃទទេមកកាន់ផ្ទះត្រូវខ្ញុំសួរថា ផ្កាឈើនៅណា ? ក៏ពោលពាក្យឈ្មោះនេះ នាងខ្ញុំជេរគេ ហើយពោលថា ធម្មតាព្រះរាជាទាំងឡាយជាអ្នកប្រទុស្ដរ៉ាយ ក្រោធគ្រាតែមួយ ក៏ធ្វើសេចក្ដីវិនាសសូម្បីច្រើន ដោយការកាត់ដៃនិងកាត់ជើងជាដើម, សេចក្ដីវិនាសគប្បីមានសូម្បីដល់យើង ព្រោះកម្មដែលលោកធ្វើ' ដូច្នេះហើយក៏បោលគេមកក្នុងទីនេះ;កម្មដែលគេធ្វើ ចូរជាកម្មល្អក៏ដោយ ចូរជាកម្មអាក្រក់ក៏ដោយកម្មនោះចូរជារបស់គេអ្នកតែមួយសូមតេជះព្រះអង្គចូរទ្រង់ជ្រាបសេចក្ដីដែលនាងខ្ញុំបោលហើយ ។

## [ព្រះរាជាទ្រង់ធ្វើជាក្រោធ]

ព្រះរាជាទ្រង់សម្រេចសោតាបត្តិផលដល់ព្រមដោយសទ្ធាជាអរិយសាវកដោយការឃើញទីដំបូងនុ៎ះឯងទ្រង់ត្រិះរិះថាឱ !

ស្រីនេះជាអន្ធពាល មិនញុំាងជ្រះថ្លាក្នុងគុណបែបនេះឱ្យកើតឡើង ។ ស្ដេចលោកធ្វើជាក្រោធ ត្រាស់ថា អ្នកឯងនិយាយអ្វីនាង ? នាយមាលាការនោះធ្វើការបូជា ដោយផ្កាឈើសម្រាប់បម្រុងយើងឬ ? ស្រីនោះទូលថា សូមតេជៈព្រះអង្គ ។ ព្រះរាជាត្រាស់ថា សេចក្ដីល្អដែលអ្នកឯងចោលគេធ្វើហើយ, យើងនឹងដឹងកិច្ចដែលគួរធ្វើដល់នាយមាលាការ អ្នកធ្វើការបូជាដោយផ្កាឈើទាំងឡាយរបស់យើង ទ្រង់បញ្ជូនស្រីនោះទៅហើយ ប្រញាប់ស្ដេចទៅក្នុងសំណាក់ព្រះសាស្ដា ថ្វាយបង្គំហើយ ស្ដេចត្រាច់ទៅនឹងដោយព្រះសាស្ដានោះ ពិតមែន ។

ព្រះសាស្ដា ទ្រង់ជ្រាបសេចក្ដីជ្រះថ្លានៃព្រះរាជហឫទ័យរបស់ព្រះរាជានោះ ស្ដេចត្រាច់ទៅកាន់ព្រះនគរតាមថ្នល់ដែលជាទីត្រាច់ទៅដោយស្គរហើយ បានស្ដេចទៅកាន់ព្រះទ្វារនៃរាជដំណាក់របស់ព្រះរាជា ។ ព្រះរាជាទ្រង់ទទួលបាត្របានទ្រង់មានព្រះប្រាថ្នានឹងអញ្ជើញស្ដេច ព្រះសាស្ដាចូលទៅកាន់ព្រះរាជដំណាក់ ។

ចំណែកព្រះសាស្ដា បានទ្រង់សម្ដែងព្រះអាការដែលនិងប្រថាប់អង្គុយក្នុងព្រះរាជរាំងនុំះឯង ។ ព្រះរាជាទ្រង់ជ្រាប់ព្រះ

អាការនោះហើយ បង្គាប់ឱ្យធ្វើបារាំក្នុងខណៈនោះឯង ដោយព្រះតម្រាស់ថា លោកទាំងឡាយចូរធ្វើបារាំដោយរហ័ស ។

ព្រះសាស្ដាប្រថាប់អង្គុយជាមួយនឹងពួកភិក្ខុហើយ ។

សួរថា "ក៏ព្រោះហេតុអ្វី ព្រះសាស្ដាទើបមិនស្ដេចចូលកាន់ព្រះរាជដំណាក់ ?"

ឆ្លើយថា (ព្រោះ) បានឮថា សេចក្ដីបរិវិតក្កយ៉ាងនេះបានមានដល់ព្រះអង្គថា បើថាយើងគប្បីចូលទៅអង្គុយក្នុងខាងក្នុងសោត មហាជនគប្បីមិនបានដើម្បីនឹងឃើញយើង គុណរបស់នាយមា-លាការនឹងមិនប្រាកដ ។ ប៉ុន្តែថា មហាជននឹងបានដើម្បីឃើញយើងអ្នកអង្គុយនៅក្នុងព្រះរាជវាំង, គុណរបស់នាយមាលាការក៏នឹងប្រាកដ ។

[ព្រះរាជាទ្រង់ព្រះរាជទានវត្ថុ ៨ ៗ យ៉ាង]

ពិតមែន ព្រះពុទ្ធរបស់យើងប៉ុណ្ណោះ រមែងអាចដើម្បីធ្វើគុណរបស់បុគ្គលដែលមានព្រះគុណទាំងឡាយ ឱ្យប្រាកដ, ជនដែលនៅសល់ កាលនឹងពោលគុណរបស់បុគ្គលដែលមានគុណទាំងឡាយ រមែងប្រព្រឹត្តកំណាញ់ (គឺសន្សំហើយ) ។ ផែនផ្កា

ឈើ ៤ ផែន បានតាំងនៅក្នុងទិសទាំង ៤ ហើយ ។ មហាជនហែហមព្រះសាស្ដាហើយ ។ ព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ដោយអាហារដែលប្រណីត ។

ក្នុងវេលាសម្រេចភត្តកិច្ច ព្រះសាស្ដាទ្រង់ធ្វើអនុមោទនាហើយ ដែលផែនផ្កាឈើ ៤ ផែន ហែហមដោយន័យមុនទុំះឯង ដែលមហាជនអ្នកបន្ទឺសីហនាទហែហម បានស្ដេចទៅកាន់វិហារហើយ ។ ព្រះរាជាតាមបញ្ជូនព្រះសាស្ដា ត្រឡប់ហើយ បន្ទាប់ឱ្យនាយមាលាការមកហើយ ត្រាស់សួរថា អ្នកឯងថាយ៉ាងណាទើបបូជាព្រះសាស្ដាដោយផ្កាឈើ ដែលខ្ញុំនគប្បីនាំមកដើម្បីយើង ? នាយមាលាការ ក្រាបទូលថា សូមតេជៈខ្ញុំព្រះអង្គគិតថា ព្រះរាជានឹងសម្លាប់យើងក៏ដោយ នឹងបណ្ដេញយើងចេញចាកពីព្រំដែនក៏ដោយ ដូច្នេះហើយ ទើបលះបង់ជីវិតបូជាព្រះសាស្ដា ។ ព្រះរាជាត្រាស់ថា អ្នកឯងឈ្មោះថា ជាមហាបុរស ហើយព្រះរាជទានរបស់ដែលគួរឱ្យ ឈ្មោះពួក៨ នៃវត្ថុទាំងពួងនេះ គឺដំរី ៨ សេះ ៨ ទាស ៨ ទាសី៨ គ្រឿងប្រដាប់ធំ៨កហាបណៈ ៨ពាន់នារី ៨ នាក់ ដែលនាំមកចាកពីរាជត្រកូលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង និងស្រុកសួយ ៨ តំបន់ ។

[ព្រះសាស្តាត្រាស់សរសើរនាយមាលាការ]

ព្រះអានន្ទត្ថេរគិតថាថ្ងៃនេះ តាំងពីព្រឹកព្រលឹមសំឡេងសីហនាទទាំងពាន់ និង ការលើកកំណាត់សំពត់ឡើងទាំងពាន់រមែងប្រព្រឹត្តទៅ ។ វិបាករបស់នាយមាលាការជាយ៉ាងណាហ្ន៎ ? ព្រះថេរៈនោះ ទូលសួរព្រះសាស្តាហើយ ។

លំដាប់នោះព្រះសាស្តាត្រាស់ចំពោះព្រះថេរៈនោះថាម្នាលអានន្ទលោកកុំបានកំណត់ថា កម្មមានប្រមាណបន្តិចបន្តួចដែលនាយមាលាការនេះធ្វើហើយ ក៏នាយមាលាការនេះបានលះបង់ជីវិតធ្វើការបូជាយើងហើយ គេញុំាងចិត្តឱ្យជ្រះថ្លាក្នុងយើងដោយអាការយ៉ាងនេះ នឹងមិនទៅកាន់ទុគតិ រហូតដល់អស់សែនកប្បដូច្នេះហើយត្រាស់ថា ៖

នាយមាលាការនឹងតាំងនៅក្នុងទេវតានិងមនុស្សទាំងឡាយនឹងមិនទៅកាន់ទុគតិរហូតដល់អស់សែនកប្ប នេះជាផលនៃកម្មនោះ, ខាងក្រោយគេនឹងជាព្រះបច្ចេកពុទ្ធនាមថា សុមនៈ ។

ក៏ក្នុងវេលាព្រះសាស្តាស្តេចដល់វិហារ ចូលទៅកាន់ព្រះគន្ធកុដិ ផ្កាឈើទាំងនោះធ្លាក់ចុះត្រង់ស៊ុមព្រះទ្វារហើយ ។

[មិនគួរធ្វើកម្មដែលក្តៅក្រហាយខាងក្រោយ]

ក្នុងវេលាល្ងាចភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម៌ថា ឃើអើ ! កម្មរបស់នាយមាលាការ គួរអស្ចារ្យ លោកលះបង់ជីវិតដើម្បីព្រះពុទ្ធដែលមានព្រះជន្មនៅ ធ្វើការបូជាដោយផ្កាឈើហើយបានរបស់ព្រះរាជទានឈ្មោះថា ពួក ៨ សុទ្ធក្នុងខណៈនុ៎ះឯង ។ ព្រះសាស្តាស្តេចចេញពីព្រះគន្ធកុដិហើយ ទៅកាន់រោងធម៌ដោយការស្តេចទៅ ៣ យ៉ាង យ៉ាងណាមួយ ប្រថាប់អង្គុយលើព្រះពុទ្ធអាសនៈហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះលោកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ? កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា យ៉ាងនោះម្នាលភិក្ខុទាំងឡាយ សេចក្តីក្តៅក្រហាយក្នុងខាងក្រោយ រមែងមិនមាន មានតែសោមនស្សប៉ុណ្ណោះ សង្វេបទកើតឡើងក្នុងខណៈដែលរំលឹកហើយ ៗ ព្រោះបុគ្គលធ្វើកម្មណា កម្មបែបនោះដែលបុគ្គលគួរធ្វើពិត កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ទើបត្រាស់ព្រះគាថានេះថា ៖

តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ

យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយរមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្តមានចិត្តល្អទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា យំ កត្វា សេចក្តីថា បុគ្គលធ្វើកម្មណាគឺកម្មដែលអាចញ៉ាំងសម្បត្តិទេវតានិងសម្បត្តិមនុស្សនិងនិព្វានសម្បត្តិឱ្យកើត គឺមានសុខជាកម្រៃរមែងមិនក្តៅក្រហាយក្នុងកាលខាងក្រោយ ដោយពិត បុគ្គលនោះឈ្មោះថា ជាអ្នកឆ្អែតហើយ ដោយកម្លាំងនៃបីតិនិងឈ្មោះថា មានចិត្តរីករាយដោយកម្លាំងនៃសោមនស្សក្នុងខណៈ ដែលរឭក ជាអ្នកកើតបីតិនិងសោមនស្សក្នុងកាលតទៅ រមែងសោយផលក្នុងទិដ្ឋធម៌នោះឯង កម្មនោះដែលបុគ្គលធ្វើហើយ ជាកម្មញ៉ាំងប្រយោជន៍ឱ្យសម្រេច គឺជាកម្មល្អ បានដល់ ជាកម្មថ្លៃថ្នូរ ។

ក្នុងវេលាចប់ទេសនា ធម្មាភិសម័យ ( ការត្រាស់ដឹងធម៌ ) បានកើត មានដល់សត្វ ៨៤.០០០ ដោយប្រការដូច្នេះឯង ។

# រឿងអាយុវឌ្ឍនកុមារ

នៅក្នុងអដ្ឋកថាលេខ៤១,ទំព័រ ៤៦២ព្រះអង្គសម្តែងអំពី [**ការក្រាបសំពះលោកអ្នកមានគុណធ្វើឱ្យមានអាយុវែង**] ដោយមានសេចក្តីថា ៖

ខាងក្រោយថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម៌ថា ម្នាលមានអាយុទាំងឡាយ លោកទាំងឡាយចូរមើល, បានឮថា អាយុវឌ្ឍនកុមារគប្បីស្លាប់ក្នុងថ្ងៃទី ៧, ឥឡូវនេះអាយុវឌ្ឍនកុមារនោះ(តាំងនៅ១២០ឆ្នាំ)ដែលឧបាសក ៥០០ នាក់ហែហមត្រាច់ទៅ, ហេតុគ្រឿងចម្រើនអាយុរបស់សត្វទាំងនោះឃើញទីងមាន ។

ព្រះសាស្តា ស្តេចមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយឥឡូវនេះ ពួកលោកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ? កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះនេះ ។ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុចម្រើនតែម្យ៉ាងប៉ុណ្ណោះក៏ទេ ។ ក៏សត្វទាំងនេះសំពះលោកអ្នកមានព្រះគុណ រមែងចម្រើនដោយហេតុ ៤ ប្រការ, ផុតពីអន្តរាយ, តាំងនៅដរាបរហូតដល់អស់អាយុ តែម្តងដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ទើប

ត្រាស់ព្រះគាថានេះថា ៖

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ

ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែង ចំរើនដល់អ្នកដែលមានសេចក្តីខ្ពង់កាយថ្វាយបង្គំជាប្រក្រតីមាន សេចក្តីកោតក្រែង ដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជា និច្ច ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះបទថា អភិវាទនសីលិស្ស គឺអ្នកថ្វាយ បង្គំជាប្រក្រតី បានដល់អ្នកខ្វល់ខ្វាយក្នុងកិច្ច គឺ ការថ្វាយបង្គំ រឿយ ៗ ។

បទថា វុឌ្ឍាបចាយិនោ សេចក្តីថា ដល់គ្រហស្ថអ្នកខ្ពង់ លំទោន ឬសាមណេរ ឬសក្នុងថ្ងៃនោះ ឬក៏ដល់បព្វជិតអ្នកខ្ពង់ លំទោន ឬអ្នកបូជាជានិច្ច ដោយការក្រាបថ្វាយបង្គំចំពោះលោក អ្នកដែលចាស់ជាងដោយបព្វជ្ជាឬឧបសម្បទា( ឬ )ចំពោះលោក អ្នកដែលចម្រើនដោយគុណ ។

ពីរបទថា **ចត្តារោ ធម្មា** សេចក្ដីថា កាលអាយុចម្រើន, អាយុនោះ រមែងចម្រើនអស់កាលប៉ុណ្ណា, ធម៌ទាំងឡាយសូម្បីក្រៅនេះ ក៏ចម្រើនអស់កាលប៉ុណ្ណោះដែរ, ព្រោះថា បុគ្គលណាធ្វើបុណ្យដែលញ៉ាំងអាយុ ៥០ ឆ្នាំ ឱ្យប្រព្រឹត្តទៅ, អន្តរាយនៃជីវិតរបស់បុគ្គលនោះអាចកើតឡើងក្នុងកាលដែលមានអាយុ ២៥ ឆ្នាំ អន្តរាយនោះ រមែងស្ងប់ទៅបាន ដោយភាពជាអ្នកក្រាបថ្វាយបង្គំជាប្រក្រតី ។ បុគ្គលនោះ រមែងរស់នៅបានរហូតដល់អស់អាយុ ។ សូម្បីវណ្ណៈជាដើមរបស់អ្នកនោះ រមែងចម្រើនព្រមនឹងអាយុដែរ ។

ន័យសូម្បីក្រៅពីនេះ ក៏យ៉ាងនេះឯង ។

ដែលឈ្មោះថា ការចម្រើននៃអាយុដែលប្រព្រឹត្តទៅដោយមិនមានអន្តរាយ រមែងមិនមានឡើយ ។

## សង្ខេបខ្លីៗ

១- ញ៉ាំងសេចក្ដីឃើញត្រូវ ដែលនៅមិនទាន់កើតឡើងឱ្យកើតឡើង

២- ញ៉ាំងសេចក្ដីឃើញត្រូវដែលកើតឡើងហើយ ឱ្យចម្រើនទៅមុខក្រៃលែងឡើង

៣- ធ្វើឱ្យមានកិរិយាមារយាទសុភាពរាបសា ទន់ភ្លន់គួរឱ្យស្រឡាញ់ គួរឱ្យរាប់អាន

៤- ធ្វើឱ្យចិត្តផូរផង់ថ្លា ព្រោះត្រិះរិះនៅក្នុងកុសលធម៌

៥- ធ្វើឱ្យមានសតិសម្បជញ្ញៈបរិបូណ៌ឡើង ព្រោះមានសេចក្ដីសង្រួមរវាំង ជាការការពារសេចក្ដីប្រមាទ

៦- ការពារសេចក្ដីភ្លេចខ្លួនសេចក្ដីវង្វេងខុសបាន ព្រោះយល់ច្បាស់ថា អ្នកដែលមានគុណធម៌ខ្ពស់ជាងខ្លួននៅមាន

៧- ធ្វើឱ្យកើតកម្លាំងចិត្ត និងអានុភាពមហាសាលអាចគ្រប់គ្រងការពារឱ្យផុតអំពីឧបសគ្គនិងភ័យពីបុគ្គលពាលផ្សេង ៗបាន

៨- ជាការកម្ចាត់បុគ្គលពាលឱ្យវិនាស ព្រោះមានតែបុគ្គលដែលគួរបូជា បណ្ឌិតអ្នកមានគុណធម៌

៩- ជាការលើកសរសើរបណ្ឌិតឱ្យខ្ពស់ឡើងធ្វើឱ្យលោកអាចបំពេញករណីយកិច្ចបានល្អ ទូលំទូលាយឡើង ។

៦. អ្នកណាគប្បីបូជាលោកអ្នកមានខ្លួនអប់រំហើយ មួយនាក់សូម្បីតែមួយភ្លែត ការបូជារបស់អ្នកនោះ ប្រសើរជាងការបូជារបស់បុគ្គលអ្នកបូជា ( លោកិយមហាជន )ដោយទ្រព្យមួយពាន់ ៗរហូតអស់រយឆ្នាំ ។

## ធម្មគតិ

៙. មាតាបិតា ជាបូជនីយបុគ្គលរបស់បុត្តធីតា

៙. គ្រូ អាចារ្យ ឧបជ្ឈាយ៍ ជាបូជនីយបុគ្គលរបស់អន្តេវាសិក( សិស្សទាំងឡាយ )

៙. រាមច្បងជាបូជនីយបុគ្គលរបស់ប្អូន ៗទាំងឡាយ

៙. ស្វាមីជាបូជនីយបុគ្គលរបស់ភរិយា

៙. ព្រះរាជា ជាបូជនីយបុគ្គលរបស់ប្រជានុរាស្ត្រ

៙. ព្រះសង្ឃជាបូជនីយបុគ្គលរបស់ពុទ្ធបរិស័ទ

៙. ព្រះសម្មាសម្ពុទ្ធជាជាបូជនីយបុគ្គលរបស់ មនុស្សនិងទេវតា មារ ព្រហ្មទាំងឡាយ ។

-ពុទ្ធបូជា មហាតេជោ បូជាព្រះពុទ្ធមានតេជៈច្រើន

-ធម្មបូជា មហាបញ្ញោ បូជាព្រះធម៌មានបញ្ញាច្រើន

-សង្ឃបូជា មហាធនំ បូជាព្រះសង្ឃមានទ្រព្យធនច្រើន ។

"យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ភិក្ខុ ភិក្ខុនី ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ

សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ការោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ ។

*ម្នាលអានន្ទ បុគ្គលណាមួយទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែងប្រតិបត្តិតាមធម៌ បុគ្គលនោះឈ្មោះថាធ្វើសក្ការៈគោរពរាប់អានបូជាតថាគតដោយគ្រឿងបូជាដ៏ឧត្តម" ។*

## បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ

## ☝..ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ នេះជាមង្គលដ៏ឧត្តម។

## សរុបសេចក្ដីនៃមង្គលកថាក្នុងអដ្ឋកថា
## ពណ៌នាគាថាថា អសេវនា ច

ព្រះមានព្រះភាគ ទ្រង់ស្ដាប់ពាក្យទេវបុត្រនោះយ៉ាងនេះហើយ ទើបត្រាស់ព្រះគាថាថា អសេវនា ច ពាលានំ ជាដើម ។ ក្នុងគាថានោះ បទថា អសេវនា បានដល់ ការមិនសេពគប់មិនចូលទៅជិត ។

បទថា ពាលានំ សេចក្ដីថា ឈ្មោះថា **ពាល** ព្រោះជាទីនៅដកដង្ហើម អធិប្បាយថា នៅដោយត្រឹមតែដកដង្ហើមចូលចេញមិននៅដោយភាពជាអ្នកនៅដោយបញ្ញា ឈ្មោះថាពាលទាំងអស់ ។

បទថា **បណ្ឌិតានំ** សេចក្ដីថា ឈ្មោះថា បណ្ឌិត ព្រោះធ្វើដំណើរទៅ អធិប្បាយថា ធ្វើដំណើរទៅដោយគតិ គឺការស្គាល់នូវប្រយោជន៍ ដែលជាបច្ចុប្បន្ននិងបរលោក ឈ្មោះថា បណ្ឌិត ទាំងអស់ ។

បទថា សេវនា បានដល់ ការគប់ការចូលជិតការមានបណ្ឌិតនោះជាសំឡាញ់ មានបណ្ឌិតនោះជាមិត្ត ការព្រមព្រៀង

ដោយបណ្ឌិតនោះ ។

បទថា បូជា បានដល់ សក្ការៈ គោរពរាប់អាន ការថ្វាយបង្គំ ។

បទថា បូជនេយ្យានំ ប្រែថា អ្នកគួរបូជា ។

បទថា **ឯតមង្គលមុត្តមំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ប្រមូលការមិនសេពគប់បុគ្គលពាល ១ ការបុគ្គលគប់បណ្ឌិត ១ ការបូជាអ្នកដែលគួរបូជា ១ ទាំងអស់ទើបត្រាស់ថា **ឯតមង្គល-មុត្តម** ។ លោកអធិប្បាយថា ពាក្យណាលោកសួរថា សូមទ្រង់សម្តែងនូវមង្គលដ៏ឧត្តម ទើបលោកកាន់យកពាក្យនោះថា មង្គលដ៏ឧត្តម ក្នុងសេចក្តីមុន ។ នេះជាការពណ៌នាបទនៃគាថានេះ ។

ចំណែកការពណ៌នាសេចក្តីនៃបទនោះ គប្បីជ្រាបដូច្នេះ ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ទេវបុត្រនោះយ៉ាងនេះហើយទើបត្រាស់ព្រះគាថានេះថា អសេវនា ច ពាលានំ ជាដើម ។

ក្នុងគាថានោះ**គាថាមាន៤** គឺ **បុច្ឆិតគាថា អបុច្ឆិតគាថា សានុសន្ធិកគាថា អននុសន្ធិកគាថា** ។

បណ្តាគាថាទាំង៤នោះគាថា ដែលត្រូវអ្នកសួរសួរហើយទើបត្រាស់ ឈ្មោះថា **បុច្ឆិតគាថា** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "**បុច្ឆាមិ តំគោតម ភូរិបញ្ញ កថំករោ សាវកោ សាធុ ហោតិ** បពិត្រព្រះគោតម ទ្រង់មានព្រះបញ្ញាដូចជាផែនដី ខ្ញុំសូមក្រាបទូលសួរព្រះអង្គ បុគ្គលដែលចេញចាកផ្ទះ... ប្រតិបត្តិដូចម្តេចទើបហៅថា **សាវកល្អ**" ។ ហើយនឹងប្រយោគថា "**កថំ នុ ត្វំ មារិស ឱឃមតរិ** បពិត្រព្រះអង្គអ្នកនិរទុក្ខ ព្រះអង្គឆ្លងអន្លង់ដោយហេតុដូចម្តេចហ្ន៎" ។

គាថាដែលព្រះអង្គមិនមានគេសួរ ប៉ុន្តែត្រាស់ដោយអធ្យាស្រ័យរបស់ព្រះអង្គឯងឈ្មោះថា **អបុច្ឆិតគាថា** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "**យំ បរេ សុខតោ អាហុ តទរិយា អាហុ ទុក្ខតោ** ពួកជនពាលដទៃពោលនូវវត្ថុកាមណាថាជាសុខ ព្រះអរិយៈទាំងឡាយពោលនូវវត្ថុកាមនោះថាជាទុក្ខ" ។ គាថារបស់ព្រះពុទ្ធទាំងឡាយសូម្បីទាំងអស់ ឈ្មោះថា **សានុសន្ធិកគាថា** ព្រោះបាលីថា **សនិទានាហំ ភិក្ខវេ ធម្មំ ទេសេស្សាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌សមតាមហេតុ ។ ដែល

ឈ្មោះថា **អននុស្សុតិកគាថា** គាថាមិនមានហេតុ មិនមានក្នុងសាសនានេះ ។ ក៏បណ្តាគាថាទាំងនេះ ដូចពោលមកនេះគាថានេះ ឈ្មោះថា **បុច្ឆិតគាថា** ព្រោះជាគាថាដែលព្រះមានព្រះភាគ ត្រូវទេវបុត្រទូលសួរហើយ ទើបត្រាស់ឆ្លើយ ។ ក៏គាថានេះ ប្រាប់មនុស្សដែលមិនគួរសេពគប់បណ្តាមនុស្សដែលគួរសេពគប់និងមិនគួរសេពគប់ហើយ ទើបប្រាប់មនុស្សដែលគួរសេពគប់ប្រៀបដូចបុរសដែលឆ្លាតស្គាល់ផ្លូវ ស្គាល់ទាំងមិនមែនផ្លូវត្រូវគេសួរដល់ផ្លូវ ទើបប្រាប់ផ្លូវដែលគួរវៀរចាកជាដំបូងហើយប្រាប់ផ្លូវ ដែលគួរកាន់យកជាខាងក្រោយយ៉ាងនេះថា ក្នុងទីត្រង់នោះមានផ្លូវបំបែកពីរ ។ បណ្តាផ្លូវបំបែកពីរនោះ ពួកអ្នកចូរវៀរចាកផ្លូវខាងឆ្វេងហើយកាន់យកផ្លូវខាងស្តាំដូច្នោះ ។ ក៏ព្រះមានព្រះភាគប្រៀបដូចបុរសដ៏ឆ្លាតក្នុងផ្លូវ ដូចដែលត្រាស់ទុកថា ៖

**ម្នាលតិស្សៈ ពាក្យថា បុរសដែលឆ្លាតក្នុងផ្លូវនេះជាឈ្មោះរបស់តថាគតអរហន្តសម្មាសម្ពុទ្ធ មែនពិត តថាគតអរហន្តសម្មាសម្ពុទ្ធនោះ ដឹងលោកនេះលោកដទៃ ដឹងទីមានមច្ចុ ទាំងដឹងទីដែលមិនមានមច្ចុ ស្គាល់បណ្តាញនៃមារទាំងស្គាល់ទីដែលមិនមាន បណ្តាញនៃមារ ។**

ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគកាលត្រាស់ប្រាប់ដល់បុគ្គលដែលមិនគួរសេពគប់ជាមុន ទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាល ការសេពគប់បណ្ឌិត តាមពិត បុគ្គលពាលទាំងឡាយ មិនគួរសេពគប់ មិនគួរចូលទៅជិតដូចផ្លូវដែលគួរវៀរបង់តពីនោះ ក៏គួរសេពគប់ គួរចូលទៅជិតបណ្ឌិត ដូចផ្លូវដែលគួរកាន់យក ។ មានអ្នកសួរពោលថា ក៏ព្រោះហេតុអ្វី ? ព្រះមានព្រះភាគកាលត្រាស់មង្គល ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតជាមុន សូមពន្យល់ដូច្នេះ ព្រោះហេតុតែពួកទេវតានិងមនុស្សប្រកាន់ការយល់ឃើញថាមង្គលក្នុងវត្ថុដែលឃើញហើយជាដើមនេះ ដោយការសេពគប់បុគ្គលពាល ទាំងការសេពគប់បុគ្គលពាលនោះ ក៏មិនមែនជាមង្គលដូច្នោះព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសេពគប់នឹងបុគ្គលដែលមិនមែនជាកល្យាណមិត្ត ដែលបំបាក់ប្រយោជន៍លោកនេះ និងលោកខាងមុខហើយទ្រង់សរសើរការសមាគមជាមួយកល្យាណមិត្ត ដែលឱ្យសម្រេចប្រយោជន៍ក្នុងលោកទាំងពីរ ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតជាមុនដល់ទេវតា និងមនុស្សទាំងឡាយ ។

បណ្តាបុគ្គលពាល និងបណ្ឌិតទាំងឡាយនោះ សត្វទាំងឡាយណាដែលប្រកបដោយអកុសលកម្មបថ មានបាណាតិបាតជាដើម ឈ្មោះថា **ពាល** ។ បុគ្គលពាលទាំងនោះ គប្បីជ្រាបបានដោយអាការៈទាំង ៣ ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងព្រះសូត្រថា "ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ របស់បុគ្គលពាលនេះ មាន ៣ យ៉ាង" ។ ម្យ៉ាងទៀតគ្រូទាំង ៦ មានបូរណកស្សបជាដើម និងសត្វដទៃប្រាកដដូច្នោះទាំងនេះ គឺ ទេវទត្ត កោកាលិកៈ កដមោទកៈ តិស្សខណ្ឌទេវីបុត្រ សមុទ្ទទត្ត នាងចិញ្ចមាណវិកាជាដើម និងបងប្រុសរបស់ទីឃវិទៈ កាលពីអតីតគប្បីជ្រាបថា **ពាល** ។

ពាលទាំងនោះ រមែងញុំាងខ្លួនឯង និងបុគ្គលដែលធ្វើតាមពាក្យរបស់ខ្លួន ឱ្យវិនាសដោយទិដ្ឋិគតៈ ការយល់ឃើញដែលខ្លួនកាន់យកមិនល្អ ដូចផ្ទះដែលត្រូវភ្លើងឆេះ ។ ដូចបងប្រុសរបស់ទីឃវិទៈ ដួលដេកផ្ងារ ដោយអត្តភាពប្រមាណ ៦០ យោជន៍ ឆេះនៅក្នុងមហានរកដល់ទៅ ៤ ពុទ្ធន្តរ ហើយដូចត្រកូល ៥០០ ត្រកូលដែលពេញចិត្តទិដ្ឋិ ការយល់ឃើញរបស់បងប្រុសរបស់

ទីឃាវុទៈនោះ ចូលទៅនៅរួមជាសម្លាញ់របស់បងប្រុសទីឃាវុទៈនោះឯង ឆេះនៅក្នុងមហានរកដូច្នោះ ។ សមដូចព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ភ្លើងតែងឆេះរាលអំពីផ្ទះបបុស ឬផ្ទះស្មៅមកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូលមានសន្ទះទ្វារដ៏ជិតស្និទ្ធមានបង្អួចបិទជិតបាន ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះតែងកើតឡើងអំពីជនពាលមិនមែនកើតពីបណ្ឌិតទេ ឧបទ្រពទាំងឡាយណាមួយកើតឡើងឧបទ្រពទាំងអស់នោះតែងកើតឡើង អំពីជនពាលមិនមែនកើតអំពីបណ្ឌិតទេ ឧបស័គ្គទាំងឡាយណាមួយកើតឡើង ឧបស័គ្គទាំងអស់នោះ តែងកើតអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ក៏ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលប្រកបដោយភ័យដ៏ពន្លឹក បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ ជនពាលប្រកបដោយឧបទ្រព បណ្ឌិតមិនមានឧបទ្រពទេ ជនពាលប្រកបដោយឧបស័គ្គបណ្ឌិតមិនមានឧបស័គ្គទេ" ។

ម្យ៉ាងទៀត ពាលប្រៀបដូចត្រីស្អុយ អ្នកដែលសេពគប់ពាលនោះ ក៏ប្រៀបដូចកញ្ចប់ស្លឹកឈើដែលខ្ចប់ត្រីស្អុយ រមែងប្រទះនឹងភាវៈដែលវិញ្ញូជនបោះបង់ចោល និងស្អប់ខ្ពើម ។

សមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

បូតិមច្ឆំ កុសគ្គេន យោ

បូតិមច្ឆំ កុសគ្គេន យោ នរោ ឧបនយ្ហតិ
កុសាបិ បូតិ វាយន្តិ ឯវំ ពាលូបសេវនា ។

ជនណាខ្ចប់ត្រីស្អុយដោយស្បូវក្លាំង ស្បូវក្លាំងរបស់ជននោះទៅជាមានក្លិនស្អុយផ្សាយទៅ យ៉ាងណាមិញ ការសេពនឹងបុគ្គលពាលក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត កាលស្ដេចសក្កៈកំពូលអស់ពួកទេព ប្រទានពរដល់អកិត្តិបណ្ឌិតក៏ពោលយ៉ាងនេះថា ៖

ពាលំ ន បស្សេ ន សុណេ ន ច ពាលេន សំវសេ
ពាលេនល្លាបសល្លាបំ ន ករេ ន ច រោចយេ ។

អាត្មាសូមកុំឱ្យជួបនឹងមនុស្សពាល សូមកុំឱ្យឮដំណឹង

មនុស្សពាល សូមកុំឱ្យនៅរួមនឹងមនុស្សពាល សូមកុំឱ្យបានធ្វើទាំងកុំឱ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល ។

សក្កទេវរាជត្រាស់សួរថា ៖

កិន្នុ តេ អករំ ពាលោ វទ កស្សប ការណំ
កេន កស្សប ពាលស្ស ទស្សនំ នាភិកង្ខសិ ។

មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល ។

កិត្តិបណ្ឌិតឆ្លើយថា ៖

អនយំ នយតិ ទុម្មេធោ អធុរាយំ និយុញ្ជតិ
ទុន្នយោ សេយ្យសោ ហោតិ សម្មា វុត្តោ បកុប្បតិ
វិនយំ សោ ន ជានាតិ សាធុ តស្ស អទស្សនំ ។

បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ជាការប្រសើរ ( របស់បុគ្គលពាលនោះ ) បុគ្គលពាលបើទុកជាគេ

និយាយ ត្រូវក៏នៅតែខឹង បុគ្គលពាលរមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះជាការប្រពៃ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់តិះដៀលការសេពគប់បុគ្គលពាលដោយអាការៈទាំងពួងយ៉ាងនេះទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាលជាមង្គលឥឡូវនេះកាលនិងទ្រង់សរសើរការសេពគប់បណ្ឌិត ទើបត្រាស់ថា ការសេពគប់បណ្ឌិតទើបជាមង្គល ។

*បណ្តាសត្វទាំងឡាយ សត្វទាំងឡាយណាប្រកបដោយកុសលកម្មបថ ១០ មានចេតនាវៀរចាកបាណាតិបាតជាដើម ឈ្មោះថា* **បណ្ឌិត ។**

បណ្ឌិតទាំងឡាយនោះ គឺគេគប្បីដឹងបានដោយអាការៈទាំង ៣ ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ទុកក្នុងព្រះសូត្រថា "ម្នាលភិក្ខុទាំងឡាយ លក្ខណៈនៃបណ្ឌិតមាន ៣ ពួកនេះ" ។ មយ៉ាងទៀតព្រះពុទ្ធ ព្រះបច្ចេកពុទ្ធព្រះអសីតិមហាសាវក ព្រះសាវកឯទៀតរបស់តថាគតនិងបណ្ឌិត មានសុនេត្ត សាស្តា មហាគោវិន្ទសាស្តា ព្រះវិធូរបណ្ឌិត សរភង្គតាបស ព្រះមហោ-

សថ សុតសោមបណ្ឌិត ព្រះបាទនេមិរាជ អយោឃរកុមារ និង អកិត្តិបណ្ឌិតជាដើមគប្បីជ្រាបថាជា **បណ្ឌិត** ។

បណ្ឌិតទាំងឡាយនោះ ជាអ្នកកម្ចាត់ភ័យឧបទ្រព និង ឧបស័គ្គបាន ក្នុងវេលាមានភ័យ បីដូចជាដួងប្រទីបក្នុងវេលាងងឹត ហាក់បីដូចជាបានបាយទឹកជាដើម ក្នុងវេលាត្រូវទុក្ខមានការស្រេក ឃ្លានជាដើមគ្របសង្កត់ ។ ពិតមែនហើយ ព្រោះការអាស្រ័យ ព្រះតថាគត ទើបពួកទេវតានិងមនុស្សរាប់មិនបានប្រមាណមិនកើត នាំគ្នាសម្រេចធម៌ជាទីអស់ទៅនៃអាសវៈស្ថិតនៅក្នុងព្រហ្មលោក ស្ថិតនៅក្នុងទេវលោក កើតក្នុងសុគតិសួគ៌ ។ ត្រកូល ៨ ម៉ឺន ត្រកូលធ្វើចិត្តឱ្យជ្រះថ្លាក្នុងព្រះសារីបុត្តត្ថេរៈ និងផ្គត់ផ្គង់ព្រះថេរៈ ដោយបច្ច័យ ៤ ក៏ទៅកើតក្នុងឋានសួគ៌ ។ ត្រកូលទាំងឡាយធ្វើ ចិត្តឱ្យជ្រះថ្លាក្នុងព្រះមហាសាវកទាំងឡាយ រាប់តាំងពីព្រះមោគ្គ-ល្លាន ព្រះមហាកស្សបៈជាដើមទៅ យ៉ាងនោះដូចគ្នា ។ សាវក ទាំងឡាយរបស់សុនេត្តសាស្ដា អ្នកខ្លះក៏កើតក្នុងព្រហ្មលោក អ្នក ខ្លះក៏បានជាសម្លាញ់របស់ទេវតា ជាន់បរនិម្មិតវសវតី ។ល ។ អ្នកខ្លះក៏បានជាសម្លាញ់នៃគហបតិមហាសាល ។ សូម្បីព្រះដ៏មាន

ព្រះភាគជាម្ចាស់ ក៏បានត្រាស់ទុកដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានអំពីបណ្ឌិត ឧបទ្រពមិនមានអំពីបណ្ឌិត ឧបស័គ្គ មិនមានអំពីបណ្ឌិតទេ" ។ ម្យ៉ាងវិញទៀត បណ្ឌិតដូចជារបស់ក្រអូប មានក្រស្នានិងផ្កាឈើជាដើម អ្នកដែលសេពគប់បណ្ឌិតក៏ដូចជាកញ្ចប់ស្លឹកឈើ ដែលខ្ចប់របស់ក្រអូប មានក្រស្នា និងផ្កាឈើជាដើម ថែមទាំងប្រសព្វភាវៈដែលវិញ្ញូជនកោតសរសើរ និងពេញចិត្ត ។

សូម្បីព្រះដ៏មានព្រះភាគជាម្ចាស់ក៏ត្រាស់ទុកដូច្នេះថា ៖

**តគរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ**

**បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា ។**

នរជនណាខ្ចប់ក្រស្នាដោយស្លឹកឈើ ស្លឹកឈើរបស់នរជននោះទៅជាមានក្លិនប្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពបុគ្គលជាអ្នកប្រាជ្ញ ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀតកាលស្ដេចសក្កៈជាកំពូលអស់ពួកទេពប្រទានពរដល់អកិត្តិបណ្ឌិតក៏ពោលថា ៖

**ធីរំ បស្សេ សុណេ ធីរំ ធីរេន សហ សំវសេ**

ធីរេនល្ហាបសល្ហាបំ តំ ការេ តញ្ចុ រោចយេ ។

អាត្មាសូមឱ្យជួបប្រទះអ្នកប្រាជ្ញ សូមឱ្យស្ដាប់អ្នកប្រាជ្ញ សូមឱ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឱ្យបានធ្វើ ទាំងសូមឱ្យបានចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។

ស្ដេចសក្កៈកំពូលអស់ទេវតាត្រាស់សួរថា ៖

កិន្នុតេអការំ ធីរោ វទ កិន្នុ ធីរោ កស្សប ការណំ

កេន កស្សប ធីរស្ស ទស្សនំ អភិកង្ខសិ ។

អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។

អកិត្តិបណ្ឌិតឆ្លើយថា ៖

នយំ នយតិ មេធាវី អធុរាយំ នយុញ្ជតិ

សុនយោ សេយ្យសោ ហោតិ សម្មា វុត្តោ ន កុប្បតិ

វិនយំ សោ បជានាតិ សាធុ តេន សម្មា គមោ ។

អ្នកប្រាជ្ញ រមែងណែនាំនូវហេតុ ដែលគួរដឹកនាំរមែងមិន

ប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ (របស់អ្នកប្រាជ្ញនោះ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែង មិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ការសេពគប់ជាមួយ នឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។

កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សរសើរការ សេពគប់បណ្ឌិតដោយធម៌ទាំងពួងយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ ថា ការសេពគប់បណ្ឌិត ជាមង្គល ។ ឥឡូវនេះ កាលនឹងទ្រង់ សរសើរការបូជា បុគ្គលដែលចូលដល់ភាពជាបុគ្គលដែលគួរបូជា តាមលំដាប់ ដោយការមិនសេពគប់បុគ្គលពាលនិងការសេពគប់ បណ្ឌិតនោះ ទើបទ្រង់ត្រាស់ថា **បូជា ច បូជនេយ្យានំ មង្គលំ** ការបូជាអ្នកដែលគួរបូជាជាមង្គល ។ ព្រះដ៏មានព្រះភាពជាម្ចាស់ ឈ្មោះថា **បូជនេយ្យ** ព្រោះទ្រង់វៀរចាកទោសគ្រប់យ៉ាង និងទ្រង់ ប្រកបដោយគុណគ្រប់យ៉ាងហើយ បន្ទាប់ពីនោះ គឺព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវកទាំងឡាយ ឈ្មោះថា **បូជនេយ្យ** ។ ពិត ហើយ ការបូជាបូជនេយ្យបុគ្គលទាំងឡាយនោះ សូម្បីតិចតួចក៏ ជាប្រយោជន៍សុខរហូតអស់កាលវែង ។ ក៏ក្នុងសេចក្ដីនេះមាន

រឿងសុមនមាលាការ និង នាងមល្លិកាជាដើមជាឧទាហរណ៍ ។ ក្នុងពីររឿងនោះនឹងពោលតែរឿងមួយ ល្មមទុកជាឧទាហរណ៍ ៖

មានសេចក្តីថា ព្រឹកថ្ងៃមួយព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ស្លៀកស្បង់និងចីវរប្រដាប់ដោយបាត្រ ស្តេចយាងចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ខណៈនោះនាយមាលាការ ឈ្មោះសុមនៈ កំពុងដើរកាន់ផ្កា សម្រាប់ថ្វាយព្រះបាទពិម្ពិសារមគធសេនយរាជ បានឃើញព្រះដ៏មានព្រះភាគយាងដល់ទ្វារក្រុង ឃើញសម្បុរ ផូរផង់គួរឱ្យជ្រះថ្លា ដែលប្រកបដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ប្រការ រុងរឿងដោយពុទ្ធសិរី ពេលដែលឃើញហើយក៏គិតថា ព្រះរាជាទ្រង់ទទួលផ្កាឈើនេះហើយ ក៏នឹងគប្បីប្រទានទ្រព្យ ១០០ ឬក៏ ១០០០ ក៏ការធ្វើដូច្នោះ គឺគប្បីបានសេចក្តីសុខត្រឹមតែលោកនេះប៉ុណ្ណោះ តែការបូជាព្រះដ៏មានព្រះភាគជាម្ចាស់ រមែងមានផលរាប់មិនបានប្រមាណមិនកើតនាំប្រយោជន៍សុខមកឱ្យរហូតអស់កាលវែង ណ្ហើយចុះ យើងនឹងបូជាព្រះដ៏មានព្រះភាគជាម្ចាស់ដោយផ្កាឈើទាំងឡាយនេះដូច្នេះហើយ គាត់ក៏មានចិត្តជ្រះថ្លាចាប់ផ្កាឈើមួយក្តាប់បាចទៅចំពោះ

មុខព្រះដ៏មានព្រះភាគ ផ្កាឈើទាំងឡាយនោះអណ្តែតទៅលើអាកាស ប្រតិស្ថានជាពិដាននៅលើព្រះដ៏មានព្រះភាគជាម្ចាស់ ។ នាយមាលាការឃើញអានុភាពនោះ ក៏មានចិត្តជ្រះថ្លាក្រៃលែងឡើង ទើបបាចផ្កាឈើទៅមួយក្តាប់ទៀត សូម្បីផ្កាឈើទាំងនោះក៏ទៅប្រតិស្ថានជារនាំងបាំង ។ នាយមាលាការបាចផ្កាឈើទៅ ៤ ក្តាប់ យ៉ាងនេះ សូម្បីផ្កាឈើទាំងអស់នោះ ក៏ទៅប្រតិស្ថានជាផ្ទះកំពូលបាំងជុំវិញព្រះដ៏មានព្រះភាគ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ប្រថាប់នៅក្នុងផ្ទះកំពូលនោះ មហាជនក៏មកប្រជុំគ្នា ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទតព្រះនេត្រឃើញនាយមាលាការ ក៏ទ្រង់ធ្វើអាការៈញញឹមឱ្យប្រាកដឡើង ។ ព្រះអានន្ទត្ថេរ ក៏ទូលសួរអំពីហេតុ ដែលទ្រង់ញញឹមដោយគិតថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មិនមានហេតុ មិនមានបច្ច័យនឹងមិនទ្រង់ញញឹមឱ្យប្រាកដទេ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ថា អានន្ទនាយមាលាការម្នាក់នេះ នឹង ត្រាច់រង្គត់ទៅក្នុងឋានទេវ-លោក និងមនុស្សលោកអស់សែនកប្ប ដោយអានុភាពនៃការបូជានេះ ហើយក្នុងទីបំផុតក៏បានជាព្រះបច្ចេកពុទ្ធ ព្រះនាមថា

**សុមនស្សរ:** ។ ត្រាស់ចប់ ក៏ត្រាស់ព្រះគាថានេះ ដើម្បីទ្រង់សម្ដែងធម៌ថា ៖

តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមុមនោ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយរមែងមិនក្ដៅក្រហាយ ឬដល់នូវសេចក្ដីពេញចិត្តមានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

ចប់គាថានោះសត្វ៨៤.០០០បានសម្រេចធម៌ ។ ការបូជាបូជនេយ្យបុគ្គលទាំងអស់នោះ សូម្បីបន្តិចបន្តួចក៏គប្បីជ្រាបថា មានប្រយោជន៍សុខអស់កាលជាយូរអង្វែង ដោយប្រការដូច្នេះ ។

ក៏ការបូជានោះជាអាមិសបូជា នឹងចាំបាច់ពោលទៅថ្វីក្នុងបដិបត្តិបូជា ព្រោះកុលបុត្រណា បូជាព្រះដ៏មានព្រះភាគជាម្ចាស់ ដោយការទទួលសរណគមន៍ និងសិក្ខាបទដោយការសមាទានអង្គឧបោសថ និងដោយគុណទាំងឡាយរបស់ខ្លួនមានបារិសុទ្ធិសីល ៤ ជាដើម នរណាទៅហ្ន៎នឹងពណ៌នាផលនៃការបូជារបស់កុល-បុត្រនោះបាន ។ ត្បិតថា កុលបុត្រទាំងអស់នោះ លោកពោលថា

បូជាព្រះតថាគតដោយការបូជាយ៉ាងក្រៃលែង ដូចជាព្រះមានព្រះភាគ ជាម្ចាស់ត្រាស់ទុកថា ៖

"យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ភិក្ខុ ភិក្ខុនី ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ ។

ម្នាលអានន្ទ បុគ្គលណាមួយទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែងប្រតិបត្តិតាមធម៌ បុគ្គលនោះឈ្មោះថាធ្វើសក្ការៈគោរពរាប់អានបូជាតថាគតដោយគ្រឿងបូជាដ៏ឧត្តម" ។

សូម្បីភាពនៃការបូជាព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវក ក៏នាំមកនូវប្រយោជន៍សុខ គប្បីជ្រាបតាមន័យនេះ ។

ម្យ៉ាងទៀត គ្រហស្ថគប្បីជ្រាបបូជនេយ្យបុគ្គលក្នុងសេចក្តីនេះ យ៉ាងនេះគឺអ្នកចម្រើនដោយវ័យ ទាំងបងប្រុសទាំងបងស្រី ឈ្មោះថា បូជនេយ្យបុគ្គលរបស់ប្អូន មាតាបិតាជាបូជនេយ្យបុគ្គលរបស់បុត្រ ស្វាមីឪពុកក្មេកម្តាយក្មេកជាបូជនេយ្យបុគ្គលរបស់ស្ត្រី

មានប្ដីទាំងឡាយ ដ្បិតថា ការបូជាបូជនេយ្យបុគ្គលទាំងអស់នោះ ជាមង្គលទាំងអស់ ព្រោះរាប់ថាជាកុសលធម៌ និងព្រោះជាហេតុនៃការចម្រើនអាយុជាដើម ព្រះដ៏មានព្រះភាគជាម្ចាស់ មានព្រះពុទ្ធតម្រាស់ទុកដូច្នេះថា ៖

"សត្វទាំងនោះ ក៏ជាអ្នកគោរពមាតា គោរពបិតាគោរពសមណៈគោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងត្រកូលរៀបច្បងប្រព្រឹត្តសមាទាននូវកុសលធម៌នេះ ក៏បានចម្រើនអាយុចម្រើនពណ៌សម្បុរឡើងវិញ" ។

ឥឡូវនេះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាទុកថា សមុដ្ឋានជាកន្លែងកើតមង្គល ហើយកំណត់មង្គលនោះនឹងពន្យល់សេចក្ដីនៃមង្គលនោះដូច្នោះ ទើបសុំពន្យល់ដូច្នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់មង្គលនៃគាថានេះទុក ៣ មង្គល គឺការមិនសេពគប់បុគ្គលពាល ការសេពគប់បុគ្គលជាបណ្ឌិត និងការបូជាចំពោះបុគ្គលដែលគួរបូជា ដោយប្រការដូច្នេះ ។ បណ្ដាមង្គលទាំង ៣ នោះ គប្បីជ្រាបថា ការមិនសេពគប់បុគ្គលពាលឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍របស់លោកទាំង ២ ហេតុ

ការពារភ័យ មានភ័យកើតពីការសេពគប់បុគ្គលពាលជាបច្ច័យជាដើម ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជាឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃនិព្វាននិងសុគតិ តាមន័យដែលពោលទុកហើយក្នុងការពណ៌នាសេចក្ដីបន្ថែម នៃផលរបស់ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជានោះឯង ។ ប៉ុន្តែខ្ញុំនៅមិនទាន់បានសម្ដែងមាតិកា តពីនេះទៅនឹងកំណត់សេចក្ដីដែលជាមង្គលយ៉ាងនេះ ទើបនឹងពន្យល់សេចក្ដីនោះ ដែលជាមង្គល ។

# មង្គលកថាមង្គលទី ៣ ចប់

## គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស.២៥៥៧
-អដ្ឋកថាពន្យល់សេចក្តីនៃគម្ពីរព្រះត្រៃបិដក.ស.២៥២២
-មង្គលត្ថទីបនីភាគ ១ របស់ព្រះមហាឃិន នឿន ព.ស.២៥៣៨
-គម្ពីរឃ្លាំងបរិយត្តិភាគ ១-២ ព.ស. ២៥៥៧
-គម្ពីរធម្មាវលី របស់ភិក្ខុធម្មវរាចារ្យ
-មង្គលជីវិត របស់ព្រះភិក្ខុ វជិប្បញ្ញោ គូ សុភាព ព.ស.២៥៥៥
-មិត្តល្អ របស់ព្រះភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ ព.ស.២៥៥៥
-សង្គាលកសូត្ររបស់ព្រះភិក្ខុវជិរប្បញ្ញោ សាន សុជា ព.ស.២៥៥២
-វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១
-ព្រមទាំងឯកសាមួយចំនួនទៀត។

# ថ្ងៃល្អនៃជីវិត

*នៅក្នុងបិដកលេខ ៤១ ទំព័រ ៤៧៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុថាម្នាលភិក្ខុទាំងឡាយសត្វទាំងឡាយណាប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាព្រឹក វេលាថ្ងៃ វេលាល្ងាចសត្វទាំងនោះឈ្មោះថា មានវេលាព្រឹកដ៏ល្អ វេលាថ្ងៃដ៏ល្អ វេលាល្ងាចដ៏ល្អ។ សមដូចព្រះគាថាថា៖*

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**
**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ។**

*ថ្ងៃណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ថ្ងៃនោះឈ្មោះថា នក្ខត្តបឫក្សល្អ មង្គលល្អ ថ្ងៃភ្លឺស្វាងល្អ ថ្ងៃនៃអរុណរះឡើងល្អខណៈល្អយាមល្អ (ទានដែលបុគ្គលបូជាហើយ)ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះឈ្មោះថា ជាគ្រឿងបូជាល្អ។*